ទបបសាធារណរដ្ឋនិយម_ ផ្តល់ដល់ខ្មែរគ្រប់រូប នូវសិទ្ធិស្មើ ៗ គ្នា ចាំងអស់ទៅតាមសមត្ថភាព និងកិច្ចការទបស់ខ្មែរម្នាក់ ៗ ។ តែសមភាពនឹងជាក់ស្តែង ចំពោះខ្មែរអ្នកសាធារណរដ្ឋនិយម គឺការគ្មានស្តេចនេះឯង គឺយើងបំបាត់ចោលនូវឫទ្ធិសិទ្ធិពីកំណើត បើយខ្មែរយើងគ្រប់រូប_ សុទ្ធសឹងជាទាស្តែរដូច ៗ គ្នា ។ យើងនឹងយកច្បាប់ប្រជាធិបតេយ្យ មកអនុវត្ត ដើម្បីខ្មែរម្នាក់ ៗ មានជាអង្គការគាំទ្រណែនាំឲ្យចូលរួមក្នុងការស្តាបជាជាតិ ក្នុងការកសាងជីវភាពប្រជាជាតិ ដើម្បីឲ្យមានការទស់ប្រសើរសមទមប្រគប់ ៗ គ្នា ។ ក្នុងន័យនេះ យើងនឹងតាក់តែងឲ្យទៅជាក្បាច់សំទាប់សង្គមខ្មែរយើង ដែលម្នាក់ ៗ មានកទណ័យកិច្ច ត្រូវទៃតែគោរព ដើម្បីឲ្យកម្រិតជីវភាពប្រជាជាតិយើង ឆាប់ឮនទេ្ធងខ្ពស់សមទមឲ្យ ខ្មែរខ្មែរយើងឮន

សប្បាយជាង មានស្តេចរាជ្យអង្វែងជាង ។

o

o o

ចំពោះភាតរភាព គឺការប្រកួតប្រជែងគ្នាជាបងប្អូន

សេរីភាព និង សមភាព ពិតប្រាកដ នឹងនាំមកនូវភាតរភាពដល់ប្រជាជាតិយើង គឺថាខ្មែរយើងទាល់តែរួបរាប់រកគ្នា និងពួតដៃស្មើស្មាច់ទល់ជាមួយគ្នា ដើម្បីប្រយោជន៍ដ៏ខ្ពង់ខ្ពស់នៃប្រទេសជាតិយើង ខ្មែរឯណាត្រឹមត្រូវទាំស្រុបលក្ខខណ្ឌប្រជាធិបតេយ្យ នាំយើងម្នាក់ៗ ខ្មែរទាល់តែបានផ្តោយព្រេញចិត្តទៀង ៗ ខ្លួន ។ ម្ល៉ោះហើយយើងចៀសឲ្យបានឱ្យការបែកបាក់ការប៉ះទង្គិចគ្នាគ្នាឯង ខ្មែរម្នាក់ៗ ត្រូវចៀសឲ្យការគិតតែប្រយោជន៍ផ្ទាល់ខ្លួន ហើយចេះគិត ចេះមានការសន្តោសដល់គ្នីគ្នា ថែមទាំងជួយគ្នាទៅវិញទៅមកស្របទៅនឹងធម៌ព្រះពុទ្ធផង ស្របទៅនឹងទំនៀមទម្លាប់ដើមរបស់ខ្មែរយើងផង ។

o

o o

ចំពោះ ទំនួលភាព គឺជាសេចក្តីចំទើន

សេរីភាព សមភាព និង ភាតរភាព ជាប្រភពនៃទំនួលភាព ព្រោះថាបើខ្មែរយើងមានសិទ្ធិត្រប់គ្រាន់ ទៅតាមរបបប្រជាធិបតេយ្យ មានលទ្ធភាពនឹងតម្លើងកំរិតជីវភាពឲ្យសមទម្យប្រហាក់ប្រហែលគ្នា ហើយចេះស្រឡាញ់រាប់រក ជួយនិងការពារទៅវិញទៅមកនោះ សង្គមខ្មែរយើងនឹងឲ្យមានភាពចំទើនទៅការគ្រប់គ្រាន់ការសម្បូណ៌សប្បាយជាមិនខាន ។ យើងនឹងប្រឹងទៀបចំប្រទេសយើង ឱ្យមានអង្គការត្រប់គ្រាន់ តាំងពីផ្ទះមួយក្រុម ៗ ភូមិឃុំ ចុងការរ៉ាមាក់ញឹកនឹមួយ ៗ ទូលតដល់ស្រុកខេត្តនិងក្រុងទៀតផង ។ គឺអង្គការទាំងនេះហើយដែលនឹងផ្តល់នូវលទ្ធភាពត្រប់បែបយ៉ាងដល់ត្រប់ ៗ គ្នា ជួយឱ្យខ្មែរត្រប់ ៗ រូបមានមុខរបរដើម្បីទៅការរ៉ាសេចក្តីចំទើន ។

ហើយយើងត្រូវដឹងថា " តម្លៃរបស់មនុស្សម្នាក់ ៗ ស្ថិតនៅត្រង់ស្គាល់សារៈសំខាន់នៃការណែកិច្ចរបស់ខ្លួន ដែលតម្រូវឱ្យចំពេញកិច្ចការជាមួយនឹងគេឯងឱ្យបានច្បាស់លាស់ត្រឹមត្រូវ ដើម្បីទៅដល់ដំណាក់ជីវភាពសមទម្យស្របតាមគោលបំណងរបស់យើង "។

ដើម្បីទស្សឱ្យបានសមទម្យជាការចាំបាច់ យើងម្នាក់ ៗ ត្រូវទំការរបទិភោគផង បង្កើតនិងបង្កើនផលផង ។ ក្នុងកិច្ចបង្កើនផលនេះ យើងនឹងយកកប្បាច់និងកប្បនវិទ្យាសាស្ត្រសម័យនិយមមកអនុវត្ត គឺនិយមខិតខំយកគ្រឿងចក្រនិងបច្ចេកទេសសម័យមកប្រើព្រមទាំងយកគំនិតសហប្រ-

តិបត្តិការថ្មី ទាំងទន្លេនិងប្រជាពលរដ្ឋមកនិយម ឱ្យទៅតាមប្រយោជន៍ប្រជាពលរដ្ឋនិងរដ្ឋ ។ រដ្ឋនិងផ្នែងផ្តើមណែនាំជួយកម្លាំងពលរដ្ឋណា ដែលចេះរួបរួមគ្នា ដើម្បីទៅការពារសេចក្តីចំរើន ។ ចំណែកខ្លាំងអង្គការទាំងជនជាតិដែលមានធនធ្ងន់ល្ហែ អង្គការទាំងជនទាំងនោះត្រូវតែចូលប្រកួតកម្លាំងគ្នាជាមួយប្រជាពលរដ្ឋ ដើម្បីដំកើងនូវភាពនិងជីវភាពយើងទាំងអស់គ្នា ។

យើងមិនភ្លេចទេថា សម័យនេះជាសម័យប្រយុទ្ធ សំរាប់ទៀបចំទុកទៅគ្រប់វិស័យ ស្មែងរកមធ្យោបាយចប្រាស់លាស់ និងអញ្ជើញប្រជាពលរដ្ឋឱ្យចូលរួមព្រម ៗ គ្នា ក្នុងការស្តារបនាជាតិ ដើម្បីឱ្យមានទម្លាប់ភាព ទាំងប្រជាជាតិយើងទាំងអស់ ទៅតាមលំនាំប្រទេសនានា មានប្រទេសដង្កប់ និង អ៊ីស្រាអែលជាគោល ។

o

o o

ចំពោះ សុភមង្គល តើការសម្ព័ន្ធលីសបប្បាយ

ការចំរើន នាំមកនូវការសម្ព័ន្ធលីសបប្បាយដល់ខ្មែរយើងគ្រប់ ៗ រូប ។ ការស្រឡាញ់គ្នា ការស្មើមុខគ្នា និងសេរីភាព នាំឱ្យយើងយោគយល់គ្នា ប្រកបការងារព្រមគ្នា ហើយស្រឡាញ់គ្នា ជាហេតុនាំឱ្យយើងជៀសចាកនូវការប្រទូសរ៉ាយគ្រប់បែបយ៉ាង ហើយទម្លាប់ភាព កំរើតមានទៅក្នុងសង្គមខ្មែរ នេះហើយគឺសុភមង្គល ដែលយើងខំផ្តើឱ្យកើតមានដល់ប្រជាជាតិខ្មែរយើងទាំងអស់ តាមទបៀបប្រជាធិបតេយ្យ ។

ដើម្បីសម្រេចបាននូវគោលគំនិតទាំង ៥ ជាមូលដ្ឋាន ដែលសាធារណរដ្ឋខ្មែរជាការចាំបាច់ អ្នកដឹកនាំត្រូវយល់ឱ្យច្បាស់នូវគោលទាំងនេះ ហើយបង្រៀនឱ្យក្មួយៗដឹងនូវការគ្រោងបង្គាប់ឱ្យបានយល់ច្បាស់ ហើយអនុវត្តឱ្យបានត្រឹមត្រូវទំពោះខ្លួនឯងម្នាក់ ៗ ផង ចំពោះកិច្ចការខ្លួនផង ចំពោះប្រជាពលរដ្ឋផង ។ ក្នុងកិច្ចការគ្រប់ចំពូកត្រូវតែយកចិត្តទុកដាក់ប្រជាធិបតេយ្យ ដែលយើងទាំងអស់គ្នាសន្មតជាមួយគ្នា យកមកអនុវត្ត ។ ដូច្នេះក្នុងន័យនេះ ការទាក់ទងឱ្យបានប្រសើរជាមួយសាធារណជន ត្រូវទុកជាករណីយកិច្ចដ៏ពិសិដ្ឋ ខានពុំបានមួយរបស់អ្នកបំរើនដ្ឋគ្រប់ជាន់ថ្នាក់ ។

ជាទីបញ្ចប់ ក្នុងផ្នែកនយោបាយ យើងនឹងផ្តួកម្លាំងប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានឥតទើសមុខ ដើម្បីទៀបចំប្រជាជាតិយើង សម្រាប់ការពារប្រទេសយើងឱ្យសក្តិសិទ្ធិប្រទាំងនឹងគ្រប់ការឈ្លានពានរបស់បច្ចាមិត្រ ក្នុងពេលនេះក៏ដូចពេលក្រោយ ។

ទបបត្រគប់គ្រងប្រទេសយើង ជារបបសាធារណរដ្ឋនិយម ទាក់ទាញប្រជាពលរដ្ឋ

ទាំងអស់ខ្ញុំប្រុលរួមដោយស្មោះចិត្ត ក្នុងកិច្ចការការពារនិងការពារជាតិ ទបបយើងមិនមែនជាទបប រួមសម្បាថ្នាក់ការ ប៉ុន្តែទេសីភាពនោះទេដែរ ។

ធម្មោចារយក្រៅប្រទេសទបបយើង គឺធម្មោចារយ សន្តិភាព ស្វែងរកសុខ ស្វែងរកមិត្រ គឺថា យើងជាមិត្រនិងគ្រប់ប្រទេសទាំងអស់ ទោះជាប្រទេសនោះ មានឈ្មោះ សម្បុរ - មនោគមវិជ្ជា និងជំនឿទ្រឹស្តីសាសនាខុសគ្នាយ៉ាងណាក៏ដោយ យើងក៏ស្មើលែងតែប្រទេសណាឈ្លានឈ្លានពានយើង ។ ហើយយើងនៅតែប្រកាន់ធម្មោចារយ : ឯករាជភាព អព្យាក្រឹត្យភាពដែល ។

o

o o

ខ្ញុំព្រះករុណា សូមលើកកាយថ្វាយបង្គំសម្តេចព្រះសង្ឃនាយកទាំងពីរព្រះអង្គ និងព្រះសង្ឃទាំងពីរគណៈ សូមសម្តេច និងព្រះអង្គ ទ្រទង់ប្រកបដោយជោគជ័យសិរីមង្គលគ្រប់ប្រការ ។

សូមឱ្យបងប្អូនទាំងអស់ នៅតំបន់ដីតូច្ចាយ ប្រកបតែនឹងសេចក្តីសុខ សេចក្តីចំរើន។ ឆ្នាំខ្ញុំសូមបួងសួងដល់វត្ថុសក្តិសិទ្ធិទាំងឡាយ ជួយបងប្អូន ដែលសុទ្ធសឹងជាយុទ្ធជន ឱ្យប្រាជ្ញឈ្លេបពួកទមិឡឡាណពាន ឱ្យព្រំដែនជោគជ័យក្នុងការពារសាងជីវភាពទ្បើង ពុខ្លួន ដើម្បី សាធារណរដ្ឋយើង ។

ឆន្ទៈប្រជារាស្ត្រ-

នៅថ្ងៃ ៤ មេសា ១៩៧០ លោកនាយករដ្ឋមន្ត្រី លន់ ណល់ ប្រារព្ធអំពាវនាវ ប្រជារាស្ត្រ ដើម្បីសុំយោបល់ពីរបបសាធារណរដ្ឋ ។ ថ្ងៃទី ៥ មេសា មហាសន្និបាតមេធាវី អ្នកច្បាប់ ប្រារព្ធសម្រេចជាឯកច្ឆន្ទ លុបចោលរបបរាជានិយម ។ ទីឯពួកព្យាយាត្រាមហាសាមគ្គី ពីថ្ងៃ ១១ មេសា ១៩៧០ ក៏ប្រារព្ធសម្តែងនូវសេចក្តីចង់ប្រារព្ធរបបសាធារណរដ្ឋ ដោយសម្រែកជ័យ-ឃោសក្តី ដោយសម្លេងតំណាងជាតាក្តី មានតំណាងខេត្តជាដើម ថែលសុំឱ្យរដ្ឋាភិបាលប្រកាសកម្ពុជាជាសាធារណរដ្ឋ ។ ចំណែកប្រជាពលរដ្ឋនៅបែកខាងលិចទន្លេមេគុងក៏ប្រារព្ធផ្ញើញត្តិមកជូនរដ្ឋាភិបាល ក្នុងចំណងសុំឱ្យរដ្ឋាភិបាលប្រកាសកម្ពុជា ជាសាធារណរដ្ឋដែរ ។

ច្បាប់ស្តីពីការប្រកាសសាធារណរដ្ឋខ្មែរ ។

ក្រោមអធិបតីភាពលោកប្រធាន អ៊ិន តាំ រដ្ឋសភា ប្រជុំពីថ្ងៃ ៣-១០-៧០ បានព្រះរាជាតអនុម័តជាឯកច្ឆន្ទ នូវច្បាប់រដ្ឋធម្មនុញ្ញស្តីអំពីការប្រកាសសាធារណរដ្ឋខ្មែរ ។ ក្នុងសេចក្តីនៃច្បាប់នេះមានចែងថា " ប្រទេសខ្មែរជាសាធារណរដ្ឋតែមួយ ដែលមិនបែងចែកពុំបាន " ។

នៅសម័យប្រជុំនេះដែរបើយ៉ាមុនការអនុម័តច្បាប់នេះ រដ្ឋសភាបានអនុម័តជាឯកច្ឆន្ទ នូវនិយមន័យជាតិ ទង់ជាតិ និងរដ្ឋសង្ឃាថ្មី ទៀបំពេញដោយគណៈកម្មការទស្រាវជ្រាវជាតិ និងគណៈកម្មការតុលាការ និងរដ្ឋធម្មនុញ្ញនៃរដ្ឋសភាជាដំណួសនិយមន័យជាតិ ទង់ជាតិ ទាំងសង្ឃានៃរបបបាស ។

ខាងក្រោមនេះជាអត្ថបទទាំងស្រុងនៃច្បាប់រដ្ឋធម្មនុញ្ញស្តីពីការប្រកាសសាធារណរដ្ឋខ្មែរ ។

លេខ ៤៤២-៧០-បរ.

ន គ រ ភ ជ ា

ក្រម

ប្រមុខរដ្ឋ

ឃើញរដ្ឋធម្មនុញ្ញនៃប្រទេសខ្មែរ ជាអាទិ ត្រង់មាត្រា ៥៤ ។

ឃើញសេចក្តីសម្រេចដ៏ត្រឹមត្រូវតាមច្បាប់នៅថ្ងៃទី ១៨ ខែមីនា គ.ស. ១៩៧០ នៃសភាទាំងពីរ ស្តីពីការទម្លាក់នូវសិទ្ធិពុំ ពីមុខតំណែងជាប្រមុខរដ្ឋ ។

ឃើញព្យហយាត្រាកាលពីថ្ងៃទី ១១ ខែមេសា គ.ស.១៩៧០ ។

ឃើញឆន្ទៈតទាំងឡាយនៃប្រជាជាតិប៉ុន្មែរប្រកាសប្រទេសខ្មែរជាសាធារណរដ្ឋ ។

ឃើញសេចក្តីសម្រេចជាឯកច្ឆន្ទនៃសភាទាំងពីរនៅពេលប្រជុំរួមនាថ្ងៃទី៥ ខែតុលា គ.ស. ១៩៧០ ថាត្រូវតែប្រកាសទុកប្រទេសខ្មែរជាសាធារណរដ្ឋ ចាប់តាំងពីថ្ងៃទី ៩ ខែតុលា គ.ស. ១៩៧០ តទៅ ព្រមទាំងបង្គាប់ឱ្យគណៈកម្មការតុលាការ និង រដ្ឋធម្មនុញ្ញ ពិនិត្យនីតិវិធីច្បាប់ ដើម្បីប្រកាសនូវសាធារណរដ្ឋនេះ ។

ប្រកាសឱ្យប្រើ :

ច្បាប់ដែលរដ្ឋសភាបានអនុម័តពីថ្ងៃទី ១៧ ខែតុលា គ.ស. ១៩៧០ បើយដែល

មានសេចក្តីដូចតទៅនេះ :-

"ច្បាប់នៃធម្មនុញ្ញ ស្តីពីការប្រកាសប្រទេសខ្មែរជាសាធារណរដ្ឋ" ។

មាត្រាមួយ- ប្រទេសខ្មែរជាសាធារណរដ្ឋតែមួយដែលបែងចែកពុំបាន ។

សាធារណរដ្ឋនេះមានឈ្មោះជាផ្លូវការថា "សាធារណរដ្ឋខ្មែរ" ។

ការប្រកាសជាសាធារណរដ្ឋនឹងត្រូវធ្វើនៅថ្ងៃទី ៩ តុលា គ.ស.១៩៧០ វេលាម៉ោង ៧ ព្រឹក ដោយសភាទាំងពីរ ក្នុងនាមប្រជាជាតិខ្មែរទាំងមូលតាមសម្តែងនៃប្រធានទង្គសភា ។

មាត្រាពីរ- ក្នុងរយៈពេលដ៏ចាំបាច់ទៀបចំសាធារណរដ្ឋ និង អនុម័តនូវនីតិធម្មនុញ្ញថ្មី ឱ្យស្របទៅតាមរបបរដ្ឋាភិបាលជាសាធារណរដ្ឋនោះ នីតិធម្មនុញ្ញដែលនៅជាធរមានសព្វថ្ងៃនឹងទុកអនុវត្តតទៅជាបណ្តោះអាសន្ន លើកលែងតែបទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងគោលគំនិតនៃរបបរដ្ឋាភិបាលសាធារណរដ្ឋ ។

មាត្រាបី- ច្បាប់ និង បទបញ្ជាទាំងឡាយ ជាពិសេសបទបញ្ញត្តិនៃក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ឬទម្លាប់ច្បាប់ដែលធ្លាប់ប្រើប្រាស់ជាមកពីកំណើត ដែលជាបទបញ្ញត្តិផ្ទុយនឹងគោលការណ៍នៃរដ្ឋាភិបាលសាធារណរដ្ឋនោះ នឹងត្រូវទុកជាមោឃៈ ។

មាត្រាបួន- លោក ចេង ហេង ប្រមុខរដ្ឋនាបច្ចុប្បន្ន ត្រូវបន្តមុខតំណែងជាប្រមុខរដ្ឋតទៅទៀត រហូតដល់មានការជ្រើសរើសប្រធានាធិបតីមួយរូប ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ៨ តុលា គ.ស. ១៩៧០

ហត្ថលេខា : ចេង ហេង

ចំណាំ :

អំពីទៀងថ្ងៃប្រកាសសាធារណរដ្ឋនេះ មានមតិខ្លះសុំផ្លាស់ព្រោះខ្លាចមានការលំបាកដល់បេសកកម្ម ដើម្បីការគាំទ្រពីមហាសន្និបាតលើកទី ២៥ នៃ អ.ស.ប. ខាងមុខ ។ លោកនាយករដ្ឋមន្ត្រី លន់ នល់ ពុំឃើញស្រប ដោយសំអាងថា ប្រជារាស្ត្រ មន្ត្រីអ្នករដ្ឋការ ឬទ្ធជន ឬទ្ធជន ទន្ទឹងមកយូរហើយ ហើយថា តាមទំនាយ ការប្រកាសសាធារណរដ្ឋខ្មែរនៅថ្ងៃ ៩ តុលា ១៩៧០ វេលាម៉ោង ៧ នេះ នឹងប្រកបដោយជោគជ័យមហាប្រសើរ ហើយនិងថា ... ឮនទទួលឃើញព្រមពីលោក អ៊ូ-ថាន់ អគ្គលេខាធិការនៃ អ.ស.ប. ។ ដូច្នេះហើយឮនជាក្នុងថ្ងៃប្រកាសសាធារណរដ្ឋនោះ លោកប្រមុខរដ្ឋឮនចេញដំណើរភ្លាមទៅការដ៏ក្រុងញីវយ៉ក ដើម្បីទៀបចំកិច្ចការនានា មុនមហាសន្និបាត អ.ស.ប. នេះ ។ ឃើញថាឮនជោគជ័យមែន ដោយនៅក្នុងមហាសន្និបាតនេះ មានប្រទេស ៧១ ឮនគាំទ្រខ្មែរពេញទី ឯប្រទេសប្រឆាំងពីរ និងអនុប្បទាំង ៤៥ ថ្ងៃបើ អាល្បាងី ប្រើមធ្យោបាយគ្រប់បែបយ៉ាង ដើម្បីទាក់ទាញប្រទេសដទៃទៀតឱ្យបែរទៅរកសម្តេចសីហនុ ដូច្នាយថ្ងៃ ១៣-១១-៧០ ។

សកម្មភាពសម្តេចសីហនុក្រៅប្រទេស

ថ្ងៃ ១៨ មីនា ១៩៧០ សភាទាំងពីរបានប្រកាសទម្លាប់សម្តេចសីហនុ ចេញពីតំណែងប្រមុខរដ្ឋចាប់តាំងពីម៉ោង ១និង៣០នាទីរសៀលទៅ ។

បន្ទាប់ពីនេះមក វិទ្យុ និង វិទ្យុទូរទស្សន៍ទាំងបានផ្សាយដំណឹងនេះច្រើនដង ព្រោតពេញផ្ទៃនាបរន្តរជាតិ ។ ពេលនោះសម្តេចសីហនុបានចេញដំណើរពីប៉ារីសទៅដល់ក្រុងម៉ូស្គូហើយ ។ សម្តេចសីហនុលោកទ្រង់ជ្រាបនូវដំណឹងថា សភាទាំងពីរបានទម្លាក់លោកពីតំណែងប្រមុខរដ្ឋ នៅពេលដែលលោកចេញដំណើរពីក្រុងម៉ូស្គូ ។

នៅថ្ងៃ ១៩ មីនា ១៩៧០ សម្តេចសីហនុព្រមទាំងបរិវារបានទៅដល់ក្រុងប៉េកាំង។ ក្រោនៈតែចុះពីកប៉ាល់ហោះ សម្តេចសីហនុសើចលែងសម មុខទេដឿងស្លាំង ណាមួយខ្លាសគេផង ណាមួយឃើញបរិយាកាសដែលចិនទទួលដូចជាមិនសមនឹងតាមការដែលលោកបានស្មានពីនាយ ។

តីលោក ជូ អេន ឡាយ ដែលបានទៅទទួលសម្តេចសីហនុ ព្រមទាំងបានទូលសម្តេចថា ពួកបក្សកុម្មុយនិស្តគេទន្ទឹងចាំរូបសម្តេចនេះឯង ។

ក្រោយពេល ២៤ ម៉ោង ដែលសម្តេចសីហនុបានសញ្ជឹងគិត និងក្រោយពេលដែលបានសន្ទនាជាមួយ ជូ អេន ឡាយ និង ចាំ ឈុំង ដុង ដែយ ផ្ញើដំណើរពីហាណូយ ទៅជួបសម្តេចសីហនុនៅប៉េកាំងនោះមក សម្តេចសីហនុបានផ្ញើសេចក្តីថ្លែងការមួយច្រៀបពួកអ្នកសារពត៌មាន ថា ការដែលសភាទាំងពីរនៃប្រទេសកម្ពុជាទម្លាក់លោកពីតំណែងប្រមុខរដ្ឋនេះ ជាការផ្ទុយនឹងច្បាប់រដ្ឋធម្មនុញ្ញត្រង់មាត្រា ១២២ ពីព្រោះសម្តេចលោកយល់ថាក្នុងមាត្រានេះ លោកទ្រង់នៅជា "ប្រមុខរដ្ឋខ្មែរអស់មួយជីវិត" ។

នៅក្នុងសេចក្តីថ្លែងការដដែលនេះ សម្តេចលោកមានបន្ទូលថា លោកនឹងស៊ុំខ្លឿផ្ញើប្រជាមតិ ដែលមានការត្រួតពិនិត្យ ពីពួក (C. I. C) ។ ត្រង់នេះសម្តេចលោកភ្លេចគិតថា លោកខ្លួនឯងជាអ្នកដេញពួក (C.I.C) ចេញពីស្រុកខ្មែរនៅខែធ្នូ ១៩៦៩ ។

នៅថ្ងៃ ២១ មីនា ១៩៧០ សម្តេចសីហនុ ដោយដឹងថា លោកមិនអាចយកជ័យជំនះបាន ទើបលោកប្រកាសច្រៀបអ្នកសារពត៌មានថា : " Il n'est absolument pas dans mes intentions de chercher à retrouver le pouvoir que j'ai eu fait perdre ni à--conserver le titre, devenu dérisoire, de - Chef de l'Etat du Cambodge"..." Oui, désormais j'appartiens au passé et je le sais" ។ ដល់ ១៥ ថ្ងៃក្រោយមក គឺនៅថ្ងៃ ៥ មេសា ១៩៧០ ក្រោយ

ពីការឈប់ប្រមាថផ្ទៃការមួបញ្ចូនែនពួកដឹកនាំប្រទេសចិនកុម្មុយនិស្តមក សម្តេចសីហនុបានផ្ញើសេចក្តីថ្លែងការជាថ្មីមួយទៀតដល់ពួកអ្នកសារពត៌មានចិនទៅបេក៏ាង ។ នៅពេលមើលសេចក្តីថ្លែងការនេះ សម្តេចលោកមានបន្ទូលថាជាសេចក្តីថ្លែងការបកប្រែជាភាសាថ្មាំង ហាក់ដូចជាផ្ទុយនឹងសេចក្តីថ្លែងការដទៃ ។ បន្ថែមសម្តេចដដែលនិងបន្ថែមទិន្នន័យលោក ដែលផ្ញើសេចក្តីថ្លែងការជាភាសាថ្មាំងមកចម្លែកតែសេចក្តីថ្លែងការ នេះមួយដែលផ្សាយថាបកប្រែជាភាសាថ្មាំង ។

អ្នកណាដែលស្តាប់សម្តេចសីហនុច្បាស់ណាស់ មានការនឹងឮសំខាន់ចំពោះសេចក្តីថ្លែងការនេះដែលមាន " ពាក្យ " មាន " ឃ្លា " ខ្លះ ទាំងផ្ទុយពីចិត្តគំនិតសម្តេចទាំងស្រុង ដូចជាថា : " d'être le compagnon de route de notre peuple" ត្រង់នេះ គេមិនទាន់ដែលដឹងគេមិនទាន់ដឿឮថាសម្តេចលោកសុខចិត្ត " ដើរជាមួយនារ្ត " គឺលោកសុខចិត្តតែពីដឹកនាំនារ្តទៅវិញ ទើបគេអាចដឿឮបាន ។

មានឃ្លាខ្លះទៀតនាំផ្ទុយពីចិត្តគំនិតសម្តែងសីហនុទាំងស្រុងដូចជា : "d'accompagner notre jeunesse et nos intellectuels patriotes et progressistes dans leur lutte, leur résistance, leur révolution armée dont le but est d'assurer à notre nation une vie nouvelle basée sur une justice sociale pleine et entière, une démocratie authentiquement populaire" ។

ដប់ (១០) ថ្ងៃត្រឡប់មកទៀត គឺនៅថ្ងៃ ១៥ មេសា ១៩៧០ សម្តេចសីហនុបានសារភាពប្រកាសច្រាំងគេងងាមសារមួយថា លោកសុខចិត្តបើកការទាំងប្រហារប្រទេសខ្មែរ ដើម្បីជាក់ប្រទេសខ្មែរឱ្យទៅជាកុម្មុយនិស្ត ។ នេះជាសំដីខ្លះរបស់សម្តេចក្នុងសារនរបស់លោក : " L'échec de mon socialisme bouddhique est indéniable" សម្តេចបានបញ្ជាក់ទៀតថា : លោកគ្មានប្រសិទ្ធិភាពនឹង " résoudre les problèmes vitaux de la corruption, du chômage" ។ សម្តេចរលាកសំរេចចិត្តថានឹងទាយទន្ទឹកកិច្ចសងដែលរលាកបង្កើតខ្លួនលោក ព្រមទាំងរលាកបានមានបន្ទូលទៀតថា : " dans la lutte que je suis déterminé à mener jusqu'à son terme(ou tout au moins jusqu'à ma mort éventuelle dans le maquis où je m'intégrerai dans quelque temps) , je poursuis entre autres un but personnel" : " Je dirai que je veux me venger"។ លោកមានបន្ទូលទៀតថា :

"Désormais je suis engagé d'une façon irréversible dans le combat. A ce combat je donne un sens élevé. Je veux le mener avec mes partisans et avec notre jeunesse progressiste pour amener cette jeunesse au pouvoir et lui permettre ainsi de

réaliser son rêve de justice sociale et de socialisme (le socialisme tel qu'on l'entend dans les grands pays socialistes)"

ដើមឡើយ ក៏ចាំងខ្ទង់អំពើខ្ពក់ដ្ឋាន ពាន មកលើអធិបតីភាព និងបូរណភាពទឹកដីរបស់ខ្មែរ ពួកយួនយៀកកុង - យួនខាងជើង និងចៅហ្វាយរបស់គេ គឺ ចិនក្រហម ឲ្យានបង្កើតឱ្យមាន "រណសិរ្សរួបរួមកម្ពុជា" (FUNK) ដែលមានសមត្ថកិច្ចលើពន្ធុជា មេ បើយនិងបង្កើតរាជរដ្ឋាភិបាលរួបរួមប្រទេសកម្ពុជា (GRUNK) ។ រហស់បំរាប់ផ្ញើឲ្យប់ខែឡើងទាំងពីរនេះ ឲ្យានកើតទៀងទាត់ថ្ងៃ ៥ ខែសីហា ១៩៧០ គឺក្រោយការឡើងពាន ពួកយៀកកុង-យួនខាងជើងជំនួន១ខែមកលើទឹកដីយើង ។

រណសិរ្សរួបរួមកម្ពុជា (FUNK) មានសមាជិកដូចតទៅ :

១-សម្តេចសីហនុ.....ប្រធាន
២-សម្តេចប៊ែន នុត.....នាយការិយាល័យនយោបាយ
៣-ចៅ សេង.....សមាជិក
៤-ផ្លង សំអុល..... -ដ-
៥-ចាន់ យូរ៉ាន..... -ដ-
៦-ជា សាន..... -ដ-
៧-ហ៊ូ ឆន់..... -ដ- (បើសិនជា នៅរស់)
៨-ហ៊ូ និម..... -ដ- (បើសិនជា នៅរស់)
៩-ហួត សំផាត់..... -ដ-
១០-ខៀវ សំផន..... -ដ- (បើសិនជា នៅរស់)
១១-សារិន ឆាក..... -ដ-
១២-ជូន ម៉ឺ..... -ដ-

ក្នុងពេលថ្មីៗនេះ រណសិរ្សរួបរួមជាតិ (FUNK) តាមឯកសារខ្លះ គេឲ្យានដឹងថាមានក្រុម (២១) ចំកន្ទុយដូចតទៅ :

១-ពួកខ្មែរក្រហម (aile gauche du sangkum)
២-ព្រះសង្ឃទាំងពីរគណៈ (ទោះក្នុងឯកសារគ្មានឲ្យានចុះឈ្មោះព្រះសង្ឃណាមួយអង្គទេ)

---

(១)-មើលក្នុងសៀវភៅ Le Dossier Sihanouk ទំព័រ ៤៣ ។

៣_កងទ័ពរំដោះរបស់ប្រជាជនខ្មែរ (Forces armées populaires de libération khmère : F.A.P.L.K.)

៤_ពួកគណៈបក្សប្រជាជន (P.C. Cambodgien)

៥_ប្រជាពលរដ្ឋខ្មែរ (l'Union des paysans)

៦_សហជីពនៃនិជ្ជាជីវៈ: (le Syndicat des travailleurs)

៧_ l'union de la jeunesse démocratique

៨_ l'Association des femmes démocratiques

៩_ l'Association des intellectuels et enseignants patriotiques

១០_l'Association des écrivains

១១_ពួកថៃ និង ចាម នៅទតនៈគីទី ស្ថិតក្រៃង មណ្ឌលគីរី និង ក្រចេះ ។

១២_ Les Organisations démocratiques des Cambodgiens résidant à l'étranger.

ចំណែកខាងរាជរដ្ឋាភិបាលរួបរួមប្រទេសកម្ពុជា មានសមាសភាពដូចតទៅនេះ ។

១_សម្តេច ឪម៉ែន នុត នាយករាជរដ្ឋាភិបាលរួបរួមប្រទេសកម្ពុជា

២_ចៅ សេង រដ្ឋមន្ត្រីទទួលបន្ទុកខាងកិច្ចការពិសេស (នៅស្រុកចូរាំង)

៣_សារីន ងាក រដ្ឋមន្ត្រីខាងការបរទេស

៤_ចាន់ យូរ៉ាន់ រដ្ឋមន្ត្រីខាងអប់រំប្រជាពលរដ្ឋនិងយុវជន

៥_ខ្នុតមសេនីយ ង៉ោ ហ៊ី រដ្ឋមន្ត្រីក្រសួងសុខាភិបាល ក្រសួងធម្មការ និង សង្គមកិច្ច

៦_ជួន ម៉ុំ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

៧_ខ្នុតមសេនីយ ជួង សំអុល រដ្ឋមន្ត្រីក្រសួងផ្គត់ផ្គង់គ្រឿងសម្ភារៈសឹក

៨_ខៀវ សំអេន រដ្ឋមន្ត្រីក្រសួងការពារប្រទេស

៩_ហ៊ូ និម រដ្ឋមន្ត្រីក្រសួងឃោសនាការ

១០_ហ៊ូ យន់ រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

១១_ជា សាន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

១២_ហួត សំហ៊ាត់ រដ្ឋមន្ត្រីក្រសួងសាធារណការ និង ទូរគមនាគមន៍ ។

ក្នុងចំណោមរដ្ឋមន្ត្រីទាំង ១២ រូបមានតែរដ្ឋមន្ត្រីបីរូបទេ ដែលស្នាក់នៅក្រុងប៉េកាំង ។

នៅថ្ងៃ ២០ កក្កដា ១៩៧០ មានការកែប្រែគណៈរដ្ឋមន្ត្រីនេះ ជាលើកទី១ បន្ទាប់ពីមានការស៊ុះចូលនូវសមាជិកថ្មីពីរនូបទៀត គឺ : លោក គាត ឈន និងលោក

ជួនប្រុសុីត ។

-លោក ជួន ប្រុសុីត ជា រដ្ឋមន្ត្រីខាងការប្រៃប្រស័យទាក់ទង និងកិច្ចការតស៊ូ

-លោក តាត ឈន រដ្ឋមន្ត្រីប្រចាំភូនៅអមលោកនាយករដ្ឋមន្ត្រី ។

ក្នុងការស៊ុីឡូនតង់ទៀតទទួលស្គាល់ជា ផ្លូវច្បាប់ (reconnaissance de jure) ដល់រាជរដ្ឋាភិបាលរួបរួមប្រទេសកម្ពុជានេះ (GRUNK) នេះរហូតមកដល់ថ្ងៃទី ១ ធ្នូ ១៩៧០ មានតែប្រទេស ២៣ ទេ ក្នុងចំណោមពួកបក្ខពួកខាងកុម្មុយនិស្ត ដែលបានទទួលស្គាល់ជា ផ្លូវច្បាប់ ។ នៅក្នុងបក្ខពួកកុម្មុយនិស្តដទៃដែលនេះ ប្រទេសដែលមិនទទួលស្គាល់ (GRUNK) នេះ គឺ :

១- Union soviétique;

២- Allemagne de l'Est;

៣- Pologne;

៤- Tchécoslovaquie;

៥- Hongrie ។

នៅថ្ងៃទី ៤ កញ្ញា ១៩៧០ រណសិរ្សរួបរួមកម្ពុជា (FUNK) ត្រូវបញ្ចូលមកក្នុងរាជរដ្ឋាភិបាលរួបរួមប្រទេសកម្ពុជា (G.R.U.N.K) វិញ ។

បន្ទាប់មកមានការកែប្រែសមាសភាពរាជរដ្ឋាភិបាលនេះ ដោយបញ្ចូលសមាជិកថ្មី ពុំខ្លះទៀត ជាលើកទីពីរ ។

ការខ្វែងគំនិតគ្នាខ្លះ ពុំកំចេះតែមានកើតទៀងដោយម្ចាស់ឯកពីសមាជិកខ្លះប្រកាសថា ខ្លួនមិនចូលជាមួយសម្តេចសីហនុទេ ម្ចាស់ឯទៀតនៅមានការខ្វែងគំនិតគ្នាត្រង់ដាក់ពាក្យថា "រាជរដ្ឋាភិបាល" នាំផ្ទុយនឹង "កុម្មុយនិស្ត" ទៅវិញ ដូចមានសំដីខ្លះ ពុំ ចេញមកថា : " Ils ne sont pas sihanoukistes, ils sont tous khmers rouges. Le Gouvernement est maintenant de tendance nettement communisante car sur dix-neuf ministres et vice-ministres dix sont khmers rouges"

ដោយឃើញថា មានបរាជ័យចំពោះ " សង្គមនិយមព្រះពុទ្ធសាសនា " របស់សម្តេចសីហនុ ទើបសម្តេចលោកប្រកាសថា :" Il ne peut y avoir maintenant que le socialisme maxiste" លោកបន្ថែមទៀតថា : " Pour le moment, je leur suis encore indispensable, mais après la libération je ne le serai peut-être plus" ។

ក្រៅពីការពិភាក្សាបន្តិចមក ពួកអ្នកដឹកនាំរបស់ខ្ញុំនិងពួកខ្មែរក្រហម មិនឈ្លបក្រសួរតាមសម្តេងសីហនុទេ ។

ព្រមទាំងសម្តេចលោកមានបន្ទូលទៀតថា : " Le Gouvernement m'a prié de préciser que le gouvernement royal n'est pas communiste" បើយោងលោកឯកឧត្តមទៀតថា : " Son programme et son administration ne sont pas communistes mais progressistes". ។

ឯកឧត្តមសម្តេចសីហនុ ក្រឡេកមកសួរខ្ញុំបន្ថែមអំពីលោកឯកឧត្តមបញ្ជាក់ថា លោកទទួលបទបញ្ជាយ៉ាងតឹងរឹងពីពួកចិនកុម្មុយនិស្ត ព្រោះអីកាលពីបីឆ្នាំមុនទេនេះ គឺនៅថ្ងៃទី ៤ តុលា ១៩៦៧ លោកឯកឧត្តមបានបន្ទូលដូចតទៅទេនេះ : " Quand on est pris dans l'engrenage du communisme, on n'est plus libre, on abdique sa dignité d'homme" ។ .

X

X X

ចំពូកទី៤

- វិធានការរដ្ឋាភិបាលស្រែចម្ការស្រង់ជាតិ ចាត់
នៅក្នុងប្រទេស ដើម្បីកសាងសាធារណរដ្ឋខ្មែរ

- មតិសាធារណៈ

លេខ -១ -កច -៦០ -បរ

ក្រឹត្យ - ច្បាប់

ប្រមុខរដ្ឋប្រទេសកម្ពុជា

ឮនឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។

ឮនឃើញព្រះរាជក្រឹត្យលេខ ៤៥៩-៦៩-បរ ចុះថ្ងៃទី ១៤ សីហា គ.ស. ១៩៦៩ កែតម្រូវដោយអត្ថបទជាបន្តបន្ទាប់នៃ ស្តីពីការតែងតាំងគណៈរដ្ឋមន្ត្រី ។

ឮនឃើញ ក្រមលេខ ៤៣៣-៧០-បរ ចុះថ្ងៃទី ២៨ ខែមីនា គ.ស.១៩៧០ ប្រកាសថា ប្រជារាជាតិស្ថិតក្នុងភាពអាសន្ន ។

ឮនឃើញ ព្រះរាជក្រឹត្យលេខ ៦១៣-នស ចុះថ្ងៃទី ២៦ ខែកញ្ញា គ.ស. ១៩៥៨ កែតម្រូវដោយអត្ថបទជាបន្តបន្ទាប់មក នីដែលបង្កើតឱ្យមានក្រុមប្រឹក្សាជាន់ខ្ពស់ខាងការពារជាតិ ។

ឮនឃើញ ក្រមព្រហ្មទណ្ឌ និងច្បាប់អាជ្ញា និង ក្រមតុលាការសឹក នីដែលដាក់ឱ្យអនុវត្តដីតាមព្រះរាជក្រមលេខ ៨៥៩-នស ចុះថ្ងៃទី ១២ ខែកុម្ភៈ គ.ស.១៩៥៥ ។

គណៈរដ្ឋមន្ត្រី ឮនយល់ព្រមដែង ។

បង្គាប់ដូចមានខាងក្រោមនេះ :

ច្បាប់អាជ្ញាសឹក នីដែលមានសេចក្តីដូចតទៅនេះ :

មាត្រា ១- ត្រូវដាក់ទោសប្រហារជីវិតលើឈ្មួញដូចខាងក្រោម :

១-ជនទាំងឡាយណា នីដែលឮនចូលរួម ឬឮនលែងដោយចេញមុខក្នុងការបះបោរ ចលាចលប្រឆាំងនឹងរដ្ឋាភិបាល ។

២-ជនទាំងឡាយណា នីដែលរួបរួមគ្នាក្បត់ ឬ ប៉ុនប៉ងផ្តួលរដ្ឋប្រហារ ប្រឆាំងនឹងរដ្ឋាភិបាល ។

៣-យោធាទាំងឡាយនៃកងយោធពលខេមរជាតិ នីងជាទូទៅ ជនទាំងឡាយណា នីដែលរដ្ឋាភិបាលឮនប្រគល់អាវុធឱ្យ ដើម្បីការពារជាតិ ឬ រក្សាសេចក្តីសុខសាន្តក្នុងប្រទេស ហើយរត់ចោលកង ឬ ពួករបស់ខ្លួនព្រមទាំងយកអាវុធទៅដែង ដើម្បីទៅចូលនឹងសត្រូវ ។ ត្រូវដាក់ទោសដូចគ្នា ទូទៅយោធា នីងជនដូចមានឋានៈទាំងនេះ នីដែលឮនទីងនុះប្រឆាំងដោយកម្លាំង ឬ អាវុធនីងបទបញ្ជា ។

ត្រូវផ្តន្ទាទោសដូចគ្នា ចំពោះជនណាដែលឃុបឃិតញុះញង់ឱ្យជនខាងលើប្រព្រឹត្ត
ទត់ចោលកង ឬ ពួកទាហានខ្លួនទៅចូលរួមនឹងសត្រូវ ។

៤-ជនទាំងឡាយណាដែលឃុបឃិតផ្តល់គ្រឿងសាស្ត្រាវុធ ទីឯ គ្រោងទីលេនឱ្យសត្រូវ
ឬ អ្នកសមគំនិត ។

៥-ជនទាំងឡាយណា ដែលប្រដាប់ដោយអាវុធទៅប្តូរទ្រព្យជាកម្មសិទ្ធិសាធារណៈ
ឬ ទាហានជនដោយខុសច្បាប់ ដោយចុច្ចរិត នឹង ដោយប្រើកម្លាំងយកវត្ថុទាំងឡាយ ដែលមិន
មែនជាទាហានខ្លួន ។

៦-ជនទាំងឡាយណាដែលបង្កបង្កើត អគ្គីភ័យ ឬ អំពើនឹទ្រុតប៉ាង ខាងការផ្ញើ
ឱ្យទិនាសដល់សំណង់អាគារ ជាសម្បត្តិសាធារណៈ ឬ ជាកម្មសិទ្ធិឯកជនដោយមានបំណងខាងវិនច្ឆេទ
កម្ម ឬ ខាងលួចប្លន់ ។

៧-ជនទាំងឡាយណាដែលឃុបឃិតផ្ញើមនុស្សត្រាសលើក្បែង ឬមនុស្សចាស់ដោយមាន
បំណងខាងវិនច្ឆេទកម្មខាងយកតម្លៃលោះ ឬ ដោយមានបំណងជួយសត្រូវ នឹងអ្នកសមគំនិត ។

៨-ជនទាំងឡាយណាដែលឃុបឃិតប្រព្រឹត្តផ្ញើមនុស្សឃាតដោយចេតនា គិតទុកជាមុន
ដោយមានបំណងបំផ្លើនយោធ្ស ឬ មនោគមវិជ្ជា ឬ ដើមប្បីជួយកិច្ចការសត្រូវ ។

៩-ជនទាំងឡាយណា ដែលឃុបឃិតផ្ញើដោយចេតនា តាមពាក្យសម្ដី តាមលាយលក្ខ
អក្សរ ឬ តាមវិធានការណ៍ផ្សេងៗ ទៅតដោយគ្រឿងប្រដាប់ទើល ឬ សំរាប់ស្តាប់ ឬនិ
ការយោសនា វិទ្ធង្សនា ឬ ធ្វើឱ្យមានអវេតុភ័យ ក្នុងកងទ័ព ឬ កងកម្លាំងការពារ ។

ក្នុងករណីដែលមានស្ថានត្រាប្រឈើ ឧណ្ហកម្មដែលត្រូវផ្តន្ទា ពុំអាចបន្ធូយឱ្យតិចជាង
អតិបរមាណានៃទោសគុកបង្ខំឱ្យធ្វើការជាទម្ងន់មានកំណត់ " ២០ ឆ្នាំ " ទោសព្យួរមិនត្រូវយក
មកអនុវត្តជិញ្ញនទេឡើយ ។

មាត្រា ២- ទោសគុកបង្ខំឱ្យធ្វើការជាទម្ងន់អស់មួយជីវិត នឹងត្រូវផ្តន្ទាដល់ :

១-ជនណាដែលផ្តល់ ឬ ទទួលសំណូក ឬ ប្រព្រឹត្តវីតិក្រម ។

២-អ្នកបង្កើតឱ្យមានវិភវនិ តាមមធ្យោបាយណាក៏ដោយ ដែលឆ្លៀតឱ្កាស
ដើមប្បីធ្វើការទិបជាន់ផ្សេងៗ ឬ បណ្តាលឱ្យមានខូចប្រយោជនិដល់ជនរួមជាតិ ឬ ជនបរទេស
ឬ ដើមប្បីឱ្យខ្លួនមាន ឬង ខុសច្បាប់ដោយមកពីខូចប្រយោជនិអ្នកដទៃ ។

៣-យោធាទាំងឡាយនៃកងយោធពលខេមរជាតិ ឬ ជនទាំងឡាយណាដូចមាន
ចែងក្នុងមាត្រា១ កថាខ័ណ្ឌទី៣ ហើយដែលទត់ចោលកង ឬ ពួកខ្លួន ដោយយកគ្រឿងសស្ត្រាវុធ
ទៅជាមួយផង ឬ គេចទត់នៅចំពោះមុខសត្រូវ ។

៤-ជនទាំងឡាយណាដែលញុះញង់យោធា ឬ ជនដូចមានចែងក្នុងមាត្រា ១
កថាខ័ណ្ឌទី៣ ឱ្យទត់ចោលការ ឬ ដែលឃុបឃិតផ្តល់សេប្បៀងអាហារ គ្រឿងអាវុធ ទីស្ថ ឬ

ទៅក្តុងផ្សេង ៗ ទៀតឱ្យពួកសត្រូវ ឬ អ្នកសមគំនិត ។

ក្នុងករណីដែលត្រូវប្រើស្ថានគ្រាក្រុមី ត្រូវអនុវត្តនូវទោសគុក បង្ខំឱ្យធ្វើការដាច់ខ្លួន មានកំណត់ពី ៥ ឆ្នាំ ទៅ ២០ ឆ្នាំ តែទោសត្រូវពន្យារមិនត្រូវយកមកអនុវត្តនូវឡើយ ។

មាត្រា ៣- ត្រូវផ្តន្ទាទោសគុកបង្ខំឱ្យធ្វើការដាច់ខ្លួនមានកំណត់ពី ៥ ឆ្នាំ ទៅ ២០ ឆ្នាំ :-

១-ជនទាំងឡាយណា ដែលស្តាប់សម្លេងវិទ្យុក្នុងបេះកាំង ហាណូយ ឬក្នុង ឬ របស់ពួកសត្រូវឯទៀតទោះបីមានការព្រមានពីអាជ្ញាធរក៏ដោយ ។

២-ជនទាំងឡាយណា ដែលផ្សាយដំណឹងមិនពិត ដើម្បីបំភ័យឥតសមហេតុសមផល ឬ ធ្វើឱ្យមានចលាចលដល់សាធារណជន ។

៣-ជនទាំងឡាយណា ដែលកាន់កាប់គ្រឿងសស្ត្រាវុធ ឬ គ្រាប់ទំលែងនៅតាមផ្លូវសាធារណៈ ឬ កន្លែងសាធារណៈដោយគ្មានច្បាប់អនុញ្ញាតត្រឹមត្រូវ ។

៤-យោធា ឬ ជនទាំងឡាយណា ដែលទទួលភារកិច្ចផ្តល់អាវុធឱ្យ ហើយកាន់កាប់អាវុធ និងគ្រាប់ទំលែងនោះក្រៅតំបន់ដែលកំណត់ឱ្យ ឬ វត្តមានរបស់ខ្លួន គ្មានលិខិតផ្លូវការត្រឹមត្រូវបញ្ជាក់ទេឡើយ ។

៥-យោធា ឬ ជនទាំងឡាយណា ដូចមានចែងក្នុងមាត្រា ១ កថាខ័ណ្ឌទី ៣ ដែលទត់ចោលកងទ័ពដោយគ្មានយំាយកគ្រឿងអាវុធ ឬ គ្រាប់ទំលែងទៅជាមួយ ។

ក្នុងករណីដែលត្រូវប្រើស្ថានគ្រាក្រុមី ត្រូវអនុវត្តនូវទោសគុកពី ១ ឆ្នាំ ទៅ ៥ ឆ្នាំ តែទោសពន្យារមិនត្រូវយកមកអនុវត្តនូវឡើយ ។

មាត្រា ៤- ក្នុងទយៈពេលនៃការប្រកាសឱ្យប្រើច្បាប់អាជ្ញាសឹកនេះ សាលាជំនុំសឹកសំរាប់កងទ័ព ត្រូវមានសមត្ថកិច្ចក្នុងការបង្កើតបទឧក្រិដ្ឋដូចទៀបទាប់ខាងលើនេះ ។

មាត្រា ៥- សាលក្រមនៃសាលាជំនុំសឹកសំរាប់កងទ័ព ពុំអាចបើកឱ្យប្តឹងឧទ្ធរណ៍ ឬ ប្តឹងសារទុក្ខឡើយ ។

ការឱ្យមនុស្សត្រូវទោសទៅក្រៅឃុំដាបណ្តោះអាសន្នក្តី លុះតែមានការយល់ព្រមពីស្នងការនគរបាល អមសាលាជំនុំសឹកនោះផង ។

បណ្តឹងទាស់ នឹង ពិការសុការបុនសក្រៅពីពីការស្តីពីការឱ្យនៅក្រៅឃុំដាបណ្តោះអាសន្នចេញ ត្រូវនឱ្យសាលាជំនុំសឹកសំរាប់កងទ័ពសំរេច ។

កំប៉ុន្តែអ្នកត្រូវទោសដល់ប្រហារជីវិតចង់ ដឹងមានសិទ្ធិដាក់ពាក្យសុំអនុគ្រោះទៅការិយាល័យក្រឡាបញ្ជីក្នុងកំឡុង ៣ ថ្ងៃគត់ គិតពីថ្ងៃដែលក្តទទួលដំណឹងពីសាលាក្រម

ស្លាម ។ បណ្តឹងសុំអនុគ្រោះ បណ្តាលឱ្យផ្លាកសេចក្តីសំរេចនៃសាលាក្រម ។

៣ កិច្ចសុំអនុគ្រោះ ត្រូវទៅដង្ហមន្ត្រីក្រសួងការពារជាតិ និង ក្រសួងយុត្តិធម៌ ពិនិត្យរួមគ្នា ដើម្បីបង្ហាញយោបល់តាមហេតុផលលើវិធានការគ្រាប្រញាប់ ។ តែយោបល់នេះ ពុំមែនជាការតម្រូវឱ្យប្រមុខរដ្ឋសំរេចតាមជាដាច់ខាតទេឡើយ ។ ប្រមុខរដ្ឋអាចយកទណ្ឌកម្មណាមួយទៅដូនគ្នា ទោសទិញកិច្ចនាមការគួរដល់កាល ។

មាត្រា ៦ - ច្បាប់នេះត្រូវប្រកាសឱ្យអនុវត្តភ្លាម គិតពីថ្ងៃទី ១ ខែមិថុនា គ.ស. ១៩៧០ ក្នុងពេលដែលប្រជាជាតិប្រកាសស្ថិតនៅក្នុងភ័យន្តរាយ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ៣០ ខែឧសភា គ.ស.១៩៧០
ហត្ថលេខា : ចេង_ចេង

ឃានដាក់ជូនសូមហត្ថលេខា
នៃប្រមុខរដ្ឋ
ដោយទង្ហមន្ត្រីក្រសួងការពារជាតិ
ហត្ថលេខា : លន់_លន់

ទទួលបញ្ជានៃប្រមុខរដ្ឋ
នាយករដ្ឋមន្ត្រី
ហត្ថលេខា : លន់_នល់

ឃានចម្លងដើម្បីចែក :
អគ្គលេខាធិការ នៃគណៈរដ្ឋមន្ត្រី
ហត្ថលេខា : អ៊ឹក_ស៊ិន

ការផ្ញើរដ្ឋធម្មនុញ្ញថ្មី

ជាដំបូងបង្អស់យើងសូមគោរពនិងសរសើរដល់ការខិតខំរបស់លោក អ៊ឹង មីង ដែលបានព្យាយាមទាំងពុះពារផងក្នុងការតែងសេចក្តីព្រាងរដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ យកមកដាក់ឱ្យគណៈកម្មការពិសេសពិនិត្យ ។ ឯត្រង់ខ្លឹមសារនិងអត្ថន័យ យើងពុំទាន់វិនិច្ឆ័យនៅលើចំណុចនេះទេ។ ឱកាសនេះយើងគ្រាន់តែបញ្ចេញយោបល់ចំពោះឈ្មោះដែលមានក្នុងមាតិការបស់រដ្ឋធម្មនុញ្ញរបស់យើង ។

រដ្ឋធម្មនុញ្ញជារបស់អ្នកណា ?

គឺជារបស់សាធារណរដ្ឋខ្មែរ របស់មហាជនខ្មែរ ។ ពាក្យថាសាធារណរដ្ឋខ្មែរមានន័យទូលំទូលាយណាស់សំរាប់អ្នកសាងជាតិ ។ គួរតែរដ្ឋធម្មនុញ្ញយើងយោលគន្លិតទៅតាមន័យនេះដោយមិនប្រសប់ តែកុំប្រទង្គិចពាក្យ " សាធារណរដ្ឋខ្មែរ " និងពាក្យ " សាធារណរដ្ឋកម្ពុជា " ដែលយើងពុំព្រមប្រើក្នុងការតាំងឈ្មោះនៃសាធារណរដ្ឋរបស់យើងនោះ ។

ពាក្យថាមហាជនខ្មែរ គឺជាពាក្យមានន័យទូលំទូលាយមួយទៀត ដែលអ្នកតែងរដ្ឋធម្មនុញ្ញ គប្បីចេះដឹងឈរដងព្រៃមាសង្គមសាស្ត្រខ្មែរ ឱ្យច្បាស់លាស់ជាមុន មិនមែនគ្រាន់ចេះតាមសៀវភៅឬតាមការពិនិត្យសើ ៗ គឺសន្មតថាឈរបញ្ហានេះច្បាស់នោះទេវ៉ើយ ។ ទៅវិញនេះ យើងនៅមានឱកាសទៀតក្បែកទៅថ្ងៃមុខទៀត

អ្នកណាផ្ញើរដ្ឋធម្មនុញ្ញ

តាមធម្មតា គោងមានសភារដ្ឋធម្មនុញ្ញមួយដែលនាស្ត្រទ្វេះឆ្នោតជ្រើសរើសសម្រាប់ឱ្យផ្ញើរដ្ឋធម្មនុញ្ញដូចនាឆ្នាំ ១៩៤៦ ក្នុងប្រទេសយើង ។ តែក្នុងពេលបដិវត្តន៍ផ្តាស់ប្តូរបបគ្រប់គ្រងភ្លាម ៗ ច្រើនតែគណៈបដិវត្តិនីតែងតាំងគណៈកម្មការព្រាងរដ្ឋធម្មនុញ្ញមួយ សម្រាប់យកឱ្យនាស្ត្រអនុម័តដោយប្រជាមតិ ឬយកឱ្យតំណាងរបស់នាស្ត្រគ្រប់ជាន់ថ្នាក់អនុម័ត ។ ដូចកាលទៀត គឺគេប្រគល់ភារៈផ្ញើរដ្ឋធម្មនុញ្ញឱ្យទៅរដ្ឋសភាដែលមានស្រាប់នោះដែរ (ដោយប្រែភេទឬមិនចាំច្បាប់ប្រែភេទរដ្ឋសភានោះឱ្យទៅជាសភារដ្ឋធម្មនុញ្ញ) ។

ចំពោះប្រទេសយើង ការចាប់ចេញដំណើរពីដំបូង ហាក់ដូចជាស្រួលដែរ ។ គណៈកម្មាធិការស្រាចស្រង់ជាតិឮនតែងតាំងគណៈកម្មាធិការមួយខាងផ្ញើរដ្ឋធម្មនុញ្ញ មានសមាជិកសុទ្ធសឹងជាឥស្សរជនចំណាប់ ។ ដូចជាលោក ឃុក ន៉ាស៊ី - ភួង តុន - អ៊ឹង មីង - ថាប់ ចាន់ ន៉ាយ ឈួត - ស្វាយ សូរ - ទួង បុត្តា ជាដើម ។ គណៈកម្មាធិការនេះត្រែងត្រាងអស់ពេលដាំយូរក្នុងទេវ៉ើងថា មិនដឹងជាយោលគន្លិតទៅតាមរបបសាធារណរដ្ឋប្រធានាធិបតីនិយម

ឬក៏ទៅតាមទបបសភានិយម ។ ដាសម្រេចទៅ គណៈកម្មាធិការនេះ ឥតឮនប្រសូតចេញនូវ សេចក្តីព្រាង នៃទង្គធម្មនុញ្ញសាធារណរដ្ឋបែបណាមួយសោះ ។ ទៀងនេះ មិនដឹងដាបណ្តាលមក អំពីការពុំឮនបញ្ជាក់បេសកកម្មក្នុងសេចក្តីបង្កាប់ការតាំងគណៈកម្មាធិការនេះ ពុំស្តាប់ការខ្លួនឯង ឬពុំបានទទួលខុសត្រូវចំពោះបេសកកម្មខ្លួននោះទេ ។ ចំណែកឯគណៈកម្មាធិការពិនិត្យការទិវត្តនិ នៃគនិតសាធារណរដ្ឋនិយមនោះវិញ តែឮនលើកយកទៀងផ្ញើរទង្គធម្មនុញ្ញមកចោទដាយឮនទាំង អន្លើាញ្ជាសមាជិកនៃគណៈកម្មាធិការផ្ញើរទង្គធម្មនុញ្ញមកបភ្លឺដឹកនាំសម័យប្រជុំនិមួយ ៗ ផង ។

ក្រោយមក លោក អ៊ឹង មឹង ឮនទៀងជាប្រធានទង្គសភាស្តីទី ក្រោយពីការ ប្រកាសសាធារណរដ្ឋខ្មែរ ។ លោកឮនលើកយកទៀងផ្ញើរទង្គធម្មនុញ្ញមកចោទក្នុងទង្គសភា ហើយ ឮនសម្រេចមម្រាងថា ទង្គសភាជាអ្នកផ្ញើរទង្គធម្មនុញ្ញសាធារណរដ្ឋខ្មែរ ហើយមម្រាងទៀត ឮន សម្រេចតែងតាំងគណៈកម្មការពិសេសមួយ សម្រាប់ព្រាងទង្គធម្មនុញ្ញ ដោយមានសមាជិកចូលំចូលាយ ដូចតទៅ :

-សមាជិកនៃគណៈកម្មការចម្បាប់ និង ទង្គធម្មនុញ្ញក្នុងទង្គសភា និងក្រៅទង្គសភា ។

-សមាជិកនៃគណៈកម្មការមហាផ្ទៃ ក្នុងទង្គសភានិងក្រៅទង្គសភា ។

-ឥស្សរជនជំនាញខាងចម្បាប់ឯទៀត ៣ ។

ក្រៅអំពីសមាជិកទង្គសភា មានសមាជិកនៃគណៈកម្មការផ្ញើរទង្គធម្មនុញ្ញ ទីលគណៈ កម្មាធិការទស្រាចស្រង់ជាតិ ឮនបង្កើតទៀងនោះជាដើម ។

គណៈកម្មការពិសេសនេះ មានរូបលោក អ៊ឹង មឹង ជាប្រធាន (ប្រចំហែលដោយ ស្ងៀប្រវត្តិ ពីព្រោះលោក អ៊ឹង មឹង មានឋានៈជាប្រធានគណៈកម្មការចម្បាប់និងទង្គធម្មនុញ្ញក្នុង ទង្គសភា) ។... រួចស្រាប់តែថ្ងៃទី ៥ ទិច្ឆិកានេះ មានការប្រជុំគណៈកម្មការពិសេសនេះថា ដើមឡើពិនិត្យសេចក្តីព្រាងទង្គធម្មនុញ្ញទីលជាស្នាដៃនៃលោក អ៊ឹង មឹង ។ តែទីប្រជុំឮនជជែក ទ័ទៀកញ្ជែកថា គួរកុំបន្ទាន់រួសរាន់ពេក ទុកពេលមួយខែឱ្យតំណាងនិស្សិត - បញ្ញវន្ត - និងសមា ជិកឯទៀត ៣ ពិនិត្យ ពិភាក្សាទៅតាមអង្គការរបស់គេទៀង ៣ ខ្លួនឮនរយៈមួយខែសិន ។

ការចាត់ការទីលឮនផ្ញើរួចមកហើយនេះ ឃើញថាពុំទាន់ឮនដឹតដល់ណែទៅ ទេឡើយទេ ថែមទាំងមានចំណុចខ្លះខុសអំពីគនិតសាធារណរដ្ឋនិយម ឬខុសពីលក្ខណៈប្រជាធិបតេយ្យថែម ទៀត ។

ផ្ញើរទង្គធម្មនុញ្ញដើមឬអី ? សំទាប់អ្នកណា ?

លោក អ៊ឹង មឹង ឮនខិតខំនិងពុះពារផ្តើមផ្ញើរសេចក្តីព្រាងនៃទង្គធម្មនុញ្ញ មុន

ការលះបង់ប្តេជ្ញាចិត្តតែងតាំងគណៈកម្មការពិសេសនៃទង្គិចសាសនាបង្កើតឆ្នាំ ។ ទៅពេលប្រជុំជាលើកដំបូងនៅថ្ងៃទី ៩ នោះ លោកអ៊ីជានយកសេចក្តីព្រាងនេះ មកដាក់ឱ្យគណៈកម្មការពិសេសពិនិត្យតែម្តង ។

ឥទ្ធិពលនេះគណៈកម្មការពិសេសជានលម្រេចថាយកឯកសារព្រាងទង្គិចសាសនាបង្កើតរបស់លោក អ៊ីង ម៉ីង ជាមូលដ្ឋានដើម្បីជជែកគ្នាតទៅ ។

១-ដំបូងបង្អស់ គួរសួរថា យើងធ្វើទង្គិចសាសនាបង្កើតឆ្នាំដើម្បីអ្វី? សំរាប់អ្នកណា? ។ ចំពោះសំណួរនេះ មានចម្លើយនៅក្នុងបុព្វកថានៃសេចក្តីព្រាងស្រាប់ ដែលស្តីថា "យើងប្រជាជនខ្មែរ ដើម្បីពង្រឹកកម្លាំងសាមគ្គីជាតិ ធានាអនុវត្តឯកភាព យុត្តិធម៌ សេចក្តីសុខស្ងប់ សុខុមាលភាពទូទៅ សំរាប់រួបរួយើងនិងមច្ចាជននៃយើង យើងតែងតាំងទង្គិចសាសនាបង្កើតបច្ចុប្បន្ននេះនៃប្រទេសកម្ពុជា" ។

តាមយើងឃើញ បុព្វកថានេះមិនទាន់លះបង់ប្រកបពេញលេញទៅតាមសេចក្តីព្រួយបារម្ភរបស់មហាជនខ្មែរនៅទេ ហើយពុំត្រូវតាមស្ថានការណ៍ជាក់ស្តែងរបស់ប្រទេសជាតិផង ។ យើងឃើញថា ដែលយុទ្ធជន - មហាជនខ្មែរខំតស៊ូនឹងលត្រូវទិញបង្ហូរឈាមពោនទឹកដី គឺដើម្បីការពារអាយុជីវិតប្រជាជាតិខ្មែរឱ្យរស់នៅក្នុងលោកដ៏ថ្លៃវិសេស នឹងធ្វើឱ្យប្រជាជាតិខ្មែរឆ្ពោះស្គាល់សុខសន្តិភាពដ៏ធំទូលាយនៅក្នុងពិភពលោក ។ ហើយដែលយើងធាក់ប្រាសនិយមពុករលួយជាតិនឹងបក្ខពួកសត្តិ-ភូមិប្រតិកិរិយាពុករលួយ គឺយើងព្រួយបារម្ភរបបប្រតិបត្តិតែងសង្គមទៅតាមលទ្ធិប្រជាធិបតេយ្យ ឱ្យឆ្ពោះស្គាល់ស្តីពីកង្វះនិងធ្វើដំណាក់ប្រទេសឱ្យឆ្ពោះខ្ពស់ទុងទៅឯទៅឯ ។

នៅប្រទេសដទៃ មានសហគន្ធអាមេរិកជាដើម គេយកពាក្យពង្រឹកសាមគ្គីមកធ្វើជាត្រីមុខក្នុងបុព្វកថាទង្គិចសាសនាបង្កើតឆ្នាំ ដោយហេតុគេត្រូវការយកទង្គិចសាសនាបង្កើតឆ្នាំជាស្នូល ជាមូល-ដ្ឋានសំរាប់បង្រួបបង្រួមទង្គិចជាច្រើនប្លែក ៗ គ្នាឱ្យស្ថិតនៅស្រុះស្រួលក្នុងសហភាពរបស់គេ ។

ចំណែកប្រទេសយើងដែលមានឯកភាពស្រាប់ ៗ គ្រប់ទិស័យស្បែកឈាមជ័រ សាសនា ភាសា ទំនៀមទម្លាប់ ។ ល ។ ពុំចាំបាច់យកពាក្យសាមគ្គីធ្វើជាពន្លឺទង្គិចសាសនាបង្កើតនៅក្នុងបុព្វកថាទេ។ ពាក្យសាមគ្គីអាចជាគោលដៅសំរាប់នយោបាយទូទៅ ឬ សំរាប់នយោបាយនៅក្នុងទេសៈកាលៈតែប៉ុណ្ណោះ ។ ហើយម្យ៉ាងទៀតពាក្យសាមគ្គីជាតិមួយម៉ាត់នេះថើបប្រើខុសតង្ហុត ងាយទៅជាឥតន័យ ពីព្រោះថាពួកយើងអ្នកទៅមុខ ពុំអាចទៅសាមគ្គីជាមួយពួកទាញថយក្រោយទេឬ? ពួកយើងជាអ្នកភ្នាក់ងារពួកភ្លឺស្វាងឈើទៀងផ្លាយ ពុំអាចទៅសាមគ្គីជាមួយពួកបន្លំ ពួកចំកិន្តស្មារតី-ទាស្ត្រ ដើម្បីយកអំណាចមកក្តាបដូចរបបប្រតិបត្តិតែងជំនាន់សម្តេចសីហនុទេឬ? ។

យើងសូមស្នើថា ក្នុងបុព្វកថា គួរយើងយកគន្លឹះដូចតទៅជាពន្លឺវិញ ៖

-គំនាងរស្មីរភាពប្រជាជាតិ ។

-ពង្រីកនិងលំអសិទ្ធិប្រជាធិបតេយ្យ

-លើកជីវភាពប្រទេសជាតិឱ្យខ្ពស់រុងរឿង

-សាងសុខសន្តិភាពឱ្យមានសុខដុមរមនា រវាងនានាជាតិ

គន្លឹះប្រជាជាតិ ជាពន្លឺនាំឱ្យយើងស្គាល់ដោយជាក់លាក់ ក្នុងវដ្តធម្មនុញ្ញអំពីបញ្ហាឯករាជ្យ - អធិបតីភាព - បូរណភាពទឹកដី បញ្ហាយកភាសាខ្មែរជាភាសាផ្លូវការ បញ្ហាថែរក្សានិងលំអភោគសម្បត្តិធម្មជាតិខ្មែរ បញ្ហាពង្រីកវប្បធម៌ជាតិនិងព្រះពុទ្ធសាសនាឱ្យទីកល្អូតលាស់ បញ្ហាភាតព្វកិច្ចនៃការសិក្សា និងបញ្ហាសិទ្ធិកុមារា កុមារី ជាដើម ។

ត្រង់នេះ យើងសូមទុំពុកថា នៅក្នុងវដ្តធម្មនុញ្ញ ១៩៤៧ ព្រះពុទ្ធសាសនាគ្រាន់តែត្រូវទំពាធទទួលស្គាល់ជាសាសនារដ្ឋប៉ុណ្ណោះ ពីព្រោះពួកទាំងអាណានិគមនិយម និងស្តេចសីហនុ ទប់មិនឱ្យមានគន្លឹះទុំពុកបំទុងគំនាងលើសពីនេះ ដោយហេតុពួកវាមានការពិសោធន៍នឹងអាចារ្យល្ងា ក្រទ្បាហោមគង់ អាចារ្យនៅវត្តឧដុងតែជាបព្វជិត ហើយពួកវាកំភ័យខ្លាចតែការទុំពុកបំទុងសាសនារបស់យើងបណ្តាលឱ្យមានកងកម្ពុជបះបោរទៀត ។

គន្លឹះពង្រីកលទ្ធិប្រជាធិបតេយ្យ គន្លឹះលើកស្ទួយកំពស់ជីវភាពប្រទេសនិងគន្លឹះកសាងសុខសន្តិភាព វាស្មើគ្នាជាមួយនឹងបញ្ហាព្រះពុទ្ធសាសនារដ្ឋខ្មែរបស់យើង ជាគន្លឹះគំនាងរស្មី - ភាព យុត្តិធម៌ - សេចក្តីសុខស្ងប់ - សុខុមាលភាព តែងតែគ្រាន់តែជាព្រះពុទ្ធាមួយច្បាប់ជីវិតប៉ុណ្ណោះ ។

២ -បន្ទាប់មក យើងសួរបញ្ហាក់ឱ្យទិតតែចង្អាស់ទៅទៀតថា តើធ្វើវដ្តធម្មនុញ្ញសំរាប់អ្នកណា ? ។ យើងឆ្លើយខ្លួនឯងថា សំរាប់ខ្មែរ សំរាប់មហាជនខ្មែរ ។

បើថាធ្វើវដ្តធម្មនុញ្ញសំរាប់ខ្មែរ យើងមិនគប្បីបញ្ហាក់ក្នុងវដ្តធម្មនុញ្ញ អំពីឱ្យសិទ្ធិជ្រកកោនដល់បរទេសភៀសខ្លួនដោយរើឯងនោះទេ ។ ព្រោះខ្មែរឯងមិនត្រូវមានឬមួនយៀកក្នុងរាជធ្លីធ្វើជាភៀសខ្លួនមក យកដីខ្មែរអស់ទៅ ។ ចង្អាប់ជ្រកកោន មានន័យក្នុងវដ្តធម្មនុញ្ញខ្មែរស្រាប់ ពួកវាគ្រាន់តែបន្តមមធ្យោបាយព្រាក់ឱ្យក្រាស់ក្រែលបន្តិចទៅ មិនយូរប៉ុន្មានចំនួនអាឯកដនចិន យួន នឹងក្លាយទៅជាបញ្ហាដោះស្រាយលែងរួចតែម្តង ។

មួយទៀត គួរយើងកុំភ្លេចថា មិនយូរប៉ុន្មាន យើងត្រូវតែមានជោគជ័យលើយៀកក្នុង - យួនខាងជើង ។ ពួកវាមួយភាគច្រើន ឬ តិច មុខតែទម្លាក់អាវុធ ហើយសុំរស់នៅជ្រកកោននៅលើដីយើងជាពុំខាន ដង្វិតស្រុកវាត្រូវគ្រាប់បែកគ្រាំគ្រាជាទម្ងន់នេះ

ម្យ៉ាង ហើយម្យ៉ាងទៀតវាថារបបត្រួតត្រាលើស្រុកវា ផ្ញើខ្យល់ពិភាក្សាសង្គមនៅណាស់ ។ តើយើងគិតយ៉ាងណា ចំពោះមតិអន្តរជាតិ បើទង្គិចមូលដ្ឋានយើងស្តីចឹងស៊ាស់ ។ អំពីលទ្ធិបរទេសជ្រកកោនជាយ៉ាងណាយោបល់ដូចច្នេះ ?

បើថាផ្ញើទង្គិចមូលដ្ឋាន សំទាប់មហាជនខ្មែរ តើនរណាខ្លះទៅជាមហាជនខ្មែរ ? អ្នកផ្ញើការអ្វីខ្លះ ជាមហាជនខ្មែរ ? អ្នកមានគំនិតដូចម្តេចខ្លះ ជាមហាជនខ្មែរ ? ជនចំពូកណាខ្លះ ដែលយើងត្រូវទៅគៀងចេញ កុំឱ្យមានសិទ្ធច្បោះផ្លោត ឬឃោះថាបក្ខជន ?....។

បើទុយើងផ្ញើទង្គិចមូលដ្ឋានសំទាប់មហាជនខ្មែរ គួរយើងដឹងថាអ្នកណាខ្លះជាមហាជនខ្មែរ

តាមយើងឃើញ មហាជនខ្មែរគឺប្រមូលផ្តុំជនទាំងអស់ដែលមានឈាមជ័រជាខ្មែរ , មានប្រវត្តិសាស្ត្រទូទៅជាមួយសង្គមខ្មែរជាច្រើនលតវត្តមកហើយ , រស់នៅលើទឹកដីនៃដូនតាជនខ្លួនដែលជាខ្មែរ , មានភាសាខ្មែរ ជាមាតុភាសា , មានទំនៀមទំលៀមទម្លាប់ជាខ្មែរ , មានទិដ្ឋានណាញ្ញាណនិងឆន្ទចង់រស់នៅជាខ្មែរជានិច្ច ។ ការទង្គិចមូលដ្ឋានសាធារណរដ្ឋខ្មែរយើងត្រូវតែដៀសវាងប៉ះពាល់ទៅដល់កិច្ចការផ្ទៃក្នុងនៃប្រទេសជិតខាងទាំងអស់ ។ តែប៉ុន្តែយើងមិនត្រូវភ្លេចថាមានជនជាតិខ្មែរនៅក្រៅប្រទេសខ្មែរយ៉ាងក្រាស់ក្រែល, គួរតែយើងជឹកនាដល់គ្នាផង , គួរបើកបរិយាកាសសាធារណរដ្ឋខ្មែរឱ្យមានទំនងមកលើមាតុភូមិខ្មែរផង ដ្បិតគ្នាឮនខំតស៊ូស្វិតស្វាញបង្ហូរឈាមបង្ហូរទឹកភ្នែកជាច្រើនអង្វែងឆ្ងាំមកហើយ ដើម្បីប្រទ្ធាតែរស់ជាខ្មែរជានិច្ច ។

ឧទាហរណ៍ ដូចជាមានមាត្រាគិតពីលក្ខន្តិក:ពិសេស សម្រាប់ជនជាតិខ្មែរពីបរទេសមកឱ្យឮនទៅជាពលរដ្ឋមានសិទ្ធិចេញលេញជាដើម ។

បើយើងក្រទៅក្រមើលសេចក្តីព្រាងរបស់លោក អ៊ឹង ម៉ឹង មាត្រាទី ៧៥ ស្តីអំពីប្រធានាធិបតីសាធារណរដ្ឋ យើងឃើញថា :

"ជនដែលឈរឈ្មោះជាបេក្ខជនប្រធានាធិបតីសាធារណរដ្ឋ គឺពលរដ្ឋប្រុស ឬ ស្រី ទាំងឡាយណា កើតនៅប្រទេសកម្ពុជា , ប្រកបនូវសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយមានអាយុ ៤០ ឆ្នាំយ៉ាងតិច ហើយឮនរស់នៅក្នុងប្រទេសកម្ពុជាឮនរយៈ ១៥ ឆ្នាំ រាប់មកដល់ពេលច្បោះផ្លោត" ។

យើងឃើញថាកម្រិតត្រង់លក្ខណៈពលរដ្ឋ-អាយុ និង រយៈពេលរស់នៅក្នុងប្រទេសកម្ពុជា គឺជាការសមរម្យទេ តែនៅខ្វះត្រង់ចំណុចជនចូលជាតិខ្មែរទៀតនេះម្យ៉ាង ហើយបែរជាលើសត្រង់ចំណុចកំណើតក្នុងស្រុកខ្មែរទៅវិញ ។

បើតាមន័យមាត្រា ៧៤ នេះ គេត្រូវតែឆ្ងល់ចេញមិនឱ្យមានសិទ្ធិឈរឈ្មោះជាបេក្ខជនប្រធានាធិបតីឲ្យនូវបងប្អូនខ្មែរក្រោមទាំងអស់ ដែលឲ្យនៅតែនៅដែនកូដិនស៊ីន ឬនៅប្រទេសថៃទៀតដែរ តែឲ្យនមកវិស់នៅប្រទេសកម្ពុជាជាយូរយារមកហើយ ហើយទោះបីប្រជាជាតិខ្មែរទុកជាវែងជនខ្មែរកំដោយ ដូចជាលោក សឺន សាន ទ្រេឡឹង កាង សឹង ង៉ុក ថាញ់ ជាដើម ។

យើងឲ្យនដឹងច្បាស់ ហើយដែរថាកំថាវែងជនខ្មែរទាំងនេះ ពិតជាគ្មានបំងប្រឡាអ្វីមកឈរឈ្មោះជាបេក្ខជនប្រធានាធិបតីសាធារណរដ្ឋខ្មែរទេឡើយ ពីព្រោះគេពុំមែនជាសាមីខ្លួនពុះពារទម្លាក់សីហនុពីថ្ងៃទី ១៨ មីនា ១៩៧០ ហើយពុំតាំងខ្លួនថាជាអ្នកមេសាងសាធារណរដ្ឋខ្មែរទេឡើយ ។ តែចេះអៀនខ្មាស់ក្នុងការសំដែងនូវគុណដែលកាយពុំមាន ។ តែទោះបីយ៉ាងនេះក្តី យើងក៏ពុំត្រូវមានគំនិតទាំងវាខ្មែរពិតប្រាកដដូចគ្នា មិនឱ្យទេឡឹងដល់ថានេះកំពូលនៃកិត្តិយសជាតិរបស់ទាំងអស់គ្នានោះដែរ ដែលជាអំពើទិន្នេចកម្មដល់កិត្តិយស និងទឹកចិត្តរបស់មនុស្ស ។ ឃុទ្ធជនខ្មែរមកពីកម្ពុជាក្រោមឲ្យនបូជាជីវិតជាច្រើនក្នុងកិច្ចការពារទឹកដី ការពារសន្តិសុខឱ្យយើងឲ្យនសាងសាធារណរដ្ឋទេឡឹង ។ ខ្លះឲ្យនាំយកប្រពន្ធកូនមកសាងជីវភាពនៅមាតុប្រទេសខ្មែរ ។ កូនរបស់គ្នាដែលឲ្យនកើតនៅដែនកូដិនស៊ីនត្រូវតែមានសិទ្ធិបណ្តុះបណ្តាលខ្លួននៅក្នុងមាតុប្រទេស ទាំងដល់មានលទ្ធភាពអាចទេឡឹងដល់កំពូលនៃកិត្តិយសជាតិផង ។

មួយវាងទៀត បើតាមមាត្រាទី ៧៤ នៃរដ្ឋធម្មនុញ្ញឃើញថាជនបរទេសកើតនៅកម្ពុជាឲ្យនរស់នៅក្នុងប្រទេសនេះរយៈ ១៥ ឆ្នាំមកហើយ ជនបរទេសនេះអាចសុំចូលជាតិខ្មែរហើយអាចឈរឈ្មោះជាបេក្ខជនប្រធានាធិបតីឲ្យនពេញច្បាប់ ។ រួចបើប្រទេសកំណើតដើមនៃជននោះចេះបិនប្រសប់លួកដែមកប្រើមធ្យោបាយផ្សេង ៗ ក្នុងកលល្បិចឲ្យនផ្នាតជាដើម ប្រហែលប្រទេសយើងអាចនឹងមានប្រធានាធិបតីជាខ្មែរឈាមយួន ឬខ្មែរឈាមចិន-ថៃ ជប៉ុន-ឡាវ-លាវ ។ ល។ ក្នុងថ្ងៃណាមួយជាពុំខាន ។

ឥឡូវ យើងបំបែកន័យទៅតាមមុខរបរ វិជ្ជាជីវៈ ចំណេះវិជ្ជា ធនធានពូជអម្បូរទៅវិញ តើអ្នកណាខ្លះជាមហាជនខ្មែរ ? ។ បើតាមយើងឃើញថាទាំងអស់គ្នា កសិករ, កម្មករ, ពាណិជ្ជករ, ខ្សន្ធាហករ៉ូ អ្នកវដ្ឋការទាហាន-ស៊ីវិល, ព្រះសង្ឃ-ត្រហស្ថ អ្នកមាន-អ្នកក្រ, រហូតដល់អ្នកគ្មានការងារធ្វើ ឱ្យតែខ្មែរ គឺសុទ្ធតែសមាជិកនៃសង្គមមហាជនខ្មែរទាំងអស់ ។

បើតាមមាត្រាទី ៣១ នៃរដ្ឋធម្មនុញ្ញ ស្តីអំពីសិទ្ធិនឲ្យាឲ្យរបស់ពលរដ្ឋយើងឃើញថាព្រះសង្ឃនិងទាហានក្នុងនីតិកម្ម ពុំមានសិទ្ធិឲ្យនផ្នាតទ្រើសទើសតំណាងឬឈរឈ្មោះជាតំណាងក្នុងតំណែងណាទេឡើយ ។

ហេតុអ្វីក៏ទាហានពុំមានសិទ្ធិដូចគេ ?

ក្នុងរបបសង្គមចាស់ ច្បាប់បញ្ញត្តិតាមទស្សនៈសេរីនិយម មួយរយភាគរយ ត្រើនហាមឃាត់មិនឱ្យទាហានឬភ្នាក់ងារនគរបាលធ្វើនយោបាយទេ ពីព្រោះគេយល់ឃើញថា នគរបាលមានកងទាហាន មានកងតម្រួតនិងក្រសួងនគរបាលត្រប់ចំពូក នគរនេះត្រូវមានការៈតែការពារសេរីភាពនិងសន្តិសុខឱ្យឯកជនត្រប់ ៣ រូប , ត្រូវតែនៅជាអាជ្ញាកណ្តាលទាំងគណៈបក្សនយោបាយនានាក្នុងស្រុក , មិនត្រូវចូលឬលំអៀងទៅគណៈបក្សណាជាដាច់ខាត ។ ដូច្នេះតាមន័យនេះទាហាន-ប៉ូលិសនិងអ្នកនគរបាលនគរ មិនត្រូវមានលទ្ធិបោះឆ្នោតឬឈរឈ្មោះឱ្យគេបោះឆ្នោតទេឬ ? តើឥឡូវនេះវិញ មានប្រទេសសេរីនិយមណាខ្លះក្នុងលោក ដែលនៅប្រកាន់របបសង្គមចាស់ ? ។ តាមយើងដឹង គេបានយកទស្សនៈលទ្ធិសេរីនិយមរបស់គេមកកសាងសង្គមថ្មីត្រប់ ៣ប្រទេស ហើយទាហានរបស់គេសុទ្ធតែមានសិទ្ធិនយោបាយក្នុងត្រប់ទីស័យដូចពលរដ្ឋគេឯទៀត ៣ ដែរ ។

ខ្មែរយើងសម័យខ្មែរទាំង និងសម័យអំណាចផ្តាច់ការសីហនុ ទាំង និង សីហនុ ខ្ទប់ទាហានមិនឱ្យធ្វើនយោបាយទេ ពីព្រោះគេខ្លាចទើបំនះពីការដិះដាន់របស់គេ ។

ឥឡូវយើងមកដល់សម័យសាធារណរដ្ឋសង្គមខ្មែរថ្មីហើយ តើយើងទុកទាហានគ្រាន់តែជាគ្រឿងប្រើប្រាស់ដូចសម័យមុន ឬ ?

បើមានខ្មាំងលត្រូវយើងឆាប់ ! យើងប្រើទាហានឱ្យទៅស្លាប់ ! បើជ្រើសទើសតំណែងនាស្ត្រកាន់កាប់ការនគរ យើងមិនឱ្យទាហាន មានសិទ្ធិបោះឆ្នោត ! ។ ធ្វើយ៉ាងនេះ ដូចជាហុចលេសឱ្យទាហានទើបំនះ ដូចសម័យសីហនុទៀតជាពុំខាន ដរាបណាគេពុំពេញចិត្តនិងអ្នកកាន់ការនគរណាមួយ ។ ប្រសិនបើគេបានបោះឆ្នោតផង ទោះបីខុសឬត្រូវ អាក្រក់ឬល្អយ៉ាងណាក៏គេអស់ចិត្តដែរ ។

ម្យ៉ាងទៀត យើងបានចាប់អារម្មណ៍លើសេចក្តីព្រាងនគរធម្មនុញ្ញ ត្រង់ចំណុច ៤ ប្រការខាងក្រោមនេះ ... ដែលមានន័យជាប់គ្នាជានគរដឹកតី :

-ពោលអំពីពន្ធដីកសាមគ្គីជាតិក្នុងបុព្វកថា ។

-ពុំបានធិប្បាយថាតំណែងនាស្ត្រគ្មានអំណាចការកាប់មុខតំណែងនគរការនគរឯង ។

-ពុំបានធិប្បាយថា នគរមន្ត្រីនិងនគរលេខាធិការ មុននិងចូលកាន់តំណែង តែងតែស៊ុំសេចក្តីទុកចិត្តនគរសភាសិន ។

បើយើងពិនិត្យមើលគន្លឹះ ទាំង ៤ យ៉ាងនេះ ឃើញថា ពុំត្រូវតាមគតិសាធារណរដ្ឋទេ ហើយពុំស្របនឹងលទ្ធិប្រជាធិបតេយ្យផង ។

មកដល់ឥទ្ធរនេះ បញ្ហាធ្វើរដ្ឋធម្មនុញ្ញថ្មីនេះ ក៏នៅមានការរអាក់រអួលនៅទៀតដែរ ពុំទាន់ច្បាស់ចេញជារូបរាងយ៉ាងណានៅទៀតដែរ ។ ឮថាតាមសេចក្តីផ្តើមនៃសន្និបាតប្រតិភូលមាគមអ្នកចេះដឹងត្រង់ក្រសួង សមាគមធនាគា បញ្ញវន្ត និង យុវជន នាថ្ងៃ ១៩ វិច្ឆិកា ១៩៧០ សម្រេចជាឯកច្ឆន្ទថា សុំឱ្យសភាទាំងពីរអនុញ្ញាតឱ្យរដ្ឋាភិបាលបង្កើតគណកម្មាធិការចម្រុះមួយ ដែលមានតំណាងសភាទាំងពីរនិងតំណាងអង្គការសមាគមខ្មែរត្រង់មជ្ឈដ្ឋានទាំងអស់ចូលរួមស្រង់មតិឱ្យបានច្បាស់លាស់ទូលំទូលាយយកមកទៀបចំនៅរដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរឱ្យស្របទៅនឹងចំណង់ការត្រូវការ ការដាក់ស្តែង តម្លៃខ្ពង់ខ្ពស់របស់ខ្មែរ និងជាខ្លឹមប្រយោជន៍នៃប្រជាជាតិខ្មែរ ។

កំណែនទូទៅ

នៅពេលសង្គ្រាមនេះ រដ្ឋាភិបាលស្រែាចស្រង់ដាតិច្ចនបង្កើតច្បាប់កំណែនទូទៅ តាមសេចក្តីប្រកាសនាយករដ្ឋមន្ត្រី លេខ ២៣៩៧-៧០ ចុះថ្ងៃទី ៧ វិច្ឆិកា ១៩៧០ ដោយបែងចែកផ្ទៃដី ទឹនសាធារណរដ្ឋខ្មែរទាំងមូលជា ក្រចឡាអុក ។

នៅក្នុងសេចក្តីប្រកាសនាយករដ្ឋមន្ត្រីនេះ យើងនឹងលើកយកប្រការទាំងបីមកចុះជាឡាយដូចតទៅ នេះ :-

ប្រការ១.- ខេមរជនគ្រប់រូបទាំងពីរភេទ ដែលមិនមែនជាទាហានអាយុពី ១៨ ទៅ ៦០ ឆ្នាំ ត្រូវដាក់កំណែន ដើម្បីបំរើក្នុងកិច្ចការពារប្រទេស ។

ប្រការ២.- មន្ត្រីរដ្ឋការទាំងឡាយដែលមិនចូលជាទាហាន ត្រូវចូលក្នុងអង្គការការពារដែលបង្កើតទេ្បីងដោយនាយរបស់ខ្លួន តាមថានានុក្រម ដោយមានការទាក់ទងជាមួយនិងអាជ្ញាធរទាហានមានសមត្ថកិច្ចប្រចាំកន្លែង ដែលមន្ត្រីរដ្ឋការទាំងឡាយនោះ តាំងលំនៅដ្ឋាន ។

មន្ត្រីរដ្ឋការទាំងឡាយនោះ ត្រូវចញ្ចូនក្នុងអង្គការការពារព្រមទាំងអាវុធផ្ទាល់ខ្លួន បើសិនជាខ្លួនមានអាវុធនោះ ។

នៅក្នុងទីក្រុង អាវុធរបស់មន្ត្រីរដ្ឋការទាំងនោះនឹងត្រូវទុកជារបស់អង្គការការពារទីកន្លែងនៃលំនៅដ្ឋានរបស់ខ្លួន ។

ប្រការ៣.- ចំពោះការទេ្បបដែនដីវិញ ប្រទេសទាំងមូលត្រូវបែងចែកដូចខាងក្រោមប្រយោជន៍ដើម្បីទេ្បបចំការពារខ្លួន :

១- ក្រុង	.....	ក្រ
-ភ្នំពេញ រដ្ឋធានី	.....	ក្រ
-កំពង់សោម	.....	ក្រកស
-បៃលិន	.....	ក្រ.១
-តិវីរមឃ	.....	ក្រ.២
២- ខេត្ត	.....	" ១ "

ចុះហេតុអ្វីក្នុងជាចាំច្បាប់បែងចែកជាក្រចឡាអុកដូច្នេះ ?

ការបែងចែកក្រចឡាអុក អាចនាំឱ្យខ្មែរស្គាល់ទឹកដីខ្មែរច្បាស់ ស្គាល់មនុស្ស

នៅក្នុងភូមិជាមួយគ្នា ស្គាល់បញ្ហានិងទុក្ខធុរៈគ្នា ទៅទិញ ទៅមកចេះស្រឡាញ់រាប់អានគ្នា ចេះប្តូរយោបល់និងចំណេះចេះដឹង ហើយតាមរយៈការទាក់ទងនេះ ម្នាក់ៗ អាចដុះឆ្អូនវិគ្គិតរួម គំនិតស្នេហាទឹកដី ស្នេហាភូមិស្រុក ហើយកំណើតចិត្តចង់ការពារទឹកដីនោះ ដោយរួមគ្នាជាកងស្ម័គ្រចិត្តណា ដើម្បីពិនិត្យឱ្យច្បាស់ដឹងដល់ឆ្ងៃសន្តិសុខក្នុងភូមិ មានការត្រួតពិនិត្យអ្នកចម្ងាយដែលចេញចូលក្នុងភូមិ ឬ រួបរួមគ្នារាល់ថ្ងៃសហគមន៍ ដោយជួយគ្នាទៅទិញ ទៅមកប្រៀបដូចជីវិតគ្រួសារដ៏ធំមួយ ។

ចុះក្រុមឬអ្នកមានអីខ្លះ ?

សាធារណៈរដ្ឋខ្មែរកើតសង្គ្រាម ដើម្បីឈ្នះសង្គ្រាម ខ្មែរត្រូវនាំគ្នាប្រយុទ្ធ ។ នឹងប្រយុទ្ធកើតទាល់តែខ្មែរផ្ទៀងសហការគ្នា ។

ដើម្បីអនុវត្តគោលការណ៍នេះ រដ្ឋាភិបាលបានបង្កើតអង្គការជាន់ខ្ពស់មួយក្នុងក្រុមឬអ្នក ហៅថា "សង្គ្រាម" ។ អង្គការ "សង្គ្រាម" មានអង្គការបន្តបន្ទាប់ទៀត ហៅថា "អនុសង្គ្រាម ប្រយុទ្ធនិងសហការ" ។ អង្គការក្នុងក្រុមឬអ្នកប្រចាំក្រុងភ្នំពេញ ហៅថា "អនុសង្គ្រាមទី១" ។ ក្រុងចែកជាសង្កាត់ សង្កាត់នីមួយៗ ហៅថា "ប្រយុទ្ធទី១" ។ ចែកសង្កាត់ជាក្រុមឬបន្ទាប់ទៀត ហៅថា "សហការទី១" ដែលយើងសន្មតខ្ញុំឈ្មោះជាឮទាំងថា "អ៊ីឡូត" (flot) ។ ចែកអ៊ីឡូតជាក្រុមឬទៀត ឮជា "អ៊ីឡូតរង" (sous-flot) ឬ "សហការទី១១" ។ ក្នុងអ៊ីឡូតរងនេះ ត្រូវទៀបងចែកជាក្រុមឬទៀត ឮជាក្រុមផ្ទះ ៥០ខ្នង ឬ "សហការ ១១១" ។ ចែកក្រុមផ្ទះ ៥០ខ្នងជាក្រុមតូចៗ ទៀត ឮជាក្រុមផ្ទះដប់ខ្នង ឬ "សហការទី ១១១១" ។

ក្រុមឬអ្នកនៃកំណែនទូទៅនិងគំនិតសហគមន៍

ការចែងចែកជាក្រុមតូចៗ គឺជាមធ្យោបាយមួយដ៏សំខាន់ ក្នុងការត្រួតពិនិត្យឱ្យឮនដិតដល់ឆ្ងៃសន្តិសុខនៃប្រទេស ។ ប៉ុន្តែក្រៅពីបញ្ហាសន្តិសុខ ក្រុមឬអ្នកនេះ អាចជាតម្រាយផ្លូវមួយដ៏ពិសេស ហើយចាំបាច់បំផុត ក្នុងការទៀបចំប្រជាពលរដ្ឋឱ្យរៀបជាសហគមន៍ ។ ព្រោះថា "ដំណាក់ការទី១ នៃសកម្មភាពសហគមន៍ គឺផ្ញើយ៉ាងណាឱ្យពលរដ្ឋរួបរួមគ្នាជាក្រុមសិន ។ កាលណាឮនជាក្រុមហើយ ទើបចាប់ផ្តើមអនុវត្តដំណាក់ការទី២ គឺការអប់រំសមាជិកធានក្រុមផ្ទះ ១០ខ្នង...៥០ខ្នង ព្រមទាំងភូនខ្នង ឱ្យស្គាល់ការណែនាំកិច្ចរបស់ខ្លួនម្នាក់ៗ ក្នុងក្របខ័ណ្ឌកំណែនទូទៅនិងក្នុងគោលគំនិតសហគមន៍ ។

នឹងស្រដីឱ្យខ្លីថា កាលណាប្រជាពលរដ្ឋរៀបជាក្រុម ជាសហគមន៍ ដោយមានទម

មានតែកាយហើយ ទើបអាចចាប់ផ្តើមពង្រីកនិងពង្រឹងវិស័យសេដ្ឋកិច្ច សង្គមកិច្ច ធ្វើឲ្យវប្បធម៌ តាមសហគមន៍នោះ ។

ដូច្នេះ នៃផែនការកំណែទម្រង់ទៅ ពិតជា ស្របទាំងស្រុងទៅនឹងគោលគំនិត នៃក្រសួងអភិវឌ្ឍន៍សហគមន៍ នៃដែលមានបំណងក្នុងឆ្នាំ ៧ គឺតែតែពីប្រយោជន៍ផ្ទាល់ខ្លួនខុសបែបបទ ដោយយកសុខតែឯង យកទ្រព្យខ្លួនតែឯង ឬយកទុក្ខគេមកផ្ញើសុខទុក្ខខ្លួន ។

ក្នុងការទេរ្យបចំក្រុងឬអ្នក តើមានការពិភាក្សាឃ្លាំ ឯណា ទីដែន ?

មានការពិភាក្សាខ្លះទីដែន ដោយអ្នកស្រុកពុំស្ងួរឈរប្រយោជន៍នៃផែនការនេះ ។ អ្នកខ្លះពុំមានគំនិតសហគមន៍ ។ អ្នកខ្លះបែបសោះអង្គើយចំឯងជាយល់ថា កិច្ចការត្រួតបែបឃ្លាំ ឯ ក្នុងការទេរ្យបចំការពារសន្តិសុខ ឬ ទេរ្យបចំឧទ្យាន ជាការផ្តាច់មុខរបស់អ្នកឧត្តមការ ។

អង្គការ "សង្គ្រោម" និងមានប្រសិទ្ធិភាព ថើប្រសិនជា អ្នកស្រុកយល់ច្បាស់ថា អង្គការនេះ ពិតជា មានប្រយោជន៍ចំពោះអ្នកស្រុក ពិតជា ចង់ការពារអ្នកស្រុកឲ្យចាកផុតពីទុក្ខភ័យត្រួតបែបឃ្លាំ ឯ និងជួយលើកជីវភាពអ្នកស្រុក ឲ្យឮឆ្ងាយល្បីល្បាញ ដូចឮឆ្ងាយ ទ្រូចមកហើយ ។

១- ការជំនុំជំរះនិងការផ្តន្ទាទោសសម្តេច សីហនុ

កាលពីព្រឹកថ្ងៃអាទិត្យទី ៥ កក្កដា ឆ្នាំ ១៩៧០ តុលាការសឹកសំរាប់កងទ័ព ឮឆ្ងល់ថ្នា ទោសសម្តេចសីហនុ ដោយប្រហារជីវិតបង់ មកពីបទល្មើសក្បត់ជាតិ ទោះបីជនជាប់ចោទនេះ មិនឮឆ្ងានមកចូល ញ ខ្លួននៅចំពោះមុខតុលាការក៏ដោយ ។

អតីតប្រមុខរដ្ឋដែលគេហួតឯងការកាលពីថ្ងៃទី ១៨ មីនា ១៩៧០ នោះ ឮឆ្ងានត្រូវគេដកឈ្មោះតិជា ខ្មែរទៅហើយ ។ ទ្រព្យសម្បត្តិទាំងអស់ត្រូវទិបអូស ។

សម្តេចសីហនុ ត្រូវឮឆ្ងានគេចោទថា ឮឆ្ងានប្រព្រឹត្តបទប្រទុស្សន្ត ឈ្លើយនឹងសេចក្តីសុខសាន្ត ទ្រៅប្រទេស ដោយមានពាក្យចោទទាំង ៩ ខ ដូចតទៅ :

១- អនុញ្ញាតឲ្យកងកម្លាំងយៀកកុង ឆ្លងខាងជើងមកតាំងទីលើដែនដីនៃប្រទេស កម្ពុជា ។

២- ឮ ញ ជំកងកម្លាំងយៀកកុង ឆ្លងខាងជើង និង ឮ ថ្មើតទ្រា ទៅឲ្យឈ្លា ឆ្លង ប្រទេសកម្ពុជា ។

៣_ ក្នុងឃុបឃិតជាមួយកងកម្លាំងយៀកកុង_ជួនខាងដើង និង ចាំថែតឡាវ ដោយ
ឱ្យពួកនេះឈ្លានពានយ៉ាងចេញមុខមកលើប្រទេសកម្ពុជា ។

៤_ ក្នុងជួយបើកដៃដល់ការឈ្លានពាន នៃកងកម្លាំងយៀកកុង_ជួនខាងដើង និង
ចាំថែតឡាវ ប្រឆាំងនឹងប្រទេសកម្ពុជា ។

៥_ ក្នុងផ្តល់ទ្រព្យសម្បត្តិ គ្រាប់ទំលែង សៀ្បៀងអាហារ ឱ្សថ និង សម្ភារៈ
ទៅឱ្យកងកម្លាំងយៀកកុង_ជួនខាងដើង ។

៦_ ញុះញង់ ឱ្យប្រជាជនចូលខាងសត្រូវ ។

៧_ ញុះញង់ទាហានខ្មែរ ឱ្យទៅបំទើក្នុងកងទ័ពសត្រូវ ។

៨_ ទំលោភច្បាប់ទន្លេធម្មនុញ្ញ ។

៩_ ផ្តើមិច្ចេទកម្ម សេដ្ឋកិច្ច និង ពាណិជ្ជកម្ម ។

២_ការជំនុំជំរះ និងការកាត់ទោសបក្ខពួកសម្តេច សីហនុ

កាលពីព្រឹកថ្ងៃទី ១៧ សីហា ១៩៧០ ចាប់តាំងពីម៉ោង ៨ ទៅ តុលាការសឹក
ក្រុងភ្នំពេញ ក្នុងបានចាប់បើកការកាត់សេចក្តី ជាចំណាត់បក្ខពួកសម្តេចសីហនុ ដែលត្រូវទោសពីបទក្បត់
ជាតិយូរមកហើយជាមួយមហាអំណាច ។

ជនជាប់ចោទដែលជាបក្ខពួកសម្តេចសីហនុ មានដូចតទៅ :_

១_ ខៀវ សុត	១២_ កែវ មាស
២_ ដៅ ហ៊ុំ	១៣_ ទៀង ម៉ាច
៣_ ចៅ សេង	១៤_ អាង គីមឃន
៤_ សាទិន ឆាក	១៥_ សៀន អាន
៥_ ចាន់ យូរ៉ាន់	១៦_ ហាក់ សៀង ឡាយនី
៦_ ជា សាន	១៧_ មាស សាទែត
៧_ ហួត សម្បត្តិ	១៨_ អ៊ឹង សេនណារ៉ាក់
៨_ ខៀម ស្ងួន	១៩_ ស៊ី អ៊ុន
៩_ គាត ឈន់	២០_ អ៊ឹង ម៉ាង
១០_ ជួន ប្រសិទ្ធ	២១_ សួង ស៊ីកៀវ
១១_ ជួន ម៉ី	២២_ ត្រឹង លាន

២៣_តូច ខាំ ដៀវ៉ឹន	២៧_សេត ប៉ែងហួន
២៤_ហេង ពេច	២៨_អ្នកស្រី សៀនអាន
២៥_សៀង ហួនឡុង	២៩_អ្នកស្រីសីហនុ ឆាមដើម ម៉ូនីក ស៊ីហ៊ុន
២៦_អែង ហា	៣០_នាង ច្រើម ៣ង ។

ឈ្មោះ ឡុង សំអុល មិនត្រូវទៅគេយកមកកាត់ទោសទេ ពីព្រោះក្រសួងការពារប្រទេសមិនមានហ្វូតដាសត្តិ ។ តុលាការចាំជំនុំនៅលើកក្រោយ ។

ឈ្មោះ ជី ប៊ី កំមិនត្រូវឲ្យនជាប់ចោទដែរ ព្រោះឈ្មោះនេះ ឲ្យនត្រូវទៅគេនាយការណ៍មក ដោយភ័ន្តច្រឡំ ។

លោកស្នងការនគរបាលឲ្យនថាឥឡូវលោក មាយ ផល្គន់ ដែលជាក្រុមប្រាបញ្ជាការយកថ្លែងបទចោទប្រកាន់ទៅលើដូនជាប់ចោទទាំង ៣០ នាក់ ដោយសំអាងជាពិសេសទៅលើភស្តុតាង និង ឯកសារផ្ទេរ ៧ មានលេខថ្លែងការណ៍តាមទិព្យបែកាំង និងព្រឹត្តិប័ត្រទីភ្នាក់ងារពត៌មានចិន ស៊ិន ហួរ និងទីភ្នាក់ងារពត៌មានឡាទាំង ព្រមទាំងសារពត៌មានបរទេស ដែលផ្សាយពីសកម្មភាពដូនទាំងនោះ មានការបង្កើតនគរបាលប្រទេស សកម្មភាពញុះញង់ប៉ុនប៉ងរំលាយរដ្ឋាភិបាលពេញច្បាប់ ។

ក្នុងនេះមានពួកនគរបាលខ្លះ ដែលឲ្យនឥតប្រុលសម្តែចសីហនុឲ្យនបញ្ជាះបញ្ជូលសហការីផ្ទាល់ខ្លួន និងបើកប្រាក់នគរបាលដែលនៅក្នុងស្តាន់ចូតយកទៅជាមួយផង ។

លោកខុកញ៉ា ម៉ែន គិមសាន ចាងហ្វាងតុលាការសឹក ឲ្យនបង្ហាញដល់អង្គប្រជុំនូវភស្តុតាងនិងឯកសារផ្ទេរ ៧ មានទាំងលិខិតជាលាយលក្ខណ៍អក្សរ ដែលដូនជាប់ចោទឲ្យនសរសេរបំបួលលួងលោមឲ្យសហការីផ្ទៃតាមខ្លួនព្រមទាំងនូវបទឥត និងអត្ថបទសារពត៌មានបរទេស ស្តីអំពីសកម្មភាពនៃដូនជាប់ចោទទាំងនេះ នៅក្រុងប៉ែកាំង និងនៅញ៉ីវយ៉ក ។

បន្ទាប់ពីឲ្យនថយចូលទៅពិភាក្សាអស់រយៈពេលជិតពីរម៉ោងមក តុលាការសឹកនិងប្តឹងសេចក្តីផ្ទើចោលការតាក់ដោយដាច់ណាត់ ៖

ក) ផ្ទើចោលប្រហារជីវិតបង់លើនូបដូនត្រូវទៅចោទ ឈ្មោះ ៖

_ម៉ែន ឆុត	_តាត ឈាវ
_ដោ៉ ប៊ូ	_ដួន ប្រសិទ្ធ
_ចៅ សេង	_ដួន ម៉ុំ
_សាទិន ឆាក	_កែវ មាស

-ចាន់ ឃួន់ ន
-ជា សាន
-ហួត សម្បត្តិ
-ខែម ស្ងួន
-អ៊ុង ម៉ាង ។
-អាំង តិមឃន
-សៀន អាន
-មាស សាទេវ័ត
-អ៊ុំទ សេណា ទាំ ក
-

ចាត់ខ្លួន ព្រមទាំងសម្រេចថា ត្រូវដកសញ្ជាតិខ្មែរ ពីជនត្រូវចោទទាំងអស់នេះ តទៅ ដោយមកពីបទកម្ចាត់ប្រល័យទាក់ទងនឹងមហាអំណាចបរទេស ។

ខ) ផ្ដើទោសដាក់គុកឈ្មោះ
-អ្នកស្រីសីហនុ នាម ដើមឃ្លីក អ៊ីហ្គ្រី
-នាង ថ្ងៃម ៣ង

ចាត់ខ្លួន បង្គំឱ្យផ្ដើការដាទម្ងន់អស់មួយជីវិត ពីបទកម្ចាត់ដោយប្រល័យទាក់ទងជាមួយមហាអំណាចបរទេស ព្រមទាំងសម្រេចថា ត្រូវដកសញ្ជាតិខ្មែរ ពីជនត្រូវចោទទាំងនេះផង តទៅ ។

គ) ផ្ដើទោសដាក់គុកឈ្មោះ
-គ្រិន លាន
-ចេង ចេច
-ទេវ៉ឹង ម៉ាច
-សិទ្ធ បេង់ឃួន
-ស្ងួច ទាំ ដេវ៉ឹន
-លី អុន
-ស្ងួង ស៊ីឃៀវ៉ឹន
-សៀង ឃួនឡុង
-ហាក់ សៀងឡាយនី
-អ្នកស្រី សៀន អាន ។

ចាត់ខ្លួន បង្គំឱ្យផ្ដើការដាទម្ងន់កំណត់ ២០ ឆ្នាំ ម្នាក់ ៗ ពីបទកម្ចាត់ដាតិដោយប្រល័យទាក់ទងជាមួយពួកមហាអំណាចបរទេស ។

ឃ) បង្គាប់ឱ្យទិបអូសដាប្រចាំជនីទន្ធការ នូវទបល់តាងនិងទបល់ទ្រព្យទាំងឡាយណាដាទបល់ដនត្រូវចោទទាំងអស់ ៣០ នាក់ខាងលើដែលមានដីការ ពីមន្ទីរស៊ើបសួរឱ្យកត់និងឃាត់ទុកនូចទៅ បើយ៉ាងណា ឬកំនៅមិនទាន់កត់និងឃាត់ទុកនៅទេឡើយក្ដី ។

ង) បង្គាប់ឱ្យលើកការទិបអូសលើរថយន្តលេខ ពី ២.៩៥៧៦ ទីដែលពីដើមដាទបល់ដនត្រូវចោទ ហួត សម្បត្តិ ចេញទីដែលមានវត្តមានគ្រប់គ្រាន់ថា ឈ្មោះ ហួត សម្បត្តិ ឮនផ្ដើលិខិតបុះបង្គត់លេខាលក់ឱ្យទៅអ្នកដទៃ មានឈ្មោះ ចេវ៉ា អុន ជាគ្រូពេទ្យនាយកនៅសៀម-

ទាប អង្គនៅក្រុង ជាម្ចាស់ទ្រព្យទីថ្លៃ ដើម្បីទុកឱ្យឈ្មោះនេះប្តឹងសុំផ្លាស់ប្តូរឈ្មោះទៅក្រសួងមានសមត្ថកិច្ចតាមច្បាប់ ។

៣_ តុលាការសើកវិនិច្ឆ័យកនលើនៃលោក សឺង ងុក ថាន់

នៅព្រឹកថ្ងៃទី ៤ កញ្ញា ១៩៧០ តុលាការសើកក្រុងភ្នំពេញ ឭនបើកសម័យជំនុំជំនះ នៅរឿងលោក ស៊ឺង ងុក ថាន់ ទីប្រឹក្សា នៃទីស្តីការនាយកនដ្ឋមន្ត្រី ដែលឭនត្រូវនៅជាប់ចោទកាលក្នុងជំនាន់របបសម្តេចសីហនុ ពីបទប្រទុស្តនាយនឹងសេចក្តីសុខសាន្តក្រៅនគរ ។

ក្រោយពីដកឃ្លាទៅពីក្រោះសម្ងាត់អស់ពេលជាងពីរទម៉ាងមក តុលាការក៏ឭនប្រកាសលទ្ធផលសម្រេចសេចក្តីដូចតទៅ :

១_ការប្តឹងទាស់របស់លោក សឺង ងុក ថាន់ ទុកជាត្រឹមត្រូវនៅតាមច្បាប់ ។

២_បដិសេធសាលក្រមតុលាការសើកលេខ ៣៦០ ចុះថ្ងៃ ២៧_៩_៦៩ ជាអសារបង់។

៣_តាមមាត្រា ១០៧ នៃក្រមតុលាការសើក លោក សឺង ងុក ថាន់ ត្រូវឭនរួចខ្លួនពីការចោទ ចាប់តាំងពីថ្ងៃនេះទៅ ។

៤_ តុលាការសើក ឭនកាត់ទោសលោក ភួង ម៉ាន ហ៊ាំង

នៅថ្ងៃទី ២ តុលា ១៩៧០ តុលាការសើក ឭនសម្រេចកាត់ទោសដាក់គុក ភួង ម៉ាន ហ៊ាំង អស់មួយជីវិត ដោយបង្ខំឱ្យធ្វើការជាទម្ងន់ តាមមាត្រា ១០៧ ក្រមតុលាការសើក ។

៥_ តុលាការសើក ឭនកាត់ទោសលោក តុម សាវ៉ាន ទាន់

លោក តុម សាវ៉ាន ទាន់ អតីតមេបញ្ជាការ តំបន់សើកទង់កំពត ដែលត្រូវនៅឭនតុលាការសើក នៃ យោធភូមិភាគទី៣ កាត់ទោសប្រហារជីវិត កាលពីដើមខែសីហា មុនត្រូវនៅទទួលការប្រហារជីវិតនៅក្រុងកំពត នៅថ្ងៃ ៩_៩_៧០ ។

៦_ នៅថ្ងៃ ២០ មេសា ១៩៧០ លោក ទ្រិញ ន៉ាញ អគ្គលេខាធិការ នៃគណៈកម្មការស្រោចស្រង់ជាតិ ឭនផ្ញើជាអធិបតីនៃពិធីដោះលែងអ្នកទោសនយោឭយចំនួន ៤៨៦ នាក់ជាប់ពីបទថ្នាំបំទើពួកកុម្មុយនិស្ត ឬ បំទើពួកខាងលោកសេរី ។

ក្នុងចំណោមអ្នកទោសនយោឭយនេះ មានខ្លះត្រូវនៅតុលាការសើកជំនាន់សម្តេចសីហនុកាត់ទោសប្រហារជីវិតផង ។

៧_ នដ្ឋា អិច្ចលស្រ្តោ ចស្រង់ជាតិ លើកលែងទោសដល់អ្នកទោសសៀម ១០៤នាក់

នៅព្រឹកថ្ងៃទី ៧ ខុសភា ទៀលម៉ោង ៨កន្លះ លោកទ្រិញ ទាំញ នដ្ឋមន្ត្រី ក្រសួងឃោសនាការ.. ដែលជាតំណាងនដ្ឋា អិច្ចលស្រ្តោ ចស្រង់ជាតិ ឲ្យនអញ្ជើញទៅក្រុងខេមរៈភូមិន្ទ (ខេត្តកោះកុង) ដើម្បីថ្លែងជាអធិបតី ក្នុងពិធីដោះអ្នកទោសសៀមចំនួន ១០៤នាក់ ដែលជាប់ឃុំឃាំងនៅទីនោះពីបទលួចឆ្លងដែន និងលួចនេសាទត្រី ក្នុងព្រំដែនសមុទ្រប្រទេសកម្ពុជា។

៨_ តុលាការសឹក ឲ្យនកាត់ទោសលោក ចេង សាយ៉ុិន

ចាប់ពីថ្ងៃចន្ទទី ១៤ ធ្នូ ១៩៧០ តុលាការសឹក នៃយោធភូមិភាគទី ៦ ឲ្យនបើកសម័យជំនុំជំរះកាត់ទោសនាយទាហាន ៤ រូបមកពីក្រចេះ។

អ្នកជាប់ពិរុទ្ធទាំង ៤ នាក់ គឺ :

សឹក្តី៥ ចេងសាយ៉ុិន

សឹក្តី២ ទែកទ ម៉ឹងក្រាត

សឹក្តី៣ សេង អេរ៉ឹង

និងព្រឹទ្ធាចារ្យទី១ ឡាក់ ឡាំ

បន្ទាប់មក តុលាការសឹក ឲ្យនកាត់ទោសប្រហារជីវិតតែម្នាក់ ចេង សាយ៉ុិន ទេ។

ប្រាសាទរង្គៀតត្រូវទទួលការគំរាមកំបែង

ជា លើកទី១ ក្នុងទំព័រទេសចរណ៍សិល្បៈ ស្ថាបត្យកម្ម បច្ចុប្បន្នកាលនេះ វត្តជា កេរ្តិ៍ដំណែលសិល្បៈដែលធ្លាប់មាន ឈ្មោះល្បីល្បាញក្នុងចំណោមវត្តជាកេរ្តិ៍ដំណែលនានា សំខាន់មនុស្សជាតិទូទៅ ផងដែរនេះ ត្រូវទទួលការគំរាមកំហែងពីពួកសត្រូវការចោទ ឲ្យដួលរលំ ។

ប្រាសាទអង្គរដ៏ល្បីល្បាញសុសសាយនេះហើយ ជានិមិត្តរូបនៃមហាអំណាចខ្មែរនៅគង់វង្សថិតថេរមកហើយ ពុំ ជាតំបន់ស្រុកទេសនៃអ្នកប្រាជ្ញគ្រប់សញ្ជាតិ និងគ្រប់មណ្ឌលនៃបព្វជិតទេ ។

ទោះជាយ៉ាងនេះ ប្រាសាទអស់ទាំងនោះ ត្រូវទទួលរងនៅក្នុងមហន្តរាយ ។ ខណៈលោកទាំងមូលជាទីកន្លែងដែលគេសង់ប្រាសាទទាំងនោះ កំពុងតែទៅជាសមរភូមិ ត្រូវពួកទុច្ចរិត គ្មានសាសនា គ្មានបព្វជិត ទាយជាតាល់ថ្ងៃគ្នា ឈប់ឃើញមកលើប្រាសាទអស់នោះផង ។

ការដែលពួកខ្មែរថ្មីនេះ ឮនទាយប្រហារទៅលើពួកការពារសាសនាគ្រិស្ត កំទាមិនឮនផ្ទៃខ្លួនខ្លះតាមសំឡេងប្រាសាទណាមួយ ឬ កំពុងនដឹមានតម្លៃណាមួយដែរ ។ ប៉ុន្តែនៅពេលនេះ ពួកយើងកំពុងឮនខាងដើង ទាយយើងឥតត្រាប្រណី ដោយត្រៃអាវុធដ៏កំណាចអាចបំផ្លាញនិងកំទេចចំពីក្រុងទាំងមូលទៀតផង ។

នេះគឺជា សេចក្តីប្រមាថមើលងាយចំពោះវត្តជាទីសក្ការៈបូជា ដែលខ្មែរមិនអាចអត់អោនឱ្យបានឡើយ ព្រមទាំងជាការទទឹងលោភពេញទីទៅលើបព្ជាជាអន្តរៈជាតិ នៃអង្គការសហប្រជាជាតិ និង ទៅលើសិទ្ធិសញ្ជាអន្តរៈជាតិ នាថ្ងៃទី ១៤ ឧសភា ១៩៥៤ ។

អាស្រ័យដោយហេតុនេះ ការថែរក្សាប្រាសាទអង្គរក្នុងកាលៈទេសៈដ៏អាក្រក់នេះ មិនមែនត្រឹមតែការៈ អាជ្ញាធរនៃប្រទេសខ្មែរយើងទេ គឺជាការៈរបស់ពិភពលោកទាំងមូលដែរ ។

អង្គការសហប្រជាជាតិ និង UNESCO នឹងត្រូវពិនិត្យយ៉ាងម៉ត់ចត់ចោទបញ្ហាដែលគួរឱ្យព្រួយបារម្ភ ហើយចាត់វិធានការណ៍យ៉ាងប្រញាប់ដើម្បីបញ្ចប់នូវអំពើឈ្លានពានរបស់ពួកទមិឡនេះ ។

ទៅទៀងទាំងអស់នេះ គួរយើងខ្ញុំពុកទៀងទាញថា កាលពីពួកអ្នកដែលធ្លាប់ចាំងនៅក្នុងសង្គ្រាមសាកលលោកលើកទី២ ក៏មិនអាចសំទេចដល់ទីដៅបានដែរ ដូចជានៅតំបន់

ខ្លះខ្លះ ៗ មានទីក្រុងរ៉ូម (Rome) វ៉ឺនីស (Venise) ហ្វ្លរ៉ង (Forence) និង ប៉ារីស (Paris) ដែលជាតំបន់ពោរពេញទៅដោយសិល្បៈនៃបច្ចឹមប្រទេស ។

ហេតុដូច្នេះ ដើម្បីទប់ទល់នូវស្ថានការណ៍ នឹត្តរឱ្យប្រែប្រួលជាអន្តរបៀបនេះបើយ ទើបសភា ទាំងពីរនៃប្រទេសកម្ពុជា ដើរឯកន្តរផ្ញើរត្តិមួយផ្ញើទៅអគ្គសភានៃអង្គការសហប្រជាជាតិ ដែលមានសេចក្តីទាំងស្រុង ដូចតទៅ :

ញត្តិរបស់សភាទ្វេរ ផ្ញើទៅអគ្គសភានៃ
អង្គការសហប្រជាជាតិ

បកប្រែក្រៅផ្លូវការ ពី A.K.P. №7025 du 17/6/70 Page 1.

-ដោយពិនិត្យឃើញថា កងកម្លាំងយៀកកុង-យៀកណាមខាងជើង និងព្រះថេតទ្បាវ កំពុងវាយប្រហារមកលើប្រទេសកម្ពុជាគ្រប់ប្រកាលភ ។

-ដោយពិនិត្យឃើញថា ពួកឈ្លានពានទាំងនោះវាយប្រហារយ៉ាងខ្លាំងក្លា ដើម្បីយកផ្ទៃដីជាទីតាំង នូវចំណតអាកាសយាន និង ប្រាសាទអង្គរ នៅខេត្តសៀមរាប ដែលជាប្រាសាទកេរ្តិ៍ដំណែលថ្នែកវប្បធម៌សំខាន់មនុស្សជាតិទូទៅ ។

-ដោយពិនិត្យឃើញថា ការវាយប្រហារមកលើប្រទេសកម្ពុជា ហើយគំរាមកំហែងទៅលើប្រាសាទអង្គរ ជាការរំលោភយ៉ាងជាក់ស្តែង ទៅលើអង្គការសហប្រជាជាតិ និងទៅលើកិច្ចព្រមព្រៀងអន្តរជាតិ នៅទ្បាវ (La Haye) ឆ្នាំ ១៩៥៤ ស្តីអំពីការថែរក្សាសម្បត្តិវប្បធម៌ ក្នុងពេលមានអាវុធ កិច្ចព្រមព្រៀងដែលប្រទេសកម្ពុជាបានចុះសច្ចានុមតិ កាលពីថ្ងៃ ២៤ មេសា ១៩៦១ ។

-ដោយពិនិត្យ ឃើញថា ក្នុងបច្ចុប្បន្នកាលនេះ ប្រទេសកម្ពុជាមានការពិបាកយ៉ាងខ្លាំង ដើម្បីការពារកេរ្តិ៍ដំណែលវប្បធម៌ទាំងនោះដោយខ្លួនឯង និងទប់ទល់នឹងការឈ្លានពានរបស់យៀកកុង-ជួនខាងជើង និង ព្រះថេតទ្បាវ ។

សភាទ្វេរទាំងពីរ សូមអំពាវនាវយ៉ាងខ្ទេចខ្ទាំ ក្នុងពេលប្រជុំពេញអង្គ កាលពីថ្ងៃ ១៣ មិថុនា ១៩៧០ ចំពោះអគ្គសភានៃអង្គការសហប្រជាជាតិ ឱ្យទិនេរភ្លេចមិនធ្លាក់ចុះ និង ផ្ញើអន្តរាគមន៍ ដោយកងកម្លាំងនៃអង្គការសហប្រជាជាតិ ដើម្បីឱ្យប្រាសាទនានាក្នុងប្រទេសកម្ពុជា ជាពិសេសប្រាសាទអង្គរ ចាកផុតពីការបំផ្លិចបំផ្លាញរបស់ពួកឈ្លានពាន ។

ផ្ញើទៅភ្នំពេញ ថ្ងៃទី ១៣ មិថុនា ១៩៧០

ប្រធានព្រឹទ្ធសភា
ហត្ថលេខា : អ៊ឹង ស៊ីម

ប្រធានរដ្ឋសភា
ហត្ថលេខា : ឯក ជីអ៊ឹន

ក្រោយពីញត្តិទបស់សភាទ្វេនទាំងឲ្យនផ្ញើទៅអគ្គសភា នៃអង្គការសហប្រជាជាតិ
មក ក្រុមប្រឹក្សាប្រតិបត្តិ នៃ UNESCO ឲ្យនផ្ញើសេចក្តីប្តេជ្ញាជាឯកច្ឆន្ទមួយ មានសេចក្តីទាំង
ស្រុងដូចតទៅ :

(បកប្រែក្រៅផ្លូវការ)

សេចក្តីប្តេជ្ញាជាឯកច្ឆន្ទរបស់ក្រុមប្រឹក្សាប្រតិបត្តិ
នៃ UNESCO

ក្រុមប្រឹក្សាប្រតិបត្តិឲ្យនប្តេជ្ញាជាឯកច្ឆន្ទនៅពេលប្រជុំ នាថ្ងៃទី ១៨ មិថុនា
១៩៧០ ដែលមានលោក Etienne Dennery (France) មានលោក Prem
N Kirpal (Inde), មានលោក Qudrat Ullah shahab (Pakistan) et
S.Exc. M. Yukihisa Tumura (Japon).

ក្រុមប្រឹក្សាប្រតិបត្តិ

១_ ឲ្យនដឹងតាមសេចក្តីរាយការណ៍ទបស់លោកអគ្គនាយក (84 Ex/37)
ហើយដឹងឲ្យនឮសេចក្តីរាយការណ៍ទបស់លោកដោយមានការទទេ ស្តីអំពីការអនុវត្តធំ នៅប្រទេស
កម្ពុជា ឲ្យនសន្និសញ្ញាក្រុងឡា ហេ នៅមន្ទីថែទក្សាលម្បត្តិវប្បធម៌ក្នុងពេលមានជម្លោះគ្នា
ដោយប្រើកម្លាំងអាវុធ (conflit armé) ហើយទទួលដឹងឮសេចក្តីថ្លែងការណ៍ ដែលផ្ញើ
ទៀងនៅពេលនេះកញ្ចប់ដោះស្រាយ ពីសេចក្តីរាយការណ៍នោះ នៅក្រុមប្រឹក្សាប្រតិបត្តិ។

២_យកចិត្តទុកដាក់ទៅលើអង្គវត្ថុ និង ទ្រព្យសម្បត្តិវប្បធម៌ណាដែលទទួលរង មិនមែនចំ
ពោះ តែប្រទេសកម្ពុជាទេ គឺចំពោះមនុស្សជាតិទូទៅ ក្នុងក្របខ័ណ្ឌជា ទ្រព្យសម្បត្តិខាងផ្នែកសិល្បៈ
ខាងផ្នែកប្រវត្តិសាស្ត្រ និងខាងផ្នែកវិទ្យាសាស្ត្រ ។

៣_ទទួលដឹងឮថា ជាការពិតណាស់ណាស់ គ្រប់មនុស្សជាតិ ដែលត្រូវទទួលការពារ
ទ្រព្យសម្បត្តិទាំងនោះ ។

៤_សំដែងនូវសេចក្តីព្រួយបារម្ភយ៉ាងខ្លាំងចំពោះការប្រទុស្តរាយ ដែលបានកើត
ឡើងនេះ ដែលអាចបំផ្លិចបំផ្លាញដល់ទ្រព្យសម្បត្តិ ។

៥_ប្រតិបត្តិតាមសេចក្តីអំពាវនាវ ជានិច្ចាទិភទបស់លោកអគ្គលេខាធិការ
នៃ អង្គការសហប្រជាជាតិ កាលពីថ្ងៃ ៨ មិថុនា ។

៦_សេចក្តីអំពាវនាវដល់ប្រជាជនយ៉ាងខ្លួនឯងនូវការគាំទ្រ និងការពារ ប្រឆាំងនឹងការឈ្លានពានរបស់ខ្មែរ ដើម្បីខ្លឹមសារនៃការពារ និងការពារ ប្រឆាំងនឹងការឈ្លានពានរបស់ខ្មែរ មិនខ្លឹមខ្លួចខាតទេឬ ។

៧_អញ្ជើញលោកអគ្គនាយក ខ្លឹមទៅជួបចរចាផ្ទាល់ជាមួយអ្នកដែលបានផ្តើមសន្ធិសញ្ញានៅប្រុងទ្បាចេ ដើម្បីការពារមិនខ្លឹមានការបំផ្លេចបំផ្លាញ ការប្រមាថមើលងាយដល់ទីសក្ការៈបូជា និងមិនខ្លឹមានការលួចប្លន់ប្រឆាំងដែលជាកេរ្តិ៍ដំណែលរបស់ខ្មែរ ។

៨_សូមផ្តើសេចក្តីនាយការណ៍ក្នុងទេរឿងនេះនៅប្រុមប្រឹក្សាប្រតិបត្តិនាសម័យប្រជុំលើកក្រោយ ។

សមាសភាពនៃប្រុមប្រឹក្សាប្រតិបត្តិ គឺ :

ប្រធាន : អ៊ីតាលី

អនុប្រធាន: នែកូស្លូវ៉ាគី _ ឥណ្ឌា _ តង់ហ្សានី _ បេរ៉ូ

សមាជិក : ម៉ិចហ្ស៊ិក _ អ៊ីស្រាអែល _ ម៉ាលី _ ស្លឹស _ ប្រេហ្ស៊ិល _ ស៊ីលី _ នីហ្សេរីយ៉ា _ កូតឌីវ័រ _ អាហ្សង់ទីន _ ចក្រភាង _ សីង្ហបុរ _ អាហ្គង់ដាស្តង់ _ បេអ៊ីហ្ស _ ហុងគ្រី _ កូស្តារីកា _ កុងហ្គោ _ ប្រេសាវីល វ៉ូល្តាម អ៊ីយ៉ាន _ សេណេហ្គាល _ កាណាដា _ ហ្ស៊ុមប៊ី _ អារ៉ាប់ស្អូម _ លីបង់ ចក្រតីស្តាន _ អាល់ហ្សេរី _ ជប៉ុន និង សូវៀត ។

បន្ទាប់មកទៀត លោក អ៊ូ_ថាន់ អគ្គលេខាធិការ នៃអង្គការសហប្រជាជាតិ ចានផ្តើសេចក្តីអំពាវនាវមួយ ដូចតទៅ :

សេចក្តីអំពាវនាវរបស់លោក អ៊ូថាន់ ស្តីអំពីអង្គទ
(បកប្រែក្រៅផ្លូវការ)

"សង្គ្រាមវៀតណាមដែលរាលចូលដល់ប្រទេសកម្ពុជា ចានបណ្តាលឲ្យមនុស្សស្លាប់យ៉ាងច្រើន ព្រមទាំងមានការបំផ្លេចបំផ្លាញយ៉ាងសមេ្លម ។ សង្គ្រាមនេះឥឡូវត្រូវក្លាយទៅជាសង្គ្រាមឥណ្ឌូចិនទាំងមូល ។

តាមពតិមានថ្មី ៗ ដែលចានបញ្ជាក់ឲ្យដឹងថា អង្គរវត្តរបស់ប្រទេសកម្ពុជា ដែលជាទីសក្ការៈបូជា ដែលធ្លាប់មានឈ្មោះល្បីសុះសាយត្រូវបំផ្លិចបំផ្លាញ ឥឡូវនេះ ត្រូវចាំនួនទទួលការគំរាមកំហែងដូចគ្នានិងប្រាសាទនៅប្រុងទេវ ដែលជាទីសក្ការៈបូជា និងជាសម្បត្តិនៃបុព្វធម៌សាសនារបស់ប្រជាជនយើកណាមដែរ ។

ប្រាសាទអង្គរវត្តរបស់ខ្មែរ ត្រូវតែចេញឱ្យផុតពីការអន្តរាយ ។

ខ្ញុំផ្ញើសេចក្តីអំពាវនាវនេះ ដល់ស្ថាប័ជនទាំងសងខាង ឱ្យគោរពនិងទិះរក គ្រប់មធ្យោបាយ ដើម្បីការពារមហាគ្រិះនានាក្នុងតំបន់ទទួលការប្រយុទ្ធនៅវៀតណាម " ។

កត់សំគាល់. ក្នុងសេចក្តីថ្លែងការនេះ ពុំបានបែងចែងឱ្យច្បាស់លាស់ថាសាមីជនណាខ្លះ ដែលទាក់ទង ទៅនឹងសេចក្តីអំពាវនាវនេះ ។ ដូច្នេះសេចក្តីអំពាវនាវនេះ ប្រាកដតែតែចុះ ផ្សាយក្នុងសារព័តមានប៉ុណ្ណោះ មិនបានផ្ញើដូនចំពោះទៅទង្វាភិបាលណាទេឡើយ ។

បន្តបន្ទាប់មក មានសេចក្តីអំពាវនាវប្រហាក់ប្រហែលគ្នានេះ ដើម្បីការពារ អង្គរវត្តយើង ពីសំណាក់ទីនេះ

លោក Bernard Philippe Groslier, conservateur du site qui, avec les autres membres de l'école française d'Extrême-Orient de Siemreap, est resté sur place.

ក្រោយពីមានសន្និសិទសារព័តមាន នៅថ្ងៃទី ២៦ មិថុនា ១៩៧០ របស់លោក Vadime Alisseeff, ជាបេសកជនពិសេស នៃ UNESCO នៅប៉ារីស ស្តីអំពីទៀង ការពារប្រាសាទបុរាណយើង ។

បន្ទាប់មកទៀត ប្រទេសជប៉ុន ក៏មានការព្រួយបារម្ភចំពោះស្ថានភាពនៃ ប្រាសាទអង្គរយើងដែរ ។ ទើបលោកនាយករដ្ឋមន្ត្រីទី១ Eisaku Sato នៃប្រទេសជប៉ុន ប្រាប់ទុកឱ្យលោកនាយករដ្ឋមន្ត្រីក្រសួងការបរទេស គឺលោក Kiichi Aichi ពិនិត្យលទ្ធភាព នៃ ការការពារប្រាសាទអង្គរ ដែលជាកេរ្តិ៍ដំណែល សិល្បៈបុរាណខ្មែរនៅសតវត្សទី១០ និងទី ១២ បណ្តាលមកពីការរាតត្បាតនៃចំបាំង ។


តាមការសម្រេច នៃ អង្គការប្រជុំគណៈរដ្ឋមន្ត្រី នាថ្ងៃទី ១២ មិថុនា លោកទេសរដ្ឋមន្ត្រី Yasuhiro Nakasons ចាងហ្វាងទីភ្នាក់ងារទទាក់ទងការការពារ ប្រទេស ឈរឡើងថ្លែងថា ប្រទេសជប៉ុន ត្រូវតែបំពេញកិច្ចការខ្លះ ជាបន្ទាន់ចំពោះ ការ ការពារប្រាសាទអង្គរនេះ ។

(នេះជាដំណឹងផ្សាយចេញពី AFP du 12 Juin 1970)


ចំណែកខាងប្រទេសយ៉ាន់ទិញ គេឃើញមានឯកតុកម្មមួយនៅទីក្រុងទៀងចន្ទ្រ ផ្ញើទៅឯដើមប៊ីដែញចក្រពត្រដួនខាងជើង_ចៀកកុងចេញពីប្រៃសាទអង្គរ កាលពីថ្ងៃទី ៥ កក្កដា ១៩៧០ ។

មក៉ាងទៀត នៅប្រទេសកម្ពុជាយើងទិញ គណៈកម្មាធិការជាតិ ខាងកិច្ចការពារសម្បត្តិវប្បធម៌ក្នុងករណីមានសង្គ្រាម (COPROBIC) ឯកថ្លៃលេចក្តីជូនដំណឹងមួយមានសេចក្តីទាំងស្រុងដូចតទៅ :

"ដោយអនុលោមតាមអនុសញ្ញាក្រុងទ្បាហេ ឆ្នាំ ១៩៥៤ ស្តីអំពីកិច្ចការពារសម្បត្តិវប្បធម៌ ក្នុងករណីមានសង្គ្រាមនោះ សាធារណជនសូមជ្រាបថា ត្រីស្តានជាសំណង់ និងប្រៃសាទទាំងឡាយ ដែលជាសម្បត្តិវប្បធម៌ ត្រូវមានដាក់សញ្ញាសំគាល់ពណ៌ខៀវស ។ សញ្ញាមានគុណប្រយោជន៍ដល់កិច្ចការ ទប់ទល់នឹងអំពើបំផ្លិចបំផ្លាញ ការចូលទៅតាំងទីលំនៅ ឬ ការលួចប្លន់នៅពេលមានសង្គ្រាម" ។



គំនូរទី១



គំនូរទី២

គំនូរទី១ប្រៀបធៀប :

_បុគ្គលដែលទទួលភារៈមុខងារត្រួតពិនិត្យ ។

_បុគ្គលិកដែលចាត់ឱ្យគាំពារសម្បត្តិវប្បធម៌ ។

_អត្តសញ្ញាណប័ណ្ណ ដែលបានចែងនៅក្នុងបទបញ្ជានៃការប្រតិបត្តិ ។

គំនូរទី២ប្រៀបធៀប :

_សម្បត្តិវប្បធម៌ជាអសង្ហារិម ត្រូវការគាំពារពិសេស ។

_ការដឹកនាំសម្បត្តិវប្បធម៌ ។

_ទីជម្រកដែលមានត្រួតពិនិត្យ ។

ការកែប្រែគណៈរដ្ឋមន្ត្រី និងការបង្កើតអគ្គលេខាការដ្ឋានធានា

នៅដើមខែកក្កដា ១៩៧០ លោកឧត្តមសេនីយ លន់ នល់ នាយករដ្ឋាភិបាលព្រះបរមរាជាណាចក្រកម្ពុជា បានធ្វើសេចក្តីថ្លែងការណ៍មួយផ្សាយតាមវិទ្យុជាតិ បញ្ជាក់អំពីភាពចាំបាច់នៃការកែប្រែគណៈរដ្ឋមន្ត្រី នៃរដ្ឋាភិបាលព្រះបរមរាជាណាចក្រកម្ពុជានិងការបង្កើតអង្គការធំ ៣ ថ្មី ៣ ទៀត គឺអគ្គលេខាការដ្ឋានធានា ។ ការកែប្រែគណៈរដ្ឋមន្ត្រីឬការបង្កើតអគ្គលេខាការដ្ឋានក្តីគឺធ្វើទៅតាម ដើម្បីបែងចែកកិច្ចការខាងនយោបាយ និងបច្ចេកទេស ឱ្យមានការទទួលខុសត្រូវច្រើនគ្នា ហើយដើម្បីឱ្យកិច្ចការទាំងនោះបានដើរលឿនទៅមុខជាប្រក្រតីផង

តាមក្រឹត្យថ្ងៃទី ១ កក្កដា ១៩៧០ គណៈរដ្ឋមន្ត្រីរដ្ឋាភិបាលព្រះបរមរាជាណាចក្រកម្ពុជាត្រូវបានកែប្រែដូចតទៅ :

១-លោកឧត្តមសេនីយ លន់ នល់ នាយករដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងការពារជាតិ។

២-លោកឧត្តមសេនីយ ស.សិរិមតៈ ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកខាងទីស្តីការនាយករដ្ឋមន្ត្រី ។

៣-លោក យ៉ែម សំបូរ ទេសរដ្ឋមន្ត្រីទទួលបន្ទុកខាងយុត្តិធម៌ និងការទាក់ទងជាមួយសភា ។

៤-លោក ឃុប គិមអាង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សន្តិសុខ និង ធម្មការ ។

៥-លោក ព្រុំ ថុល រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម ។

៦-លោក ឆន សុខុម រដ្ឋមន្ត្រីក្រសួងអប់រំជាតិ ។

៧-លោក អ៊ឹង ត្រមុច រដ្ឋមន្ត្រីក្រសួងកសិកម្ម ។

៨-លោក ចៅ សេងអ៊ួន រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ និង មុខរបរ ។

៩-លោក ហ៊ូ ហុង រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម កាសុត្តដ៏ផ្តង់ និង ដឹកនាំ ។

១០-លោក ទិម ឆួន រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ។

១១-លោក គុន ទិច រដ្ឋមន្ត្រីក្រសួងការបរទេស ។

១២-លោក អ៊ឹង ក្រពុំផ្កា រដ្ឋមន្ត្រីក្រសួងសាធារណការ និងទេពកោសល្យជនបទ ។

១៣-លោកឧត្តមសេនិយត្រី កង កែង រដ្ឋមន្ត្រីក្រសួងសាធារណសុខាភិបាល ។

១៤-លោក កើក គីលិម រដ្ឋមន្ត្រីក្រសួងឃោសនាការ ។

១៥-លោក ហង់ ធុនហាក់ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍សហគមន៍ ។

១៦-លោក អ៊ុង ស៊ីម រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

ក

ក ក

តាមក្រឹត្យលេខ ៤៣០-៧០-បរ ចុះថ្ងៃទី ១៨ កក្កដា ១៩៧០ រដ្ឋាភិបាលស្រោចស្រង់ជាតិត្រូវមានអនុរដ្ឋលេខាធិការ ៣ រូប គឺ :

១-លោក ឌី ទូច អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃទទួលបន្ទុកខាងធម្មការ ។

២-លោក សាន់ាត ប៊ុំ អនុរដ្ឋលេខាធិការនៅទីស្តីការនាយករដ្ឋមន្ត្រី ។

៣-លោក ឈឹម ខែត្រ អនុរដ្ឋលេខាធិការទិនញ្ញវត្ថុ ។

ខ

ខ ខ

ក្រៅពីនេះលោកឧត្តមសេនិយ លន់ ឆល់ នាយកនៃនរដ្ឋាភិបាល ក៏ឧបជ្ញើតឲ្យមានទីប្រឹក្សានាយករដ្ឋមន្ត្រីចំនួន ៤ រូប គឺ :

១-លោក សឺង ង៉ុកថាន់

២-លោក ច្រឹង ឈឿន

៣-លោក ជូ ត្រៃវឿង

៤-លោក អូ ឈឿន ។

ចំណែកអង្គការទាំងមូល នៃនរដ្ឋាភិបាលវិញ ត្រូវមានទីប្រឹក្សានរដ្ឋាភិបាលចំនួន ៦ រូប គឺ :

១-លោក ផ្លែក ភឿន

២-លោក ឡុក ន៉ាស៊ី

៣-លោក ទ្រិញ្ញ ទាំញ្ញ

៤-លោក ទេវ្យី ទ្បាយអ៊ីន

៥-លោក មាស យ៉ង់

៦-លោក ទែកនៃ ស្រណោះ ។

យើងសូមបញ្ជាក់ថា ទីប្រឹក្សានាយកទន្ទមន្ត្រីមានឋានន្តរសក្តិ និងបុព្វសិទ្ធិស្មើនឹងឧបនាយកទន្ទមន្ត្រីនៃទន្ទាភិបាល ចំណែកឯទីប្រឹក្សាទន្ទាភិបាលទាំញ្ញ មានឋានន្តរសក្តិ និង បុព្វសិទ្ធិស្មើ នឹងទន្ទមន្ត្រី នៃទន្ទាភិបាល ។

តាមក្រឹត្យចង្ក្រាប់ លេខ៧ ចុះថ្ងៃទី ៦ កក្កដា ១៩៧០ ព្រះរាជទម្រេចបង្កើតឱ្យមានអគ្គស្នងការទន្ទានានាដូចតទៅ :

១ -	អគ្គស្នងការទន្ទាន	ខាងទីផែនការ
២ -	-ទ -	ខាងកីច្ចា
៣ -	-ទ -	អតីតយុទ្ធជន
៤ -	-ទ -	យុវជន
៥ -	-ទ -	អ្នកទទួលទ្រគ្រោះដោយចម្បាំង
៦ -	-ទ -	ដីលដំណាំស្រូវ
៧ -	-ទ -	ដំណាំកៅស៊ូ
៨ -	-ទ -	ចិញ្ចឹមសត្វ
៩ -	-ទ -	ប្រមាញ់និងវនសាទ
១០ -	-ទ -	ទេសចរណ៍
១១ -	-ទ -	ផលិតកម្មខ្សែថ
១២ -	-ទ -	ការស្រាវជ្រាវទៅក្រៅស្រុក
១៣ -	-ទ -	ការស្រាវជ្រាវខាងទីរ៉ែ
១៤ -	-ទ -	ការទែកទម្រង់និងការទន្យបចំទីផែនការនៃការអប់រំ ។
១៥ -	-ទ -	ទិច្ឆ និង ទូរទស្សន៍
១៦ -	-ទ -	ការកំណែនទូទៅ
១៧ -	-ទ -	កិច្ចការពុទ្ធសាសនា

តាមក្រឹត្យលេខ៤២៧-ប.ន. ចុះថ្ងៃទី ១៥ កក្កដា ១៩៧០ អគ្គស្នងការនានា ត្រូវស្ថិតនៅក្រោមអាណាព្យាបាល នៃក្រសួងទន្ទមន្ត្រីដូចតទៅ :

១ - ទីស្តីការនាយករដ្ឋមន្ត្រី

- អគ្គស្នងការដ្ឋានខាងថែនការ
- អគ្គស្នងការដ្ឋានខាងកីទ្ធា

២ - ទីស្តីការរដ្ឋមន្ត្រីក្រសួងការពារជាតិ

- អគ្គស្នងការដ្ឋានខាងអតីតយុទ្ធជន
- អគ្គស្នងការដ្ឋានខាងកំណែនទូរទៅ

៣ - ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម

- អគ្គស្នងការដ្ឋានខាងទេសចរណ៍
- អគ្គស្នងការដ្ឋានខាងការស្រាវជ្រាវទែ

៤ - ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំជាតិ

- អគ្គស្នងការដ្ឋានខាងយុវជន
- អគ្គស្នងការដ្ឋានខាងការកែទម្រង់និងការទៀបចំថែនការ នៃ
  ការអប់រំ

៥ - ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម

- អគ្គស្នងការដ្ឋានខាងការស្រាវជ្រាវកែប្រែសាស្ត្រ
- អគ្គស្នងការដ្ឋានខាងដំណាំស្រូវ
- អគ្គស្នងការដ្ឋានខាងដំណាំកៅស៊ូ
- អគ្គស្នងការដ្ឋានខាងការចិញ្ចឹមសត្វ
- អគ្គស្នងការដ្ឋានខាងប្រមាញ់និងនេសាទ

៦ - ទីស្តីការរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច

- អគ្គស្នងការដ្ឋានថែនជនរងគ្រោះ

៧ - ទីស្តីការរដ្ឋមន្ត្រីក្រសួងសាធារណសុខាភិបាល

- អគ្គស្នងការដ្ឋាន ខាងផលិតកម្មឱសថ

៨ - ទីស្តីការរដ្ឋមន្ត្រីក្រសួងឃោសនាការ

- អគ្គស្នងការដ្ឋានខាងវិទ្យុ និង ទូរទស្សន៍

៩ - ទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ធម្មការ

- អគ្គស្នងការដ្ឋានខាងលកម្មភាពពុទ្ធសាសនា ។

តាមក្រឹត្យលេខ ៤២៨-៧០-ប.ស. ចុះថ្ងៃទី ១៥ កក្កដា ១៩៧០ អស់លោកដូចមានឈ្មោះខាងក្រោមនេះ ត្រូវទទួលតែងតាំងឱ្យកាន់ដំណែងជាអគ្គលេខាធិការដូចតទៅ :

១-ទីផ្ទះធម្មការ.....លោក ថ្លែក ធាត
២-កីឡា.....លោក ប៉ូលីតែ ស៊ួន
៣-អតីតយុទ្ធជន.....លោក ប៊ុយ ម៉ាង
៤-យុវជន.....លោក ឈួក ទេង ម៉ា
៥-អ្នកទទួលគ្រោះក្នុងចម្បាំង.....លោក ចាន់ តឹម ជាង
៦-ផលដំណាំស្រូវ.....លោក សោ សុង
៧-ដំណាំកៅស៊ូ.....លោក កុល ទូច
៨-ចិញ្ចឹមសត្វ.....លោក ស្រី ង៉ុន
៩-ប្រមាញ់ និង នេសាទ.....លោក ចាន់ សុង ហុង
១០-ទេសចរណ៍.....លោកស្រី អ៊ឹង មឹង
១១-ផលិតកម្មខ្ចីសង.....ទេដ្ឋបណ្ឌិត ថាច់ ទន់
១២-ការស្រាវជ្រាវកែច្នៃសាស្ត្រ.លោក ហូ តុង លីប
១៣-ការស្រាវជ្រាវដី.....លោក ស៊ាន បេង៉ឆែ
១៤-ការកែទម្រង់និងទៀបចំផ្ទៃធម្ម
អប់រំ.....លោក ហូ តុង ហូ
១៥-វិទ្យុ និង ទូរទស្សន៍.....លោក អ៊ឹម សាវឿង
១៦-ការងារកំណែនទូទៅ.....លោកឧត្តមសេនីយ ពៅ លិមរ៉ា
១៧-សកម្មភាពពុទ្ធសាសនា.....លោក ណុប ឆុំ ។

ទង់ជាតិសាធារណរដ្ឋខ្មែរ

លក្ខណៈនៃទង់ជាតិ

-ពណ៌ : ខៀវទំនឹម ក្រហម ស

-រូបក្រឡាទ និង ផ្កាយបី

-ទ្រង់ទ្រាយ : ពណ៌ខៀវទំនឹម គឺ ៣ ភាគ ៤

-ពណ៌ក្រហមមួយ ភាគ បួន នៅជ្រុងខាងលើ និង ខាងឆ្វេង

-ក្រឡាទ ពណ៌ស នៅក្នុងពណ៌ក្រហម

-ផ្កាយ ៣ ពណ៌ស នៅទាយគ្នាចញ្ចឹតពីលើមកក្រោម ជ្រុងខាងស្តាំ ។

និយមន័យនៃទង់ជាតិ

-ពណ៌ខៀវ : តំណាងសីលធម៌ គឺសន្តានចិត្តសុចរិត យុត្តិធម៌ ជាពណ៌ត្រជាក់ ត្រជុំរបស់ប្រជាជាតិខ្មែរទូទៅ ។

-ពណ៌ក្រហម : តំណាងចិត្តអង់អាច ក្លាហាន មោះមុត ។

-ពណ៌ស : តំណាងសេចក្តីបរិសុទ្ធ សអាតល្អ គឺ សាសនា ។

-រូបក្រឡាទ : ជានិមិត្តរូបនៃអារ្យធម៌ វឌ្ឍនធម៌ សេចក្តីថ្កុំថ្កើង ធាសម័យដែលខ្មែរយើងចេះសាងក្រឡាទថ្មនោះ ។

-រូបផ្កាយ : ជាសញ្ញាវឌ្ឍនធម៌ និង នក្ខត្តឫក្ស ។

-ផ្កាយបី : មានន័យថា

-ជាតិ សាសនា សាធារណរដ្ឋទីកចំទើន

-រតនត្រ័យ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ

-អង្គការនីតិបញ្ញត្តិ នីតិប្រតិបត្តិ តុលាការ

ពិពណ៌នា អំពីទង់ជាតិសាធារណរដ្ឋខ្មែរ

ទង់ជាតិសាធារណរដ្ឋខ្មែរ នាឯចតុកោណកែង ដែលមានសមមាត្រ ២ ភាគ ៣ កំពស់ ២ ទល់នឹងបណ្តោយ ៣ ។

តួទង់ជាតិចាំងមួលមានពណ៌ខៀវ ស្មើកម្លែងតែ ១ ភាគ ៤ នៃផ្នែកខាងលើ ជ្រុងខាងឆ្វេង ដែលមានពណ៌ក្រហម ។ នៅក្នុងផ្នែកក្រហម មានទូបជ្រុងសាទអង្គុទវត្ត ។

ជ្រុងសាទមានកំពស់ ៣ ភាគ ៥ នៃកំពស់ផ្នែកពណ៌ក្រហម ។

ចុងជ្រុងសាទត្រូវនៅចម្ងាយ ១ ភាគ ៥ ពីទីបញ្ចប់ភាគ នៃពណ៌ក្រហម ។

ចុងជ្រុងសាទមានប្រវែងពីទង់នៃកំពស់ (៦ ភាគ ៥ នៃឯកតា) ហើយទូបត្រូវចារឹកក្នុងកន្លះទង្វង់ ។

ស្មូលនៃកំពូលកណ្តាលបណ្តោយចតុកោណក្រហម ហើយស្មូលនៃកំពូលសងខាងស្ថិតនៅត្រង់ ១ ភាគ ៤ នៃប៉ព្រ័ណ្តោយនេះ ចុងកំពូលត្រូវតំណែតាមគន្លងនៃទង្វង់ដើមូលចារឹកក្រៅ ។

នៅក្នុងផ្នែក ១ ភាគ ៤ នៃពណ៌ខៀវ ភាគលើមានផ្កាយបី ទៅត្រង់គ្នាតាមខ្នែងផក ដែលកាត់ចំពាក់កណ្តាលកំពស់នៃផ្នែក ១ ភាគ ៤ នៃភាគលើនេះ (គឺត្រង់ ៣ ភាគ ៤ នៃកំពស់ចាំងមួល) ។

វិដ្ឋៈមាត្រនៃទង្វង់ដែលចារឹកផ្កាយ ៥ ជ្រុង មានប្រវែង ១ ភាគ ៤ នៃឯកតា។

ផ្កាយកណ្តាលស្ថិតនៅចំកណ្តាលបណ្តោយនៃផ្នែក ១ ភាគ ៤ នៃពណ៌ខៀវភាគលើ ឯផ្កាយពីរទៀតស្ថិតនៅចម្ងាយ ១ ភាគ ៤ នៃឯកតាពីទីមខាង ។

ពិធីដែនទង់ជាតិ

ក្រាទាំលាក់ដែនទង់ជាតិ ត្រូវតែជាកងកម្លាំងប្រើប្រាក់ព្រហ្មចារី ១២ នាក់ អាយុពី ១២ ទៅ ១៥ ឆ្នាំ ដោយមានអ្នកប្រើ ពិមុ ស៊ុងទឡ្ហ ជាប្រធាន ។

មុនចាប់ផ្តើមដែនទង់ជាតិ មានទង្វើតាមប្លងស្លុងសុំជ័យ ឱ្យស្របតាមទំនៀមទំលាប់ប្ញទាណ ។ ចាប់ដែនទៅថ្ងៃ ៣_១០_៣០ ទម្លាត់ដល់ថ្ងៃ ៨_១០_៣០ វេលាម៉ោង ៥ ភ្លឺទើបរួចស្រេច ។ ទូបបន់ទង់ជាតិនេះយ៉ាងស្អាតតម្កល់លើពានមាស ។

ពិធីច្រៀកព្រុំ

ក្រើប្រាក់ព្រហ្មចារីទាំង ១២ ទូប ឮានលម្អិតសម្លាងខ្លួនច្រណាស្លៀកពាក់សំពត់ដាមួងចងក្បិន តាមពណ៌ប្រចាំថ្ងៃនិងអាវាស ដើមប្បីចូលការពិធីនេះ ។ នៅកណ្តាលទោងមានតម្កល់ព្រះពុទ្ធទូបលើទីអាសនៈដ៏ខ្ពស់មួយ ។ នៅចំព្រះរ៉ាក្បែរព្រះពុទ្ធទូបនេះមានតាំងឫស្សីច្រង់ច្រៀង ៥ ថ្នាក់ ១គូធំដាច់គេ ដែលទុំពីទ្ធដោយកំណាត់សំពត់ពណ៌ខៀវ ក្រហម ស ក្រៅពីនេះមានទន្លាប់ទន្លាផ្សេងទៀត ដូចជាឫស្សីច្រង់ច្រៀង ៧ ថ្នាក់ ៥ ថ្នាក់ ប្រាំមាម ទាំងអស់ប្លុងតែមួយគូ ពុស្លាជម ៨ សម្រាប់ជាបទិវាទ ព្រមទាំងតង្វាយផ្លែឈើ ៤ មុខ និងទៀនធូបផ្កាថ្មី ។

សូរទគាំងទី១ - ទេវីពាធីប្ងងសួងសុំជោគជ័យ ស្រីក្រមុំទាំង ១២ នាក់យកទៀនប្រេងរៀប ជាពីរជួរ ការដ្ឋាប់ផ្កាឈូកដើរចូលក្នុងទោង ទួចទុកឲ្យដាប់ផ្កាខ្សែស្រួល មុនដឹងថ្វាយបង្គំព្រះសង្ឃទាំង ៤អង្គ ដែលនិមន្តមកជាកិរិយា ដើម្បីបំពេញលក្ខណៈពុទ្ធមន្ត ។

សូរទគាំងទី២ - ព្រះសង្ឃចាប់ស្មាធ្យាយជយមង្គល នៅពេលដែលស្រីក្រមុំព្រហ្មចារីកំពុងអុជទៀនធូប ។

សូរទគាំងទី៣ - លោកអាចារ្យប្រមូលយកទៀន ធូប ទាំងនេះទៅដោតខ្សែប្រាន ស្រួល ។

សូរទគាំងទី៤ - ទាំងអស់គ្នាទៀបចំថ្វាយបង្គំព្រះសង្ឃ ដែលចាប់ស្មាធ្យាយ ជយមង្គល ។

សូរទគាំងទី៥ - ស្រីក្រមុំព្រហ្មចារីយកកំណាត់សំពត់ក្រហម ស ទៀន មកការ៉ដៃទេ ជានិមិត្តរូប ។ នៅពេលព្រះសង្ឃកំពុងស្មាធ្យាយជយមង្គល ស្រីក្រមុំព្រហ្មចារី ២ នាក់ លើកត្រដាងទង់ជាតិចំពោះព្រះសង្ឃ ។ លុះចប់កិច្ចសូត្រប្រសិទ្ធិពរជ័យ ទើបអាចារ្យយកទង់ជាតិពី ស្រីក្រមុំព្រហ្មចារីទៅតម្កល់ថ្វាយព្រះ ។ ឯស្រីក្រមុំព្រហ្មចារីទៀមច្បងឲ្យានសូត្រតាមថាតទៅនេះ

អនគ្គា ហមស្មិ លោកស្ស
សេដ្ឋា ហមស្មិ លោកស្ស
ជេដ្ឋា ហមស្មិ លោកស្ស
ឥត្ថី ទានិ បុនព្ភវំ នាតិ
អស្មិ ទានិ ចា ។

ពិធីនេះចាប់ផ្តើមនៅថ្ងៃ ៨ តុលា ១៩៧០ វេលាម៉ោង ១១ និង ៣០ នាទី រហូតដល់ម៉ោង ១៣ ទើបចប់ ។

2A
3/5 A
1/5A
1/5A
A
A
A
3A/2
1/4 A
1/4 A
1/4 A
A/2
A/2

ប្រវត្តិនៃភ្លេងជាតិ

នៅជំនាន់របបក្រសួងចាស់ គឺមុនថ្ងៃ ១៨ មីនា ១៩៧០ ភ្លេងជាតិយើងខ្ញុំ ការស្គាល់ គឺជា ភ្លេងជាតិបួយសម័យ សំនាង់ក្រោនតែស្រែកប្រែរួងដើម្បីអំពាវនាវទៅ វត្តសត្តិលិទ្ធិឱ្យមកជួយថែរក្សា ស្តេចដែនដីតែប៉ុណ្ណោះ ។ ដូច្នេះ ភ្លេងជាតិជំនាន់ចាស់ទាំងស្រុង ទាំងស្រុងពីគំនិតសាធារណរដ្ឋខ្មែរយើង ។

ដោយឃើញថា មានការប្រែរាំងគ្នាយ៉ាងនេះហើយ ទើបនៅសម័យសាធារណរដ្ឋយើងនេះមានការចាំបាច់នឹងប្តូរភ្លេងជាតិ ដែលមានគណៈកម្មការចម្រុះមួយតែងតាំងទៅដើម្បីរៀបចំភ្លេងជាតិថ្មីនេះ ។

ឯអ្នកនិពន្ធភ្លេងជាតិថ្មីនេះមានបីនាក់ គឺ : លោក ម៉ែ ប៊ុន
លោក កឹក មេង្គិត
និងលោក លី គីម អ៊ួង ។

ឯន័យនៃបទភ្លេងជាតិថ្មីនេះមានដូចតទៅ :

១-ក្នុងវគ្គខាងដើមនៃបទ "ទឹកដីខ្មែរ" មានបួនឃ្លា ។ បីឃ្លាខាងដើមជាឃ្លាសំនាង់ខ្ពើកនូវទំនៀមទំលៃនៃស្នាដៃបុព្វបុរសជំនាន់សម័យអង្គរវត្ត មានសម្លេងទន់ (nuance piano) ឱ្យស្របនឹងពាក្យថា :

"ជនជាតិខ្មែរ លឿពូកែមួយក្នុងលោក
មានជ័យជោគ សាងប្រវត្តិសាស្ត្រ
អារ្យធម៌ ខ្ពស់បវរ ជាតិសាសនា កេរ្តិ៍ដំណែល
ទុក លើភពផែនដី"

អ្នកនិពន្ធ ឲ្យបញ្ជាក់ទៀតថា ឃ្លាទី៤ គឺឃ្លាសំនាង់ភ្ជាប់ទៅនឹងឃ្លាទី១ នៃវគ្គទី២ ។ ឃ្លាទី៤ នេះមានកម្លាំងខ្លាំងពាក់កណ្តាលជាងឃ្លាឯទៀត (mi forte) ដើម្បីបង្ហាញឱ្យដឹងថា ត្រូវនៅតែស្រែកប្រែរួងខ្លាំងទៀតទេ ពុំលុះត្រាតែចូលដល់ទៅឃ្លាទី១ នៃវគ្គទី២ ។

២-ក្នុងវគ្គខាងចុងនេះ គឺបទ "សាមគ្គី" មានទាំងអស់ ៩ ឃ្លា ។ មានពីរឃ្លាសំនាង់បន្ថយសម្រែកមកត្រឹមពាក់កណ្តាលវិញ ។

ទឹងឃ្លាទី១-៣-៤-៦-៧-៨-៩ វិញ ជាឃ្លាសំនាង់ប្រែរួងគ្នាឱ្យខំដាស់

ស្នាទតីខ្លួនទេវ្តីង គឺនាំឱ្យមានសេចក្តីស្ងាហាប់ ដើម្បីតស៊ូប្រយុទ្ធយកជ័យឱ្យឮឆនទៅលើសត្រូវឈ្លានពាន ដូចជា :

* ក្រោកឈរទេវ្តីង (១) ក្រោកឈរទេវ្តីង (២)
ក្រោកឈរទេវ្តីង (៣) _ កសាងជាតិយើង តម្កើងខេមរា (៤)
ខ្មាំងពាធា (៥) ខ្មែរការពារ (៦)
ដែនបូរី (៧) តយុទ្ធប្រលែយ ត្តិទិយ្ធាន (៨)
យកជ័យឱ្យឮឆនខ្មែរសុខសាន្ត ទិវកាលទៅ (៩) * ។

ទំនុកច្រៀងនេះ ជាស្នាព្រះហស្តព្រះអាចារ្យ ប៊ាង_ខាត់ និងគណៈកម្មការ ។

ទឹងណោត (notes) ភ្លេង គឺត្រូវចេញពីសម្លេងហ្វា (ton de fa) បើយចប់នៅសម្លេង ស៊ី បេ_ម៉ូល (ton de si b) ។ ឮនន័យថាក្នុងចម្រៀងនេះ គេប្រើសម្លេង ស៊ី បេ ម៉ូល ជាមូលដ្ឋាន ។

តាមលំនាំសូរនៃសម្លេងទៅនឹងពាក្យ ក្នុងឃ្លាទី២ និងទី៥ យើញថា ជាសូរខ្លាំងពាក់កណ្តាលទីមន ។

ដូច្នេះ ន័យនៃភ្លេងជាតិនេះ គឺ សំទាប់ ជាស្នាទតីពលរដ្ឋខ្មែរជំនាន់សាធារណៈរដ្ឋ ឱ្យមានសេចក្តីក្លាហាន ស្ងាហាប់ទេវ្តីង ស្របតាមជំណើរបរទេស ដែលមានការដេរ្ងីនលេរ្ងីនពិតប្រាកដមែន ។ ក៏ប៉ុន្តែភ្លេងជាតិនេះ អាចញ៉ាំងឱ្យខ្មែរមានគំនិតជាបរទេសទៅវិញ ដែរ ដោយសារស្នាប់សម្លេងនៃបទភ្លេងជាតិនេះជាទាល់ថ្ងៃ ពីព្រោះសូរបទភ្លេងថ្ងៃនេះ គ្មានលក្ខណៈជាសូរទេរ្ងីងគ្នា (gamme) ជាលក្ខណៈខ្មែរបន្តិចសោះទេវ្តីយ ។ សូមឪ្យតែអ្នកនិពន្ធខ្លួនឯងកំទួលសារភាព ថាពិតដូច្នេះមែនហើយ ។

ម្យ៉ាងទេវ្តីត អ្នកនិពន្ធក៏ឮបញ្ជាក់ថា មានការលំបាកនឹងបញ្ចូលសម្លេងទៅនឹងសម្ភារៈភ្លេងផ្លុំ (instruments à vent) ពីព្រោះត្រូវប្រើសម្លេង :

១_សូប្រាណូ (soprano) សម្លេងឮៗ ច្រេ្រីន_ខ្លាំងជាងគេហើយចប្រាស់ផង ដែលសំទាប់ដឹកនាំសម្លេងឯទេវ្តីត ពុំ ។


២_អាល់តូ (Alto) ខ្លាំងជាងសូប្រាណូបន្តិច ដើម្បីជួយសោងសម្លេងបែបជារណបសម្លេងពីរ មួយធំមួយតូច លើក្រោម _ ដែលខ្មែរយើងហៅថា គូរ ៨ នោះ ។

៣_តេន័រ (ténor) មានសម្លេងធំជាងអាល់តូ ជារណបទី២ ដើម្បីលើកតម្លៃញ្ញនៃសម្លេងសូប្រាណូឱ្យរងំទេវ្តីង ។

ទោះជាអ្នកនិពន្ធខិតខំនិះទកយ៉ាងនេះទៅហើយក្តី កំរយើងសង្កេតឃើញថា បទភ្លេងជាតិថ្មីនេះ កំពុំទាន់ពេញចិត្តប្រជាពលរដ្ឋខ្លះផង ដោយសារបទភ្លេងជាតិនេះមានឧភាពជាភ្លេងសំខាប់ដើរទៅទិញនេះមក្យាំងទៅ ឯមក្យាំងទៅទៀត គេច្រៀនបន្ទោសថាបទភ្លេងជាតិនេះ គ្មានច្រៀងក្រាយ គ្មានលក្ខណជាតិបន្តិចសោះទេឬ ។

កំប៉ុន្តែ ទោះជាយ៉ាងណាកំដោយ យើងយល់ឃើញថា ការអ្វី ៗ កំដោយ តែបង្កើតចេញលើកទីមួយ មិនដែលទាន់ត្រូវចិត្តមនុស្សខ្លីឲ្យបានត្រចះគ្នាទេ ទាំតែងតែមានទាស់ចិត្តត្រង់នេះ ត្រង់នោះជាមិនខាន ។ ដូចេ្នះយើងនាំគ្នាប្រើប្រាស់បទភ្លេងជាតិថ្មីនេះសិនទៅ ក្រោះថាយើងខ្លីពេលតិចពេក ខ្លីពេកទៅអ្នកនិពន្ធ ខ្លីគ្នាតែងបទភ្លេងនេះ ។ យើងសង្ឃឹមថាទៅថ្ងៃក្រោយ យើងអាចយកភ្លេងជាតិនេះមកតែកែប្រែវិញ កំមិនជាការទាស់ខុសអ្វីដែរ ក្រោះថាការតាក់តែងបទនេះ ដោយប្រញាប់ប្រញាល់ពេក តម្រូវទៅតាមស្ថានការប្រទេសយើង ។

ជំនះណរិសាធារណរដ្ឋខ្មែរ



LA MARCHE DE LA REPUBLIQUE KHMERE

(Adaptation française en prose)

Les Khmers sont reconnus, de par le monde comme issus d'une Nation guerrière, remportant des victoires retentissantes.

Les monuments artistiques anciens en abondance sont bien les reflets d'une civilisation florissante de nos aïeux.

Levons-nous ! Levons-nous ! Levons-nous ! pour faire resplendir notre Nation, pour valoriser les Khmers.

Agressés, attaqués, nous ripostons pour défendre notre territoire sacré, pour annihiler les impies envahisseurs, quels qu'ils soient.

Une fois la victoire remportée, nous jouissons d'une paix éternelle.

សិលាចារឹកលើសសរទ្វារ

សេចក្តីពន្យល់អំពីទូបលម្អសួរបត្តីនៃសាធារណៈផ្ទះ

ទៅក្រុងខាងកើតនិងខាងលិច ត្រង់ចន្លោះច្រកតូចក្រោម និងភាគកណ្តាលនៃសសរ មានចារឹកខ្លះទៀត ពន្យល់ពីនាមនៃសាធារណៈផ្ទះខ្មែរ ចំនួន ៥ ម៉ាត់ គឺ : សេរីភាព _ សមភាព _ ភាតរភាព _ វិញ្ញូនភាព និង សុភមង្គល ។

ទៅកណ្តាលសសរ ត្រង់ផ្នែកក្រុងទាំង ៤ មានចារឹកខ្លះទៀតថា :

" សា ធា រ ណ រ ដ្ឋ ខ្មែ រ "

ទៅលើផ្នែកក្រុងខាងជើង និង ខាងក្រៅ ចុះក្រោមបន្តិចពីពាក់កណ្តាលនៃ សសរ មានចារឹកខ្លះទៀតកាលបរិច្ឆេទ នៃការបង្កើតសាធារណៈផ្ទះខ្មែរ គឺថ្ងៃទី ៩ ខែតុលា ឆ្នាំ ១៩៣០ ។

_ សសរសួគ្គ នេះជានិមិត្តរូបតំណាង " អង្គការ " នៃប្រជាជាតិខ្មែរទាំងមូល ត្រង្រង់ទៅដោយធាតុ ចាំមពីរទាំង ៣ គឺ : មហាជន _ កងទ័ព និង សាសនា ។ ធាតុចាំមពីរទាំង ៣ នេះសុទ្ធតែមានទូបរាងពងក្រពើនោះ គឺនៅកំណាត់ខាងក្រោមទូបរាងតំណាង "មហាជន" កំណាត់កណ្តាលទូបរាងតំណាង "កងទ័ព" ហើយនៅកំណាត់កំពូលទូបរាងតំណាង "សាសនា" ។

១_ ទូបរាងតំណាងមហាជន

ទូបរាងតំណាងមហាជន នៅទីផ្ទុកខាងក្រោមនៃសសរ វាចារជា ២ ផ្នាំង មានកំពស់ ៨៦ ស.ម. ក៏ដាក្រលមោល ទូបមនុស្សក្រុងក្រើ កំពុងបំពេញសកម្មភាពផ្សេងៗ បង្ហាញអំពីដំណើរភាពប្រចាំថ្ងៃទាំងយប់ ដូចជាកិច្ចការងារកម្ម ទេសាទ ការសំណង់ ។ ល ។.... ផ្នាំងនៃទូបរាងពងនេះត្រូវស្រមៃថាតាមលំនាំដើមទីផ្នាំងចម្លាក់ នៅមានជាងផ្នាំងទីបន្តិច ។ ត្រូវដាក់ឈ្មោះ គឺចក្រពើសម័យ គឺប្រជាជនដែលនេះបើយ ដែលត្រូវនៅ និងត្រូវផ្តើមពីកម្មវត្ថុនេះ ក៏ដូចជាក្នុងអតីតកាលនៅលើទឹកដីតែមួយ ដើមកំណើតរួមមួយ ជាតិភាព ។ ក៏ប៉ុន្តែមួយនេះ គឺកសាងទង្គិចមួយដែលមិនមែនជាកម្មវិធីទូបសម្បត្តិតែម្នាក់ គឺ កសាងប្រជាជាតិមួយ ដែលមិនមែនទៅក្រោមការចាត់ចែងដឹកនាំរបស់បុគ្គលតែម្នាក់នោះទេ ។ នៅក្នុងពេលបច្ចុប្បន្ននេះ មហាជន

ទួបទួមមួលត្រកូលគ្នា ស្ថាបនានៅលើមូលដ្ឋានដ៏មាំនៃសាធារណរដ្ឋមួយ ប្រជាជាតិសាធារណរដ្ឋមួយ ដែលត្រូវថ្នាក់ដឹកដៅដោយ : សេរីភាព សមភាព ភាតរភាព វិឌ្ឍនភាព និង សុភមង្គល សំរាប់ទាំងអស់គ្នា ។

ឮជាទួបតំណាងមហាជន ស្ថិតនៅផ្នែកខាងក្រោមនៃសេរនដូចេ្នះ ពីក្រោះមហាជនគឺជាមូលដ្ឋានៃរដ្ឋខ្មែរ ជាគ្រឹះនៃសាធារណរដ្ឋ ដែលអាចរស់នៅស្ថិតស្ថេរឮាន ដោយសារតែមហាជន និងសំរាប់ចំទៅមហាជន ។ ពិតមែនចេ្បាះថា សាធារណរដ្ឋមានដំណើរ ឮាញ់ឆ្ពោះទៅរកវិឌ្ឍនភាព ក៏ប៉ុន្តែមិនមែនឮានសេចក្តីថា ការផ្តាច់ពីអតីតកាល ពីទំនៀមទំលាប់ដែលកើតចេញទេឮាំងពីប្រជារាស្ត្រនោះទេ ។ ដូចេ្នះចេ្បាះឃ្លា ឮានជាទួបភាពដកស្រង់ពីគំនិងកឮាប់ទចនា នៅក្រសោទឮាយ័នឮានកំណត់ទុកយ៉ាងយូរអង្វែងនូវសកឮាភាព ទុក្ខក្រឮាយនិងលេចក្តីលេបឮាយនៃជនជាតិខ្មែរ ដែលជាជនជាតិទាំងប៉ុន្មាន ដូចផែនសិលា ចេ្បាះមិនអាចនឹងរលាស់រុលាយឮានទេឮាំយ ។

២_ ទួបភាពតំណាងកងទ័ព

ទួបភាពតំណាង កងទ័ព គឺជាគំនូរត្រីស្លឹក ឬ ចឮាកមុខថ្មី ដែលជាអាវុធទបស់ក្រពះសីង សំរាប់បញ្ជាញូនូវទស្សីកាទន្ទះប្រល័យសត្រូវ ទចនាទេឮាំងនៅលើផ្នែកជ្រុងខាងដើង និងខាងឆ្វេង ត្រង់ចន្លោះភាគកណ្តាល និងកំពូលនៃសេរន ។ ចឮាកមុខថ្មី នេះអាចជានិមិត្តទួបពិតប្រាកដនៃកងទ័ព ដែលមានអង្គ ៣ គឺ កងទ័ពជើងគោក ជើងអាកាស និង ជើងទឹក ។

ទួបត្រីស្លឹក ឬ ចឮាកមុខ៣នេះស្ថិតនៅចំកណ្តាលខាងលើនៃផ្នែកទួបភាពតំណាងមហាជន ពីក្រោះកងទ័ពកើតចេញមកពីមហាជន ឮាក្តបង្កើតជាមួយមហាជន នូវនៃផ្នែលទ័ពងសំរាប់ការពារមាតុភូមិ និង សាធារណរដ្ឋ ក្នុងពេលមានភ័យន្តរាយ ។ ទួបភាពនេះបង្ហាញឲ្យឃើញដែងវែងថា សាធារណរដ្ឋឮានកើតទេឮាំង ក្នុងស្ថានភាពមួយដ៏លំឮាកពីក្រោះកងទ័ពត្រូវចំណាយពេលវេទ្យាច្រើនឆ្នាំ ដើងការឮាក់ទិងការឮាក់ទងនូវបទពិសោធន៍ទាក់ទងនឹងសង្គ្រាមជាច្រើនសឮាក៏ប៉ុន្តែពិតជាមានជ័យជំនះ ដោយសារកម្លាំងអាវុធ ។ ល្អមជាគជ័យមានដល់កងទ័ព ដែលកើតចេញមកពីប្រជាជនខ្មែរ ។

៣_ ទួបភាពតំណាងសាសនា

នៅផ្នែកខាងលើនៃសេរន ទួបភាពតំណាងសាសនា គឺជា ព្រះពុទ្ធទួប

តង់នៅក្នុងព្រះឥរិយាបថទាំងបួន មានព្រះភក្ត្រមែនចន្លោះទៅទិសទាំងបួន ។ រូបភាពនេះ យកតាមលំនាំដើម នៃចម្លាក់ផ្នាំងសីមា តាំងនៅក្នុងសាសនាធ្វើជាតិ បង្ហាញឱ្យឃើញថា ព្រះពុទ្ធសាសនា ឲ្យនបង្កបង្កើតនូវកម្លាំងយ៉ាងធំខាងផ្លូវសីលធម៌ និងផ្លូវចិត្តនៃប្រជាជនខ្មែរដែលកំពុងប្រយុទ្ធតទល់នឹងអំពើទុច្ចរិតផ្សេងៗ យ៉ាងច្រើន នៃពួកទមិឡ លីយសាសន៍គ្នា ឲនចាប់ទម្លាប់អ្វីសោះ ។

ក-រូបខាងកើត : ព្រះពុទ្ធរូបក្នុងឥរិយាបថ ឋានមុទ្រា : " ព្រះពុទ្ធកំពុងផ្ទៃសមាធិ " ជានិមិត្តរូប នៃកម្លាំងខាងផ្លូវចិត្ត ។

ខ-រូបខាងលិច : ព្រះពុទ្ធរូបក្នុងឥរិយាបថ ធម្មចក្រមុទ្រា : " ព្រះពុទ្ធរូបកំពុងសំដែងធម៌ " ជានិមិត្តរូបនៃប្រភពចំណេះវិជ្ជា និង បញ្ញា ។

គ-រូបខាងជើង : ព្រះពុទ្ធរូបក្នុងឥរិយាបថ អភយមុទ្រា : " ព្រះពុទ្ធដែលគ្មានភ័យតក់ស្លុត " ជានិមិត្តរូបនៃ កម្លាំងសីលធម៌ ដែលគ្មានកម្លាំងអ្វីអាចទប់ទល់ឲ្យនទេឡើយ ។

ឃ-រូបខាងត្បូង : ព្រះពុទ្ធភូមិ ស្បរមុទ្រា : " ព្រះពុទ្ធទ្រង់យកផែនដីជាកសិណ " ជានិមិត្តរូប នៃកម្លាំងឈ្នះលើការប្រឆាំងតប ។

ឲ្យនជាដាក់រូបភាពតំណាងសាសនា ផ្នែកខាងលើនៃសសរនេះដោយហេតុថា សាធារណៈផ្នែកខ្មែរ ឲ្យនប្រកាសយ៉ាងខ្លីទ្បាទិក ទទួលស្គាល់នូវភាពខុសគ្នានៃ "គំនិត" ទៅលើ "រូបធាតុ" ភាពខុសគ្នា និង "ខុសគតិនិយម" ទៅលើ "សម្ភារៈនិយម" ។ រូបភាពនេះមិតនៅក្នុងមាគ៌ាមជ្ឈិមាដិបទា ដែលព្រះពុទ្ធបរមគ្រូទ្រង់ប្រៀសឲ្យនាឲមក គឺថាជាមាគ៌ា " អព្យាក្រឹត្យ " នេះឯង ។

(តាមឯកសារផ្លូវការ ផ្តល់មកពីក្រសួងសាធារណការ
អ្នកស្ថាបនា និង រចនាស្ថបត្យនេះ)

ឫតិសាធារណៈ

នៅគ្រប់ប្រទេសក្នុងពិភពលោកយើងនេះ គេប្រើនថែរក្សាថា ជំណឹងអ្វី ៗ ពត៌មានអ្វី ៗ ថ្លែងផ្សាយតាមវិទ្យុ ឬ តាមទូរទស្សន៍ តាមសារពត៌មាន តាមទស្សនាវដ្តី តាមព្រឹត្តិប័ត្រប្រចាំសប្តាហ៍ សុទ្ធសឹងដាក់ឫតិសាធារណៈទាំងអស់ ។

ត្រង់នេះ យើងនឹងយកពាក្យសាធារណៈមកពិនិត្យផ្សេង ដោយទុកន័យឱ្យឮនស្តាប់ត្រចៀកមុននឹងយើងចង់ដឹងឱ្យច្បាស់ថ្លឹងទៅ ហៅថា"ឫតិសាធារណៈ" នោះ ។

ពាក្យ"សាធារណៈ"គឺជាពាក្យថែលមានន័យថាអ្វី ៗ ថ្លែងជាទូទៅ បើនិយាយពីប្រជាពលរដ្ឋវិញ គឺពាក្យសាធារណៈត្រូវនឹងនាមន័យទាំងនាម ទាល់តែជា "ទាបស់ពលរដ្ឋថ្មើរតែត្រូវ" ។

ពីត្រង់នេះអ្នកឮនជា យើងពុំទាន់ដឹងថាឫតិថ្លឹ ជំណឹងថ្លឹ ថ្លែងផ្សុសចេញពីអង្គការណាមួយ ពី សារពត៌មានណាមួយ ពីទស្សនាវដ្តីណាមួយ ។ ល ។ ពុំទាន់ថានឹងនឮជាមតិ ជាជំណឹងចេញពីសាធារណៈជនឮនទេ ? ពីត្រង់ថា វិទ្យុជាតិ ជាអង្គការទទួលអ្នកការពារអំណាចណាមួយក្រុមគេតែងតែនិយាយឃោសនាតម្រូវទៅតាមតែគោលបំណងរបស់ឯងគេទៅ ពុំមែនមនុស្ស ឬ ពលរដ្ឋទាំងអស់គ្នាទៅនិយាយតាមវិទ្យុឯណា ? ចំណែកជំណឹងថ្លឹ ពត៌មានថ្លឹ ថ្លែងផ្សាយតាមសារពត៌មាន គឺជាជំណឹង គឺជាពត៌មាន ថែលបុគ្គលមួយរូប ឬ ពីរនូបអាចសរសេរចុះផ្សាយឮនទេបើយទ្រោះពុំត្តផ្សាយតាមសារពត៌មាននោះទៅ ។ ដូច្នេះ ពិតមែន មនុស្សរាប់ពាន់រាប់លាននាក់ទៅសរសេរចេញជាអត្ថបទមួយចុះផ្សាយឯណា ?

ឯញត្តិវិញ អាចជាឃោបយ៉ អាចជាបញ្ជ អាចជាចិត្តគំនិត ផ្តុសចេញពីមនុស្សប្រើនបន្តិច ពីត្រង់មុននឹងថ្លឹញត្តិ គេប្រើនថែរឮនពីត្រង់គ្នាប្រើនដែរ យ៉ាងណាក៏ថែលពី "មនុស្សម្នាក់"ដែរ ប្រកាយពីពេលជំនុំម្តង ពុំ ។

ក៏ប៉ុន្តែ បើយើងចង់ដឹងថ្លឹងថ្លឹងអ្វីជាពិតប្រាកដថាជា ឫតិសាធារណៈនោះ ផ្លូចជាមិនងាយដឹងឮនទេ សូមថ្លឹថែរញត្តិនេះក្តី ក៏មិនទាន់ថានឹងថាជា "តំណាងមតិសាធារណៈឮន ឱ្យពេញលេញតាមន័យពិតប្រាកដដែរ ពីត្រង់ដួនកាល មានអង្គការណាមួយប្រើអំណាច ឬ ប្រើមធ្យោបាយថ្លឹ ពុំ ដែរឯង ពុំ ទេវត ចង់ឱ្យគេស៊ើញលើញត្តិទៅក៏សឹងថែរមានដែរ ។

មួយវិញទៀតទេវត ប្រជាពលរដ្ឋភាគច្រើន ទោះជានៅប្រទេសណាក៏ដោយ ប្រើនថែរមានជំនឿទុកថ្លឹថា ជំណឹងអ្វី ៗ ថ្លែងសរសេរចុះផ្សាយតាមសារពត៌មាន តាមទស្សនា-

វិន្តី ។ ល ។ សុទ្ធសឹងតែជា ត្រឹមត្រូវ ជា ការពិតទាំងអស់ ដូចជា មាន ពាក្យ លេចឮសឹងតែគ្រប់ មាត់ថា "តាមការសេតនេះ.....នោះ..... គេជំរាបថាអីចេះ....អីចុះ....." ។ ម្លោះហើយ អ្នកមើលថៃមិនចេះយកការពិចារណាមកដាក់ខ្លួនផងទេ កំចេះតែជឿទៅ ។ ត្រង់នេះហើយ ឮជាអ្នកដឹកនាំ ប្រទេសនិមួយ ៗ គេត្រូវចេះឮច្បាស់ ចេះលៃ ចេះស្គាល់តម្លៃ នូវ ការពិត ពី "មតិសាធារណៈ" នេះ ។ បើមិនដូច្នោះទេ អ្នកការពារទង្វើ ៗ មុខជា មិនអាច ធ្វើការ មិនអាចចាត់ការឱ្យឮនត្រឹមត្រូវទៅឮនទេ ។ ម្លោះហើយទាំងឱ្យមានការប្រឆូក ប្រចលាំជាមិនខាន ។

ក្នុងទង្វើងមតិសាធារណៈនេះ យើងនឹងលើកយកខ្ទាហរណ៍មួយមកលាតត្រដាង អំពី ការខ្វែងគំនិតគ្នារវាងអ្នកទទួលខុសត្រូវក្នុងការដឹកនាំ ប្រទេសជាមួយនឹងមតិសាធារណៈ ។ យើង លើកយកទង្វើងផ្ទើខេមរយានកម្មទៅ ក្រសួងអប់រំជាតិមួយផ្ទើជាខ្ទាហរណ៍ក្នុងការខ្វែងគំនិតគ្នាខ្លះ ។

ក្នុងទង្វើងនេះ ក្រសួងអប់រំជាតិឮនចាប់អនុវត្តនិនូវខេមរយានកម្មនេះ រហូតមក ដល់ឆ្នាំ ១៩៣១ ឮនបួនឆ្នាំហើយ ។ មានដំណើរការហាក់ដូចជា ស្រួលទៅមុខគ្នា នការរអាក់រអួល អ្វីទេឡើយ ចំញោះលោកគ្រូ អ្នកគ្រូ ព្រមទាំងសាស្ត្រាចារ្យគ្រប់ជាន់ថ្នាក់មួយផ្នែក និងចំពោះ សិស្សដែលជាអ្នកទទួលឈ្វេងផលពីការរៀនមុខវិជ្ជាផ្សេង ៗ តាមខេមរយានកម្មនេះ ។

តទៅនេះ យើងនឹងលើកយកចំណុចសំខាន់ខ្លះ ៗ ក្នុងសេចក្តីរាយការណ៍ នៃគណកម្ម-ការពិនិត្យ និង ប្រមាណឈ្វេងនៃការអនុវត្តនិខេមរយានកម្ម តែងតាំងទៀងដោយលិខិតបង្គាប់ការ លេខ ១៩៨ អទវ-កច. ចុះថ្ងៃ ២៣-៣-៣១ ដែលឮនឮមប្រជុំទៅជាតិមន្ទីរវិទ្យាធនៃនការអប់រំ ក្រោមអធិបតីភាពនៃលោក ម៉ាង ម៉ូរី ជាប្រធាន ដើម្បីនិះរកគោលការណ៍ ប្រតិបត្តិការ ឱ្យការនិះកិច្ចរបស់ខ្លួនលំនៃចការងារឱ្យឮនប្រសើរ ។

គឺថា គណកម្មការនេះ មានចែកជាគណកម្មការរងតាមមុខវិជ្ជានិមួយ ៗ ដោយ ត្រូវបន្ថែមអ្នកឯកទេសខ្លះទៀត តាមលិខិតបង្គាប់ការលេខ ២១០ អទវ.កច. ចុះថ្ងៃទី ២៩-៣-៣១ ។

គណកម្មការរងទាំង ៥ ត្រូវចាប់ផ្តើមកិច្ចការរបស់ខ្លួន ចាប់ពីថ្ងៃ ២៩-៣-៣១ ទៅទល់នឹងថ្ងៃ ១-៤-៣១ ។

គណកម្មការរងទាំង ៥ នេះឮន

ក- ពិនិត្យតាមថ្នាក់ទៀន

-មើលឱ្យឮនយ៉ាងតិចណាស់ : ៥ ថ្នាក់ទៅភ្នំពេញ
: ១ ថ្នាក់ទៅតាខ្មៅ

-ស្រង់យោបល់ពីសាស្ត្រាចារ្យ

-ស្រង់យោបល់ពីសិស្ស

១- ចេីកការប្រមូលស្រង់យោបល់ពីសាស្ត្រាចារ្យនៅសាលប្រជុំនៃទីស្នាក់ការ ភ្នំដូនពេញ ក្រីកថ្ងៃទី ២-៤-៩១ ។

តទៅនេះជាយោបល់រួមបីនគរះកម្មាធិការ

"គណកម្មការពិនិត្យនិងប្រមាណលទ្ធផលនៃការអនុវត្តនិទេសវយានកម្ម ក្រោយពីបានដេីរពិនិត្យ និងផ្តេីអធិការកិច្ចរណែាស្ត្រាចារ្យរួចមកបានកត់សំគាល់នូវមួយចំនួនដូចតទៅនេះ :-

១- ការកត់ចំនីដែលការទេខមនហានកម្មបកប្រែ ឬ បន្ថែម

ក-ការកត់ចំនីភាគធំមានលក្ខណៈត្រឹមត្រូវ ឯការខ្វះចន្លោះនោះជាការលម្អតាទេ ក្រែាះជាកិច្ចការទេីបចាប់ផ្តេីមថ្មី ។

ខ-សិស្សទូទៅ អាចយល់ដេីមនៃការកត់នីមួយ ពុំបានច្បាស់ មិនមានការភ័ន្តច្រឡំជាអំណោយមួយដ្ឋេីមនីក្យចាប់យកនូវមុខវិជ្ជាបានយ៉ាងដាយ ។

គ-សាស្ត្រាចារ្យយល់ថា ក្នុងជាចំនាស់ក្នុងការបង្រៀនទេដែរ ។

២- វិធីសាស្ត្របង្រៀនជាយកភាសាខ្មែរជាយាន

ក. សាស្ត្រាចារ្យទូទៅ យល់ច្បាស់ថា ការបង្រៀនមុខវិជ្ជា ជាភាសាខ្មែរពុំមានចំនាស់និងតាលការណ៍តស៊ូការលំបាកទេដែរ ក្រែាះ :

ក-សិស្សអាចស្តាប់បានអាចយល់ អាចចាំ ចេីយចេះច្បាស់ ពុំដែលភ្លឹងភ្លាងបានដេីមបីថា យល់ចេីយ ទេីបភ្លេចភ្លាំងភ្លាំងវិញ ។

ខ-សិក្សាពុំទៀន ជាយទន្ទេញរួមទៀនដែរ ពុំឱ្យចាំមាត់តាមសៀវភៅស្ត្រាចារ្យជាក់ឱ្យទេ តីការចេីតឯង្ហាប្រយោជន៍បានជាយខ្លួនឯង ពុំចាំបាច់ប្រកួតតាមចាំ តាមសាស្ត្រាចារ្យទេដែរ ។

គ-ថ្នាក់ពីរមួយ ពុំ មានសកម្មភាពនស់ទេទីក ក្រែាះលើសិស្សហ៊ានសាកល្បងសាស្ត្រាចារ្យ ឬយកសៀវភៅណែនាំមកសិក្សាលើផ្ទៃក្តារ ពុំចាំបាច់ចេះច្រៀងច្រៀង ។

ឃ-សិស្សយល់ច្បាស់នូវសារៈនៃមុខវិជ្ជាពីរមួយ ពុំ ។

៣- សាទរនៃវិជ្ជា និង កិរិតុវិជ្ជាសិស្ស

ក-សាទរនៃវិជ្ជា : តាមយោបល់សាស្ត្រាចារ្យទូទៅ សិស្សអាចក្រែបជញ្ជាក់ នូវសាទរនៃវិជ្ជាឲ្យបានយ៉ាងល្អប្រសើរណាស់ ព្រោះសិស្សម្នាក់ៗ ឃុំ យល់នូវអត្ថន័យ និង អត្ថរស នៃវិជ្ជានោះ យ៉ាងច្រើនច្រុះ ហើយសន្ធុះទឹកចិត្ត កំមានសកម្មភាពខ្លាំងក្លាណាស់ដែរ ។

ខ-កិរិតវិជ្ជាសិស្ស : ប្រសិនបើប្រៀបធៀបកិរិតវិជ្ជាសិស្សសម័យខេមរយោធកម្ម និងសម័យប្រើភាសាបរទេស ជាយោធគណៈកម្មការបច្ចេកទេស និង សាស្ត្រាចារ្យទូទៅ អាចសន្និដ្ឋានថា កិរិតវិជ្ជាសិស្សសម័យខេមរយោធកម្ម ពិតជាខ្ពស់ជាងសម័យសិក្សាវិជ្ជា ជាភាសាបរទេស ហើយដោយហេតុតែការសិក្សាវិជ្ជាជាភាសាជាតិ នាំឲ្យសិស្សយល់អារម្មណ៍ទូលំទូលាយ និង ច្រើនច្រុះ នូវខ្លឹមសារ នៃវិជ្ជានិមួយៗ ឃុំ ថែមទៀត ប៉ុន្តែក្នុងបច្ចុប្បន្នកាលនេះ គណកម្មការមិនអាចធ្វើអត្ថាធិប្បាយទៀបក្នុងវិស័យ "និយាកាល" បានសំពាក្យពេចន៍ដែលឮនាមកមកហើយ ។

អាស្រ័យហេតុនេះ គណៈកម្មការពិនិត្យ និងប្រមាណលទ្ធផលនៃ អនុវត្តន៍ខេមរយោធកម្មយល់ថា ការបន្តខេមរយោធកម្មនៅ ចុតិយភូមិនៃមធ្យមសិក្សាជាការចាំបាច់ណាស់ ហើយយល់ឃើញថា ខេមរយោធកម្មសិក្សាពិតជាឆ្លើយតប នឹងសេចក្តីត្រូវការពិតប្រាកដ នឹងប្រយោជន៍ប្រជាជាតិខ្មែរផង ហើយនឹងជួយលើកស្ទួយកិរិតវិជ្ជាសិស្សឲ្យកាន់តែប្រសើរថែមទៀតផង។

ចំពោះមធ្យោបាយដំ ជំនុំ ខេមរយោធកម្មទៅថ្នាក់លើទៀតនោះគណៈកម្មការយល់ស្របតាមសេចក្តីសង្កេត និងសេចក្តីស្នើទាំងអស់នៃអស់លោកសាស្ត្រាចារ្យ នាពេលប្រជុំថ្ងៃទី ២ មេសា ១៩៣១ ក្នុងន័យសំខាន់ទាំងបី គឺ :

១-ការលើកទឹកចិត្តគណៈកម្មាធិការជាតិ ដោយឲ្យមានស្តេរភាពគ្រប់គ្រាន់ ក្រោមការគ្រប់គ្រងនៃចប្បាប់បញ្ញត្តិត្រឹមត្រូវ ដើម្បីបំបាត់ភាពតែលតោលដូចគ្រាមុនមក ។

២-ការទៀបចំឲ្យមានប្រជុំសាស្ត្រាចារ្យតាមមុខវិជ្ជា ដើម្បីទិនភូបមន្តថ្មីៗ ទៀត ក្នុងការបន្តខេមរយោធកម្ម ។

៣-ផ្តល់ជំនួយសម្ភារៈ ហិរញ្ញវត្ថុ និង បុគ្គលិកប្រយោជន៍ឲ្យគណៈកម្មាធិការជាតិប្រតិបត្តិការទៅបានទ្រលុងទ្រលាយ ពុំមានតូចទូលំទូលាយ ក្នុងការនិពន្ធសៀវភៅ ឬកម្រងមេរៀនផ្ញើទៅសាស្ត្រាចារ្យក្នុងក្រុងនិងខេត្តក្រៅ " ។

ក្នុងទេរឿងនេះ ដែលយើងលើកយកមកធ្វើជា ខ្ទាបទណីមួយក្នុងទេរឿងខ្វែងយោបល់គ្នា ខ្លះនោះ គឺមកតែពីអ្នកដឹកនាំ ខ្លះសំអាងទៅលើមតិសាធារណៈនេះឯង ។

ចំពោះទេរឿងគណៈកម្មាធិការនេះវិញ ដែលជាមធ្យោបាយមួយ បន្ទាប់ពីមធ្យោបាយធំៗ សំទាប់ស្វែងមតិសាធារណៈ ក្នុងក្របខ័ណ្ឌក្រសួងនិមួយៗ ។ បន្ទាប់ទៅទេរឿងនេះវាជាទេរឿងបច្ចេកទេសផង បើយើងស្វែងមតិសាធារណៈ ដូចពីមធ្យោបាយនេះ វាហាក់ដូចជាពុំសមហេតុសមផលខ្ទាបទណី ដូចជាគ្រូពេទ្យខាងនេះការតែអ្នកជម្ងឺ មុនពេលចាប់ផ្តើមការតែ តើលោកគ្រូពេទ្យត្រូវទៅសុំទន្ទានអ្វីឲ្យចាត់ចែងធ្វើ "ប្រជាមតិ" ស្នើសួរទាស្ត្រីខ្លួនទៅ ឬក៏ស្នើសួរតែម្តងទង្គិចគ្រួសារអ្នកជម្ងឺទៅចុះ ដើម្បីឲ្យប្រជាពលរដ្ឋ ឲ្យយោបល់មកថា ត្រូវទៅការតែឬ មិនត្រូវទៅ?

បើក្រសួងអប់រំជាតិ ស្តាប់តាមតែសេរតីមានក្តី តាមទស្សនាវិជ្ជីវក្តី ថាជាមតិសាធារណៈ ដែលប្រទាំងនឹងការអនុវត្តនិខេមវយោនកម្ម ហើយបង្ហាក់ដំណើរទៅនៃខេមវយោនកម្មនោះទៅវិញ ទេរឿងនេះ យើងខ្ញុំយាក់ដូចជាលែងយល់អ្វីទាំងអស់ ព្រោះថា បើយើងប្រដូចលោកគ្រូ លោកសាស្ត្រាចារ្យ ជាអ្នកបង្ហាត់បង្រៀនសិស្សមកនឹងលោកគ្រូពេទ្យ ហើយប្រដូចសិស្សជាអ្នកទៀនមកនឹងអ្នកជម្ងឺទៅវិញ ហើយអ្នកជម្ងឺ គេនាំគ្នាសប្បាយចិត្ត នឹងវិធីព្យាបាលទោគទបស់លោកគ្រូពេទ្យទៅហើយ តើគេថាជម្ងឺគេជាសះស្បើយមែនយ៉ាងណាបន្តិចសោះ ហេតុដូចម្តេចក៏យើងទៅនាំគ្នាដៀមតិសាធារណៈថា "មិនជាទេ" ឯណោះទៅវិញ ?

មានការខ្លះដូចជាខាងផ្នែកនយោបាយ គេតែងតែប្រើ "ប្រជាមតិ" ជាមធ្យោបាយស្វែងស្គាបមតិសាធារណៈ ដូចសម្តេចសីហនុ លោកបានធ្វើមកហើយ ។

តែថ្វីត្បិតតែសម្តេចលោកប្រើមធ្យោបាយនេះទៅហើយក្តី តើយើងអាចសង្ឃឹមបានថាជាមតិសាធារណៈពិតប្រាកដបានទេ ? តើពេលដែលទាស្ត្រទៅជួបៈ ទាស្ត្រាបានទទួលការទបង្គិតបង្គំពីអ្នកការនំអំណោចជំនាន់នោះទេ ? ត្រង់នេះហើយ ដែលយើងយល់ថា គេមិនអាចស្វែងមតិសាធារណៈឲ្យបានមួយរយភាគរយនោះទេ តែគេអាចទិះរកមធ្យោបាយខ្លះៗ ដូចយើងបានទៀបទាប់មកហើយ ។

មតិសាធារណៈក្នុងប្រទេសចំពោះព្រឹត្តិការណ៍ ១៨មីនា ១៩៧០ នៅប្រទេសខ្មែរ

បើយើងលើកយកត្រឹមញត្តិមកធ្វើជាមធ្យោបាយសំទាប់ស្វែងមតិសាធារណៈ ចំពោះព្រឹត្តិការណ៍ ១៨ មីនា ១៩៧០ យើងនេះ មតិសាធារណៈក្នុងប្រទេសយើង ដែលសាតត្រង់ជាងតាមញត្តិទបស់សមាគមអ្នកសាសេរតីមានខ្មែរ ញត្តិនៃប្រជាទាស្ត្រគ្រប់ខេត្ត មានដូចតទៅ :

ក- ញត្តិទបស់សមាគមអ្នកសាសេរតីមានខ្មែរ

យើងដកស្រង់យកតែកន្លែងខ្លះដូចតទៅនេះ :

សមាគមអ្នកសារពត៌មានខ្មែរ នៅក្នុងសម័យប្រជុំពិសេសវិសាមញ្ញ ដែលប្រព្រឹត្តទៅនៅក្រសួងឃោសនាការ កាលពីថ្ងៃទី ១៨ មីនា ១៩៧០ វេលាម៉ោង ៩ ព្រឹក ឯកច្ឆន្ទដូចតទៅនេះ ៖

១-សូមប្រកាសជាមធ្យោបាយការទឹកគាំទ្រដោយឥតលំអៀង ដូចមហាជាតុកម្មវិធីប្រជាពលរដ្ឋខ្មែរ ដែលមានចិត្តដៅប្រអាប់ និងវត្តមានខែនកងទ័ពវៀតកុង វៀតចិញ្ចឹមដែលបានចូលមកឈ្លានពាន តាំងមូលដ្ឋានលើទឹកដីខ្មែរ ។

២-សូមប្រកាសគាំទ្រទាំងស្រុង ដូចសេចក្តីសម្រេចចិត្តរបស់សភាទាំងពីរដែលបានប្រគល់អំណាចពេញលេញតាមមាត្រា ១៥ នៃរដ្ឋធម្មនុញ្ញដូចនរដ្ឋាភិបាលស្រោចស្រង់ជាតិ ដើម្បីចាត់ការគ្រប់មធ្យោបាយក្នុងបេសកកម្មស្រោចស្រង់ជាតិ ជាពិសេសគាំទ្រការដកថានេះប្រមុខរដ្ឋពីស្តេចនរោត្តមសីហនុ ។

៣-សូមសំដែងសេចក្តីទុកចិត្តទាំងស្រុង ចំពោះសេចក្តីថ្លែងការណ៍របស់ឯកឧត្តម ឧត្តមសេនីយឯក លន់ នល់ ផ្សាយតាមទិព្យជាតិកាលពីថ្ងៃទី ១៨ មីនា ១៩៧០ ដែលបានអះអាងយ៉ាងម៉ឺងម៉ាត់ថា នឹងរក្សាប្រទេសកម្ពុជាខ្មែរនៅជារបស់ខ្មែរ ក្នុងមានន័យអព្យាក្រឹត្យត្រឹមត្រូវនិងឯករាជ្យយ៉ាងសកម្ម ។

៤-សូមប្រកាសប្រឆាំងជាដាច់ខាត ចំពោះបុគ្គលិកទាំងអស់ណា ដែលចូលដែរសមគំនិតក្នុងការលក់ស្រុកខ្មែរជូន ។ សូមប្រឆាំងជាដាច់ខាតទៅតចំពោះជនណាមួយដែលចេញមុខប្រឆាំងនឹងព្រះតុកម្មដែលជាឥន្ទ្រះដុះចេញពីដួងចិត្តរបស់ប្រជារាស្ត្រខ្មែរស្នេហាទឹកដី ។

៥-សូមប្រកាសទាមទារដោយទទូចសុំឱ្យរដ្ឋាភិបាលដាក់ទោសកុំប្រណីដល់ជនទាំងឡាយណាដែលបានប្រើអំណាចផ្តាច់ការដើរជាផលប្រយោជន៍ឱ្យតែប្រវត្តិសាស្ត្រដូចយ៉ាងព្រួសារអ្នកម្នាងម៉ូនិកសីហនុ ជាពិសេសសូមឱ្យរដ្ឋាភិបាលមេត្តាចាត់វិធានការទឹបអូស យកសម្បត្តិមហាជនក្រីក្រទាំងអស់របស់ជនជាតិពួកនេះមកជាកំដាសម្បត្តិរដ្ឋ ។

៦-សូមប្រកាសបដិសេធជាខ្លាំងថា សេចក្តីសម្រេចចិត្តរបស់មហាសន្និបាតនៃសមាគមអ្នកសារពត៌មានខ្មែរ ដែលបានដូនតំណែងប្រធានកិត្តិយសកាលពីពេលមុនទៅ ស្តេចនរោត្តមសីហនុ នោះឥឡូវនេះសូមប្រកាសទុកជាមោឃៈចាប់ពីថ្ងៃទី ១៩ មីនា ១៩៧០ នេះតទៅឯងទៅ ។

ភ្នំពេញ ថ្ងៃទី ១៩ មីនា ១៩៧០

សមាគមអ្នកសារពត៌មានខ្មែរ

ញត្តិនៃប្រជារាស្ត្រ ខេត្តព្រៃវែង

តាមទូរលេខមួយច្បាប់ ចុះថ្ងៃទី ១៩ មីនា ១៩៧០ អភិបាលខេត្តព្រៃវែង ប្រាប់ដំណឹងថា ប្រជារាស្ត្រគ្រប់មជ្ឈដ្ឋានក្នុងខេត្តទាំងមូល ។ ប្រជារាស្ត្រគ្រប់មជ្ឈដ្ឋានក្នុងខេត្តព្រៃវែង ប្រាប់សំដែងសាជាថ្មីនូវការគាំទ្រទាំងស្រុងរបស់ខ្លួន ចំពោះសេចក្តីសម្រេចរបស់សភាទាំងពីរ ដែលប្រាប់ផ្ញើរមកប្រជុំ និង ចំពោះសេចក្តីថ្លែងការណ៍នៃរបស់រដ្ឋាភិបាល ។

ឯប្រជារាស្ត្រគ្រប់ខេត្តក៏ប្រាប់ផ្ញើញត្តិគាំទ្ររដ្ឋាភិបាលស្រោចស្រង់ជាតិមានសេចក្តីប្រហែលៗគ្នា នឹងញត្តិខាងលើនេះដែរ ។ យើងមិនច្បាស់យកមកចុះផ្សាយទេ ។ តែចំពោះខេត្តកំពង់ចាម ខេត្តព្រៃវែង ហាក់ដូចជាមានការផ្ទុយស្រឡះពីសេចក្តីគាំទ្រនេះ ។

ចំពោះអ្នកការទូតយើងភាគច្រើននៅបរទេស ក៏ប្រាប់ផ្ញើទូរលេខបន្តបន្ទាប់គ្នាមកសំដែងការគាំទ្ររបស់ខ្លួនចំពោះរដ្ឋាភិបាលស្រោចស្រង់ជាតិដែរ ។

ចំណែកព្រះសង្ឃវិញ ក៏ព្រះអង្គលោកយល់ព្រមភាគច្រើននឹងការដកហូតសម្តេចសីហនុចេញពីមុខដំណែងប្រមុខរដ្ឋនេះដែរ ។

មតិសាធារណៈក្រៅប្រទេស ចំពោះព្រឹត្តិការណ៍ ១៨ មីនា ១៩៧០ នៅប្រទេសថៃ

យើងនឹងលើកយកតែប្រទេសបីបួនមកនិយាយ ពីព្រោះយើងយល់ថាយើងថា នេះវាជាទឡ្ហីឯនយោបាយមួយទាក់ទងទៅនឹងទឡ្ហីឯនយោបាយអន្តរជាតិ គឺជាទឡ្ហីឯបះទង្គិចរវាងប្លុកទាំងពីរ គឺខាងប្លុកកុម្មុយនិស្ត និង ប្លុកលោកសេរី ។

ដូច្នេះចំពោះមតិសាធារណៈក្នុងប្រទេសនិមួយៗ នោះវាយោលទៅតាមខ្សែបន្ទាត់នយោបាយរបស់គេទួចស្រែចទៅហើយនេះមង្ក៉ាងទៅ ឯមង្ក៉ាងទៀត ការផ្តល់មតិមកលើព្រឹត្តិការណ៍ ១៨ មីនា ឬយើងនេះ វាជាប់ទាក់ទងទៅនឹងផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ប្រទេសគេ ក្នុងទឡ្ហីឯសេដ្ឋកិច្ចក្តី ក្នុងទឡ្ហីឯនយោបាយក្តី ឧទាហរណ៍ ដូចជាប្រទេសបារាំង ប្រទេសសៀមដែលនៅជិតយើងនេះស្រាប់ ។ ល ។

ហើយបើយើងយកមតិតាមសារពត៌មានថាជា មតិសាធារណៈដែរនោះ យើងនឹងលើកយកមតិតាមសារពត៌មានរបស់ប្រទេសខ្លះៗ ដូចជា ប្រទេសវ៉ៀតណាមខាងត្បូង សហរដ្ឋអាមេរិក ប្រទេសនេប៉ាល់ និងប្រទេសអង់គ្លេស ជាដើម ដូចតទៅនេះ ។

ក) ប្រទេសឥណ្ឌូណេស៊ី

ក្នុងពេលទាត្រីថ្ងៃទី ២៥ មីនា ១៩៧០, លោក អាដាំ ម៉ាលិក ជារដ្ឋមន្ត្រីក្រសួងការបរទេសនៃប្រទេសឥណ្ឌូណេស៊ី ប្តូនថ្លែងបញ្ជាក់ថា ប្រសិនបើស្តេចនរោត្តមសីហនុប្តូនបង្កើតរដ្ឋាភិបាលក្រៅប្រទេសមួយនោះ តើប្រទេសឥណ្ឌូណេស៊ីនឹងទទួលស្គាល់របបក្រៅច្បាប់នេះមួយ ? ។ ក្នុងការថ្លែងលោកប្តូនផ្តល់យតបចំពោះសំនួរបស់ពួកការសែត នាកាលថ្ងៃលោកប្តូនទិលត្រឡប់មកពីចូលរួមក្នុងកិច្ចប្រជុំសុន្ទិស្ថិទឥស្លាមនៅក្រុង ដេស្តដាហ៊ិ ទិញ្ញនោះ លោក ម៉ាលិក ប្តូនមានប្រសាសន៍ បញ្ជាក់ថា ក្នុងរយៈកាលទង់ចាំទំាងដប់ពេលនោះ.. ប្រទេសឥណ្ឌូណេស៊ី ប្តូនទទួលស្គាល់រដ្ឋាភិបាលនៃលោកខុត្តមសេនីយឯក លន់ នល់ ហើយថា ទៀងចាត្តុថ្ងៃលប្តូនកើតមាននៅប្រទេសកម្ពុជានោះទៀត កំក្រុងហ្សាការតាចាត់ទុកជាកិច្ចការផ្ទៃក្នុងរបស់ខ្មែរដែរ ។

ខ) សហរដ្ឋអាមេរិក

កាលពីថ្ងៃទី ៣០ មេសា ១៩៧០, លោក និច សុន ប្រធានាធិបតីសហរដ្ឋអាមេរិក ប្តូនផ្ញើសេចក្តីថ្លែងការណ៍យ៉ាងសំខាន់ស្តីពីបញ្ហា ប្រទេសកម្ពុជា ដោយលោកប្តូនគាំទ្ររដ្ឋាភិបាលស្រោចស្រង់ជាតិ ដែលមានលោកខុត្តមសេនីយឯក លន់ នល់ ជានាយកហើយលោកបញ្ជាក់ថា មានតែការដេញតាមកំចាត់ទ័ពយួនកុម្មុយនិស្តខ្មែរសឹងតែប៉ុណ្ណេះទេ ដែលជាកិច្ចទាំងនេះទាំងខ្មែរសហរដ្ឋអាមេរិកអាចដកចេញពីបរបស់ខ្លួនទាំងអស់ចេញពីយៀកណាមខាងត្បូងបាន ។

កាលពីថ្ងៃព្រហស្បតិ៍ទី១ ខែមេសា ១៩៧០ លោក ទិលីយ៉ាំ រ៉ូហ្ស៊ែរ ជារដ្ឋលេខាធិការក្រសួងការបរទេសអាមេរិកាំង ប្តូនផ្ញើសេចក្តីរាយការណ៍មួយស្តីពីបញ្ហា ភូមិភាគអាស៊ីអាគ្នេយ៍ជូនគណៈកម្មការ កិច្ចការបរទេសនៃព្រឹទ្ធសភា ដោយលោកប្តូនគាំទ្ររដ្ឋាភិបាលស្រោចស្រង់ជាតិ ពេញលក្ខណៈ ហើយលោកប្តូនបញ្ជាក់ថា : សហរដ្ឋអាមេរិកនឹងផ្ញើឱ្យអស់ពីសមត្ថភាពរបស់ខ្លួនទៅក្នុងអព្យាក្រឹត្យភាពនៃប្រទេសកម្ពុជា ។

លោក ទិលីយ៉ាំ រ៉ូហ្ស៊ែរ ប្តូនបន្តែមថា :

សហរដ្ឋអាមេរិកពុំប្តូនលូកដៃដោយផ្ទាល់ ឬមិនផ្ទាល់ទៅក្នុងព្រឹត្តិការណ៍ដែលប្តូនកើតទៀងនៅប្រទេសកម្ពុជាទេ ។ អំពីព្រឹត្តិការណ៍នេះ គឺ លោក ទិលីយ៉ាំ រ៉ូហ្ស៊ែរ ពិតជាចង់និយាយអំពីទៀង វ៉ាំស្តេចសីហនុហ្នឹងឯង លោក ម៉ាយម៉ា ដន់ហ្វ្រេល ជាមេដឹកនាំភាគច្រើននៃគណៈបក្សប្រជាធិបតេយ្យកំលោកមានមតិយល់ស្របនឹងលោក រ៉ូហ្ស៊ែរដែរ ហើយលោកប្តូនបញ្ជាក់នៅមុខព្រឹទ្ធសភាថា : " លោកប្តូនសំដែងការដឹកាស់ទបស់លោកចំពោះគ្រប់កិច្ចសន្យាទាំង

អស់រយៈពេលអាច មេទ័ពឯទៅប្រទេសកម្ពុជាវិញ ក្រោយពីការដកអតីតប្រមុខរដ្ឋខ្មែរចេញពីតំណែងនេះ..." ។

លោក ហ៊ិរុក អាយកេន ជាសមាជិកព្រឹទ្ធសភាតំណាងរដ្ឋមិនមែនបក្ស និងជាព្រឹទ្ធបុរសផ្នែកខាងគណៈបក្សសាធារណរដ្ឋនិយមនៃគណកម្មការទទួលបន្ទុកកិច្ចការបរទេសព្រមទាំងប្រកាសគាំទ្រនូវភាពស្របច្បាប់នៃរដ្ឋាភិបាលក្រុងភ្នំពេញ លក្ខណៈហើយលោកព្រមានប្រកាសថា.. លោកប្រធានាធិបតី និច សុនន មុខជាពុំព្រមថ្នាំទីនៃការលើកសង្គ្រាមឱ្យទាល់ជាលក្ខណៈភូមិភាគអាស៊ីអគ្នេយ៍នេះទេដែរ ។

គ) ប្រទេសនេប៉ាល់

ក្រោមចំណងជើងថា : " Un acte d'équité " ដែលចុះផ្សាយនៅក្នុងសារពត៌មាន " Le Courrier Phnompenhois លេខ ចុះថ្ងៃទី ១០ មេសា ១៩៧០ អ្នកនិពន្ធបានពោលថា :

"លោក Rajbhandhari រដ្ឋមន្ត្រីក្រសួងការបរទេស ប្រទេសនេប៉ាល់បានប្រកាសថា :.." ប្រទេសនេប៉ាល់គ្មានការព្រួយបារម្ភចាក់ទងខ្លាំងការទូតជាមួយស្តេចសីហនុទេ ហើយថាព្រឹត្តិការណ៍ថ្មីៗ នៃប្រទេសកម្ពុជានេះ គឺជាកិច្ចការខាងក្នុងប្រទេសខ្មែរ " ។ លោកបានពោលថាដូច្នេះគឺ លោកយល់ថា : ការដែលដកសីហនុពីតំណែងប្រមុខរដ្ឋពិតជាការត្រឹមត្រូវតាមទង្វើធម្មនុញ្ញហើយ ។

ឃ) ប្រទេសអង់គ្លេស

តាមទិដ្ឋភាពនៃសារពត៌មាន " Times " នៅទីក្រុងឡុង កាលពីថ្ងៃទី ១៩ មីនា ១៩៧០ បានពោលថា :

"..... ប៉ុន្តែមានតែមួយទេដែលបញ្ជាក់អំពីការដែលស្តេចសីហនុធ្លាក់ពីតំណែងប្រមុខរដ្ឋកម្ពុជា គឺការទទួលស្គាល់នៃប្រទេសជាតិចំពោះស្តេចអង្គនេះដែលមិនព្រមស្តាប់ឮបណ្តាពួកបញ្ញវន្តខ្មែរហើយផ្ទៃតាមតែដំបូន្មានពួកបរទិសទន្លងប៉ុណ្ណោះ ។

ម្យ៉ាងទៀតការបរាជ័យខាងវិស័យកិច្ចបណ្តាលឱ្យប្រទេសជនមានសភាពខឹងខ្លាំងចំពោះស្តេចសីហនុដោយប្រទេសជាច្រើនបានទុកសីហនុជាបងសម្លាប់អាងតួនាទីការពារប្រទេស.... ។

ជំពូក ៥

- វិធានការរដ្ឋាភិបាល ស្តែចស្រង់ជាតិចាត់
នៅក្រៅប្រទេស ដើម្បីកសាងសាធារណរដ្ឋខ្មែរ
- ភ្នាក់ងារ នៃ ចំបាំងនៅក្រៅប្រទេសខ្មែរ

ទិដ្ឋាការដែលរដ្ឋាភិបាលព្រះបាទសម្តេចព្រះនរោត្តមសីហនុ ប្រទានជូនដល់ជនបរទេស

ដើម្បីកុំឲ្យមានការភ័ន្តច្រឡំដល់ជនជាតិខ្មែរនៅក្នុងប្រទេសយើង ដែលមិនបានដឹងច្បាស់ពីព្រឹត្តិការណ៍ ១៨ មីនា ១៩៧០ រដ្ឋាភិបាលព្រះបាទសម្តេចព្រះនរោត្តមសីហនុ បានសម្រេចចិត្តលុបចោលនូវទិដ្ឋាការទាំងឡាយ ដែលបានប្រទានជូនដល់ជនបរទេសទាំងឡាយ ដែលមានបំណងចង់ចូលមកក្នុងប្រទេសកម្ពុជា ។

ក្រោយពីព្រឹត្តិការណ៍ ១៨ មីនា នេះភ្លាម រដ្ឋាភិបាលបានចាត់ការដូចតទៅ :

- នៅថ្ងៃ ២០ មីនា ១៩៧០ រដ្ឋាភិបាលបានសរសេរជំរាបអង្គភាពនានា (Missions diplomatiques et Consulaires et les organismes internationaux) ដែលនៅភ្នំពេញថា ប្រទេសកម្ពុជាមិនបានទទួលទៀតទេ គឺនៅតែបន្តទទួលអត្ថប្រយោជន៍តែមួយគត់ (តាមលិខិត លេខ 325/DGP/AP ចុះថ្ងៃទី ២០ មីនា ១៩៧០) ។

- នៅថ្ងៃ ២១ មីនា ១៩៧០ រដ្ឋាភិបាលព្រះបាទសម្តេចព្រះនរោត្តមសីហនុ បានផ្តល់សេចក្តីប្រកាស (Communiqué du Gouvernement) ច្បាស់ពីភាពលោកថា ប្រទេសកម្ពុជានឹងមិនអាចអនុញ្ញាតឲ្យទីភាប័ទប្រទេសមកកាន់កាប់ទឹកដីខ្លួនបើយសម្តែងការកប្បកិរិយាដូចជាម្ចាស់ទឹកដីទៀតទេ ។

បន្ទាប់មកទៀត ក្នុងសេចក្តីប្រកាសនេះដដែល រដ្ឋាភិបាលបានអំពាវនាវដល់សហប្រជានាតិទាំងពីរនៃសន្និសិតនាក្រុងហ្សឺណែវ ១៩៥៤ ឲ្យបញ្ជូនគណៈកម្មការអន្តរជាតិខាងកិច្ចត្រួតត្រា (C.I.C) ឲ្យមកចំពេញបេសកកម្មរបស់ខ្លួននៅប្រទេសកម្ពុជាទៀងវិញ ។

- នៅថ្ងៃ ២២ មីនា ១៩៧០ រដ្ឋាភិបាលខ្មែរបានសរសេរទៅជំរាបលោកអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ថាប្រទេសកម្ពុជាមិនបន្តរបន្ទាន់ទទួលរបស់ខ្លួនទេ (តាមលិខិត N°62/DGP/AP/X ចុះថ្ងៃទី ២២ មីនា ១៩៧០) ។

- នៅថ្ងៃ ២២ មីនា ដដែលនេះ ក្រសួងការបរទេស នៃរដ្ឋាភិបាលព្រះបាទសម្តេចព្រះនរោត្តមសីហនុ បានសរសេរលិខិត ពីរ មួយទៅ Ambassade du Royaume-Uni de Grande Bretagne នៅភ្នំពេញ មួយទៀតទៅ Ambassade de l'Union des Républiques Socialistes soviétiques au Cambodge (P.Penh). សុំឲ្យលោកសហប្រធាន នៃសន្និសិតក្រុងហ្សឺណែវ ឆ្នាំ ១៩៥៤ មេត្តាចាត់តាំងគណៈកម្មការអន្តរជាតិខាងកិច្ចត្រួតត្រា (C.I.C) នៅប្រទេសកម្ពុជាទៀងវិញ បើយមិនដូច្នោះទេ នៅក្នុងលិខិតដដែលនេះ រដ្ឋាភិបាលខ្មែរ បានសុំឲ្យលោកសហប្រធានទាំងពីរមេត្តាជួយធានាថា មួយរយៈពេលមានដីកនៃសន្និសិតក្រុងហ្សឺណែវ ១៩៥៤ ឲ្យជួយដោះស្រាយទៅវិញទីភាប័ទប្រទេស គឺ ទីភាកម្មយនិស្តជួនដែលបានតាំងមូលដ្ឋានខ្លួននៅលើ

ទីកដីប្រទេសកម្ពុជា (លិខិតលេខ 328/DGP/AP និងមួយទៀត លេខ 329/DGP/AP) ។

-នៅថ្ងៃ ២២ មីនា ដដែលទៀត រដ្ឋាភិបាលខ្មែរបានផ្ញើលិខិតមួយសុំទៅ (Ambassade de l'Inde à P.Penh) សុំឱ្យលោកជួយទាក់ទងជាមួយសមាជិក (C.I.C) ដូចជា Polonais និង Canadien អំពីទេរឿងតាំង C.I.C. សាជាថ្មីនៅប្រទេសកម្ពុជា (លិខិត លេខ 330/DGP/AP ចុះថ្ងៃទី ២៦ មីនា ១៩៧០) ។

-នៅថ្ងៃ ១៥ មេសា ១៩៧០ រដ្ឋាភិបាលបានសរសេរជំរាបមកឯងទៀតដល់អង្គទូតនានា ស្ថិតនៅភ្នំពេញ ព្រមទាំងជូនសេចក្តីប្រកាសមួយ ចុះថ្ងៃទី ១៤ មេសា ជាប់ជាមួយដែលស្តីពីទេរឿងទីពាក្យកុង-ហ្គូនខាងជើង ចូលទាយសុក្រប្រទេសកម្ពុជា (លិខិតលេខ 391/DGP/ ចុះថ្ងៃទី ១៥ មេសា ១៩៧០) ។

-នៅថ្ងៃ ១៥ មេសា ១៩៧០ ដដែលនេះ រដ្ឋាភិបាលបានទាយទូរលេខថ្លៃទៅគ្រប់អង្គទូតខ្មែរដែលស្ថិតនៅឯបរទេស គឺ : Belgrade, Dakar, Londres, Pékin, Pyongyang, Rangoon, Manille, Paris, Washington Via Itt Berlin Est, Varsovie, Canberra, Singapour Vientiane, Tokio, Djakarta, Prague, Lahavane, Newdelhi.

និង Monsieur CHAN SORY 45 Leninsky Prospeckt Appartement 450 Moscou.

និង Conrokhmer Hongkong

Missioncam Newyork

ដើម្បីឱ្យដឹងពីស្ថានការណ៍នៅប្រទេសខ្លួន និងឱ្យដឹងពីទេរឿងទីពាក្យកុង-ហ្គូនខាងជើង ទាយសុក្រប្រទេសកម្ពុជា បើយសូមឱ្យអស់លោកជួយទាក់ទងពីទេរឿងសុំជំនួយបរទេសឱ្យជួយខ្មែរ ដើម្បីទប់ទល់នឹងសង្គ្រាមនេះ (ទូរលេខ N°2.4141 ចុះថ្ងៃទី ១៥ មេសា ១៩៧០) ។

-នៅថ្ងៃ ៤ ឧសភា ១៩៧០ អ្នកតំណាងអចិន្ត្រៃយ៍ខ្មែរយើងនៅអង្គការសហប្រជាជាតិ គឺ លោក ឃឹម ទិត បានសរសេរទៅបរទាប់ជាយសព្វគ្រប់ពីសន្ទនាកថា លោក និច សុន ថ្លែងពីស្ថានការណ៍នៅប្រទេសកម្ពុជា នៅយប់ថ្ងៃទី ៣០ មេសា ១៩៧០ (តាមលិខិត LS/nf. N° 1967 / DGP ចុះថ្ងៃទី ៤ ឧសភា ១៩៧០) ។

-នៅថ្ងៃ ៥ ឧសភា ១៩៧០ លោក លន់ នល់ នាយកវត្តមន្ត្រី នៃរដ្ឋាភិបាលព្រះចស្រង់ជាតិ បានសរសេរថ្លែងអំណរគុណដល់លោក និច សុន ទិញអំពីជំនួយនៃ ស.ទ.អា. ដែលបានជួយប្រទេសកម្ពុជាឱ្យផុតពីការលិចលង់ដោយសង្គ្រាមនេះ ។

-បន្ទាប់មកនៅថ្ងៃ ១៦-១៧ ឧសភា ១៩៧០ ខ្ញុំនៃយើងក៏ឯងទៅចូលរួមសន្និសិត
នាក្រុង ចក្រាកាតា (Djakarta) នៅប្រទេស ឥណ្ឌូណេស៊ី ដើម្បីដោះស្រាយពីទង្វើង
សង្គ្រាមនៅប្រទេសខ្ញុំនៃយើង ។ (យើងនឹងចុះផ្សាយនូវសេចក្តីរាយការណ៍ពីទង្វើងនេះទៅ
ខាងក្រោយ) ។

-មកដល់ខែកញ្ញា ១៩៧០ ខ្ញុំនៃយើងឯងបញ្ជូនគណៈប្រតិភូទៅចូលរួមសន្និសិតកំពូល
នៅឯប្រទេសអាហ្វ្រិកខ្លះ ដែលធ្វើនៅក្រុង លូសាកា (LUSAKA) នៅប្រទេស ZAMBIE
ពីថ្ងៃ ៦ ដល់ ១០ កញ្ញា ១៩៧០ ។ (យើងនឹងចុះផ្សាយនូវសេចក្តីរាយការណ៍ពីទង្វើងនេះ
ទៅខាងក្រោយ)

ឥឡូវនេះទៅ យើងនឹងលើកយកឯកសារសព្វគ្រប់ ស្តីពីទង្វើងនយោបាយក្រៅប្រ-
ទេសរបស់នរដ្ឋាភិបាលស្រោចស្រង់ជាតិ ក្នុងការចាត់ការទទួលស្គាល់ព្រឹត្តិការណ៍ ១៨ មីនា ១៩៧០ និង
ការទទួលស្គាល់ចំពោះវិធីលបង្កកំនើតទង្វើងពីក្លែកក្លាយនិយមអាស៊ី មានយ៉ៅកក្នុង-ប្លែនខាងដើង ព្រមទាំង
ចិនក្រហមគាំទ្រពីខាងក្រោយផង ។

MINISTERE
DES
AFFAIRES ETRANGERES
-0-

Nº 325 /DGP/AP

Le Ministère des Affaires Etrangères du Gouvernement du Cambodge présente ses compliments à toutes les Missions Diplomatiques et Consulaires et les Organismes Internationaux accrédités à Phnom-Penh et, se référant à la note du Ministère nº 319-DGP du 18 Mars 1970 relative à la destitution légale du Prince Norodom Sihanouk de ses fonctions de Chef de l'Etat du Cambodge, a l'honneur de leur faire connaître que le Gouvernement Khmer tient à réaffirmer solennellement encore que le Royaume du Cambodge n'a pas changé sa politique d'indépendance, de paix, de stricte neutralité, de souveraineté et d'intégrité territoriale. Il reste toujours lié par les traités, accords, conventions internationaux etc... antérieurement contractés.

Il tient à réaffirmer également qu'il n'y a aucun changement dans la Constitution du Royaume. En effet, c'est conformément aux dispositions de cette Constitution que le Prince Norodom Sihanouk, ex-Chef d'Etat du Cambodge, a été démis officiellement, régulièrement et légalement de ses fonctions de Chef de l'Etat le 18 Mars 1970 à partir de 13 heures 00, par un vote à l'unanimité des deux Chambres réunies en Congrès.

MISSIONS DIPLOMATIQUES
ET CONSULAIRES ET LES
ORGANISMES INTERNATIONAUX

P H N O M - P E N H

La continuité légale de l'Etat du Cambodge réside dans la personne du nouveau Chef d'Etat, S.Exc. M. CHENG HENG, Président de l'Assemblée Nationale. N'ayant plus aucune prérogative légale, le Prince Norodom Sihanouk ne représente plus le Cambodge tant sur le plan intérieur du pays que sur le plan international. Il ne pourra représenter que lui-même en tant que simple individu. Toute manoeuvre subversive de sa part contre le Cambodge sera sévèrement condamnée par le Gouvernement légal du Cambodge conformément aux lois en vigueur. Le Gouvernement du Cambodge décline d'ores et déjà toute responsabilité découlant de tous les actes illégaux que pourrait commettre le Prince Norodom Sihanouk. Tous ses actes n'engagent que sa propre responsabilité en tant que simple particulier.

Le Ministère prie les Missions Diplomatiques et Consulaires et les Organismes Internationaux de bien vouloir porter ce qui précède à la connaissance de leurs Gouvernements respectifs ainsi que des Instances internationales intéressées.

Le Ministère des Affaires Etrangères saisit cette occasion pour renouveler aux Missions Diplomatiques et Consulaires et les Organismes Internationaux l'assurance de sa haute considération.

Phnom-Penh, le 20 Mars 1970

COMMUNIQUE DU GOUVERNEMENT

Le Peuple Khmer a suffisamment fait comprendre au monde qu'il n'accepte pas de tolérer que, sous prétexte de solidarité, des troupes étrangères viennent occuper son territoire et s'y comporter en maître.

Le Gouvernement de Sauvetage est déterminé plus que jamais à répondre à cette exigence unanime de la Nation tout entière et fera tout ce qui est en son pouvoir pour que cette volonté populaire se réalise effectivement.

Dans ce but, par ce communiqué il demande aux deux Co-Présidents de la Conférence de Genève de 1954 que la Commission Internationale de Contrôle (C.I.C.) vienne sans tarder reprendre sa mission au Cambodge pour l'aider à mettre fin d'une façon pacifique à l'occupation de son territoire national.

Notre Ministère des Affaires Etrangères prendra contact à cette fin avec l'Ambassade de l'Union des Républiques Socialistes Soviétiques et celle de Grande Bretagne. Il saisira cette occasion pour demander aux Co-Présidents de la Conférence de Genève de 1954 de bien vouloir informer et consulter rapidement les autres signataires de cet Accords sur la situation créée par l'occupation de son territoire par les troupes vietcongs et nord-vietnamiennes.

En même temps, le Gouvernement de Sauvetage fait entamer des pourparlers officiels avec les représentants du Gouvernement Provisoire de la République du Sud Vietnam et de la République Démocratique du Vietnam pour obtenir le retrait de leurs troupes.

PHNOM-PENH, le 21 MARS 1970

MINISTERE DES
AFFAIRES ETRANGERES
-oOo-

ROYAUME DU CAMBODGE

Nº 62 /DGP/AP/X
CONFIDENTIEL

Phnom-Penh, le 22 Mars 1970

